# មេរៀនចេតសិក



រៀបចំដោយ ៖
ឧបាសក គួច គុងហ៊ីម
ជួយកែសម្រួលអក្សរដោយ ៖
ឧបាសិកា ថាត សុខហ៊ាង

គ.ស.២០២៣
ព.ស.២៥៦៥

មេរៀនចេតសិក
ឧបាសក គួច គុងហ៊ីម
ព.ស.២៥៦៥

# មេរៀនចេតសិក



រៀបចំដោយ ៖

ឧបាសក គួច គុងហ៊ីម

ព.ស. ២៥៦៥

ជួយកែសម្រួលអក្សរដោយ ៖

ឧបាសិកា វ៉ាត សុខហ៊ាង

# មាតិកា


I. បរមត្ថធម៌ ........................................ 16

ក. អត្ថរបស់ពាក្យថាបរមត្ថធម៌មាន ៣ យ៉ាងគឺ ៖........................16

ខ. ព្រះបរិយត្តិមាន ៣ យ៉ាងគឺ ៖ ........................17

គ.បរមត្ថធម៌មាន ៤ គឺ ៖........................18

II. ចេតសិកបរមត្ថបរិច្ឆេទទី ២........................ 18

-ចេតសិក មានអាការសម្គាល់ ៤ យ៉ាងគឺ ៖ ........................19

-លក្ខណាទិចតុក្កៈរបស់ ចេតសិក ........................ 19

-សព្វចិត្តសាធារណចេតសិក ៧........................22

១. ផស្សចេតសិក ........................22

-លក្ខណាទិចតុក្កៈរបស់ ផស្សៈ........................ 23

-វត្ថុមាន ៦ គឺ ៖ ........................ 23

-វិញ្ញាណមាន ៦ គឺ ៖ ........................ 24

២. វេទនាចេតសិក........................26

-ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅ វេទនា តើដូចម្តេច?.........26

-ព្រះនាងធម្មទិន្នាថេរី ជាឯតទគ្គៈ ផ្នែកខាងធម្មកថិក........................ 26

-បពិត្រព្រះនាងម្ចាស់ តើសុខវេទនាមានអ្វីជាសុខ មានអ្វីជាទុក្ខ?............. 27

-វិសាខឧបាសក បពិត្រព្រះនាងម្ចាស់ ........................................ 28
-បើពោលដោយឥន្ទ្រិយមាន ៥ យ៉ាង ..............................................30
-សួរថា ភិក្ខុពិចារណាឃើញ វេទនាក្នុងវេទនា តើដូចម្តេច? .................... 33
-លក្ខណាទិចតុក្កៈរបស់ វេទនា ....................................................... 33
-យំកិញ្ចិ វេទយិតំ តំ ទុក្ខស្មឹ.......................................................37
៣. សញ្ញាចេតសិក ..............................................................39
-លក្ខណាទិចតុក្កៈរបស់ សញ្ញា ....................................................... 40
-សញ្ញាមាន ៣ គឺ ៖ .................................................................... 40
-ពាលមាន ៣ កម្រិត គឺ៖.............................................................. 44
-អកុសលសញ្ញា ៣ យ៉ាង ............................................................. 44
៤. ចេតនាចេតសិក ..............................................................46
-ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅ សង្ខារទាំងឡាយ តើដូចម្តេច?
................................................................................................ 47
-សភាវៈទាំងឡាយ តាក់តែងនូវសង្ខតធម៌ តើដូចម្តេច?......................... 47
-លក្ខណាទិចតុក្កៈរបស់ ចេតនា....................................................... 48
៥. ឯកគ្គតាចេតសិក .............................................................49
-លក្ខណាទិចតុក្កៈរបស់ ឯកគ្គតា...................................................... 50

**៦. ជីវិតិន្ទ្រិយចេតសិក** ........................................................ 50
-លក្ខណាទិចតុក្កៈរបស់ ជីវិតិន្ទ្រិយ ........................................................ 51
-អាយុចែកចេញជា ២ យ៉ាង ៖........................................................ 52
**៧. មនសិការចេតសិក** ........................................................ 53
-មនសិការចែកចេញជា ២ គឺ ៖ ........................................................ 54
-ការធ្វើទុកក្នុងចិត្តត្រូវ តើដូចម្តេច?........................................................ 54
-ការធ្វើទុកក្នុងចិត្តខុស តើដូចម្តេច?........................................................ 55
-លក្ខណាទិចតុក្កៈរបស់ មនសិការៈ........................................................ 56
-ចេតនា និង មនសិការចេតសិក ........................................................ 56
-មនសិការៈ និងបញ្ញាមានលក្ខណៈដូចគ្នា ឬក៏ខុសគ្នា?........................... 57
-អាហាររបស់អវិជ្ជា  អាហាររបស់វិជ្ជានិង វិមុត្តិ ........................................ 58
**-បកិណ្ណកចេតសិក ៦** ........................................................ 60
**១. វិតក្កចេតសិក** ........................................................ 60
-លក្ខណាទិចតុក្កៈរបស់ វិតក្កៈ ........................................................ 61
-ការត្រិះរិះខុសមាន ៣ ឬក៏អកុសលវិតក្កៈមាន ៣ គឺ៖........................... 61
-កាមចែកចេញជា ២ គឺ ៖........................................................ 62
-ការត្រិះរិះត្រូវមាន ៣ សម្មាសង្កប្បៈ........................................................ 67

**២. វិចារចេតសិក**....................................69
-លក្ខណាទិចតុក្កៈរបស់ វិចារៈ .................................... 69
**៣. អធិមោក្ខចេតសិក** ....................................70
-លក្ខណាទិចតុក្កៈរបស់ អធិមោក្ខៈ .................................... 71
**៤. វីរិយចេតសិក**....................................71
-លក្ខណាទិចតុក្កៈរបស់ វីរិយៈ .................................... 73
-សំវេគវត្ថុ ៨ .................................... 73
-សម្មាវាយាម សម្មប្បធាន៤.................................... 74
**៥. បីតិចេតសិក**....................................75
-លក្ខណាទិចតុក្កៈរបស់ បីតិ.................................... 75
-បីតិ ៥ យ៉ាង ៖ .................................... 76
**៦. ឆន្ទចេតសិក**....................................79
-លក្ខណាទិចតុក្កៈរបស់ ឆន្ទៈ .................................... 80
-ឆន្ទៈមាន ២ ប្រភេទ គឺ ៖.................................... 80
-ឥទ្ធិបាទធម៌ ៤ (ធម៌ដែលនាំឱ្យសម្រេចជោគជ័យ .................................... 81
**-អធិប្បាយ អកុសលចេតសិក ១៤** ....................................83
**១. មោហចេតសិក** ....................................84

-ម្នាលភិក្ខុទាំងឡាយ មោហៈ តើដូចម្តេច? ........................................ 84
-លក្ខណាទិចតុក្កៈរបស់ មោហៈ................................................................ 85
-ការកំណត់នូវអវិជ្ជា.............................................................................. 87
២. អហិរិកចេតសិក ..................................................................88
-លក្ខណាទិចតុក្កៈរបស់ អហិរិកៈ .............................................................. 88
៣. អនោត្តប្បចេតសិក ...............................................................90
-លក្ខណាទិចតុក្កៈរបស់ អនោត្តប្បៈ.......................................................... 90
៤. ឧទ្ធច្ចចេតសិក ......................................................................92
-លក្ខណាទិចតុក្កៈរបស់ ឧទ្ធច្ចៈ................................................................. 92
៥. លោភចេតសិក.......................................................................93
-ចង់បានមាន ២ យ៉ាង ៖ ......................................................................... 93
-លក្ខណាទិចតុក្កៈរបស់ លោភៈ................................................................ 94
-ក្នុងបរមត្ថទីបនី បានរៀបរាប់អំពីវេវចនៈនៃលោភៈ មាន ១០ យ៉ាងគឺ៖.... 95
៦. ទិដ្ឋិចេតសិក.........................................................................97
-មិច្ឆាទិដ្ឋិ ១០ យ៉ាងគឺ ៖ ........................................................................ 98
-លក្ខណាទិចតុក្កៈរបស់ ទិដ្ឋិ.................................................................... 99
-និយតមិច្ឆាទិដ្ឋិ ៣.................................................................................. 99

-សក្កាយទិដ្ឋិ ២០ ....................................................................102
-សក្កាយទិដ្ឋិ ២០ ដោយសង្ខេប ..............................................109
-ចុះព្រះអរិយបុគ្គលពិចារណា យ៉ាងម៉េចវិញ? ................................... 110
៧. មានចេតសិក ..................................................................112
-មានះ មាន ២ យ៉ាង ........................................................ 112
-លក្ខណាទិចតុក្កៈរបស់ មានះ ........................................ 113
៨. ទោសចេតសិក..............................................................114
-លក្ខណាទិចតុក្កៈរបស់ ទោសៈ........................................ 115
-អាឃាតវត្ថុ ១០ ............................................................ 115
៩. ឥស្សាចេតសិក..............................................................118
-លក្ខណាទិចតុក្កៈរបស់ ឥស្សា ........................................ 119
១០. មច្ឆរិយចេតសិក ..........................................................119
-មច្ឆរិយៈ ៥ យ៉ាង ៖ ........................................................ 119
-លក្ខណាទិចតុក្កៈរបស់ មច្ឆរិយៈ ................................... 121
-ព្រះពុទ្ធដីកា ................................................................ 122
១១. កុក្កុច្ចចេតសិក ..........................................................128
-ការស្តាយក្រោយមាន ២ លក្ខណៈ គឺ៖ ................................ 129

-លក្ខណាទិចតុក្កៈរបស់ កុក្កុច្ចៈ ........................................................ 129

១២. ថីនចេតសិក ........................................................ 130

-លក្ខណាទិចតុក្កៈរបស់ ថីនៈ ........................................................ 130

១៣. មិទ្ធចេតសិក ........................................................ 133

-លក្ខណាទិចតុក្កៈរបស់ មិទ្ធៈ ........................................................ 134

១៤. វិចិកិច្ឆាចេតសិក ........................................................ 135

-លក្ខណាទិចតុក្កៈរបស់ វិចិកិច្ឆា ........................................................ 136

-សោភណចេតសិក ២៥ ........................................................ 138

១. សទ្ធាចេតសិក ........................................................ 138

-អារម្មណ៍របស់សទ្ធាមាន ៤ យ៉ាងតាមន័យអភិធម្មគឺ៖ ........................ 139

-អារម្មណ៍របស់សទ្ធាមាន ៤ យ៉ាងតាមន័យព្រះសូត្រគឺ៖ ...................... 140

-កុសលឱ្យផលផ្សេងៗគ្នា មាន ៧ យ៉ាងគឺ ៖ ........................................ 141

-លោកសន្និវាស មានប្រមាណ ៤ គឺ ៖ ................................................ 143

-លក្ខណាទិចតុក្កៈរបស់ សទ្ធា ........................................................ 144

-សទ្ធា មាន ២ យ៉ាងគឺ ៖ ........................................................ 145

-អាឡវកយក្ស ........................................................ 149

-ព្រះមានព្រះភាគត្រាស់ថា៖ ........................................................ 150

-អរិយទ្រព្យទាំង ៧ ប្រការ ........................................ 152
-លក្ខណៈរបស់បុគ្គលមានសទ្ធា ៣ យ៉ាងគឺ ៖ .................................. 155
-ពន្យល់អំពី សទ្ធាពិស្តារ ........................................ 155
-អត្ថន័យថា សទ្ធា ........................................ 157
-សទ្ធា បរិសុទ្ធដោយអាការ ៣ យ៉ាង ៖ ........................................ 158
-ព្រះពុទ្ធដីកា កុលបុត្រដែលប្រកបដោយធម៌ ៣ ប្រការ ហៅថា ជាអ្នកដែលមានសទ្ធា ។ ........................................ 159
-អានិសង្សរបស់សទ្ធា ៥ យ៉ាង៖ ........................................ 160
-អដ្ឋកថា ពន្យល់អំពីសទ្ធា ........................................ 161
-បុគ្គលជ្រះថ្លា ក្នុងព្រះសាស្តា មានសភាពដូចម្តេច? ........................ 162
២. សតិចេតសិក ........................................ 165
-ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី តើដូចម្តេច ? ......166
-ពាក្យឧបមារបស់សតិ មាន ៤ យ៉ាង ៖ ........................................ 168
-លក្ខណាទិចតុក្កៈរបស់ សតិ ........................................ 171
៣. ហិរិចេតសិក ........................................ 173
-លក្ខណាទិចតុក្កៈរបស់ ហិរិ ........................................ 173
៤. ឱត្តប្បចេតសិក ........................................ 175

-លក្ខណាទិចតុក្កៈរបស់ ឱត្តប្បៈ........................................ 176
៥. អលោភចេតសិក ...............................................................178
-លក្ខណាទិចតុក្កៈរបស់ អលោភៈ ..................................... 178
៦. អទោសចេតសិក ...............................................................179
-លក្ខណាទិចតុក្កៈរបស់ អទោសៈ ..................................... 179
-មេត្តានិមិត្ត....................................................................... 180
-គុណនៃមេត្តា ការចម្រើនមេត្តាចិត្ត .................................... 181
៧. តត្រមជ្ឈត្តតាចេតសិក.......................................................182
-លក្ខណាទិចតុក្កៈរបស់ តត្រមជ្ឈត្តតា ................................ 183
-យុគលធម៌ ៦ គូ...................................................................184
-យុគលធម៌គូទី ១ ...............................................................184
-លក្ខណាទិចតុក្កៈរបស់ បស្សទ្ធិ........................................ 184
-យុគលធម៌គូទី ២ ...............................................................185
-លក្ខណាទិចតុក្កៈរបស់ លហុតា........................................ 185
-យុគលធម៌គូទី ៣.............................................................. 186
-លក្ខណាទិចតុក្កៈរបស់ មុទុតា ......................................... 186
-យុគលធម៌គូទី ៤ ...............................................................187

-លក្ខណាទិចតុក្កៈរបស់ កម្មញ្ញតា ........................................ 187
-នីវរណធម៌ ៥ ........................................................ 188
-នីវរណធម៌ ៦ ........................................................ 188
-យុគលធម៌គូទី ៥ ........................................................ 189
-លក្ខណាទិចតុក្កៈរបស់ បាគុញ្ញតា ........................................ 189
-យុគលធម៌គូទី ៦ ........................................................ 190
-លក្ខណាទិចតុក្កៈរបស់ ឧជុកតា ........................................ 190
-វិរតិចេតសិក ៣ ........................................................ 191
២០. សម្មាវាចាចេតសិក ........................................................ 191
-សម្មាវាចា ៤ ........................................................ 191
-លក្ខណាទិចតុក្កៈរបស់ សម្មាវាចា ........................................ 193
២១. សម្មាកម្មន្តចេតសិក ........................................................ 197
-លក្ខណាទិចតុក្កៈរបស់ សម្មាកម្មន្តៈ ........................................ 198
-សីល ៥ = កល្យាណធម៌ ៥ ........................................ 200
២២. សម្មាអាជីវចេតសិក ........................................................ 203
-មិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតខុស ៥ យ៉ាង ៖ ........................................ 205
-លក្ខណាទិចតុក្កៈរបស់ សម្មាអាជីវៈ ........................................ 207

-អធិប្បាយវិរតិ ៣ ........................................ 208
-អប្បមញ្ញាចេតសិក ២ ........................................ 209
២៣. ករុណាចេតសិក ........................................210
-លក្ខណាទិចតុក្កៈរបស់ ករុណា ........................................ 210
-សម្បត្តិ និង វិបត្តិ របស់ករុណា ៖ ........................................ 212
២៤. មុទិតាចេតសិក........................................213
-លក្ខណាទិចតុក្កៈរបស់ មុទិតា ........................................ 213
-សម្បត្តិ និង វិបត្តិ របស់មុទិតា ៖........................................ 214
-អប្បមញ្ញា ឬ ព្រហ្មវិហារធម៌ ៤ ........................................ 215
១. មេត្តា ........................................ 216
-គុណធម៌មេត្តារបស់ព្រះសារីបុត្ត ៩ ចំណុច ៖........................................ 217
-មេត្តានិមិត្ត........................................ 219
-មេត្តាភាវនាមានអានិសង្ស ១១ ប្រការគឺ ៖........................................ 221
២. ករុណា........................................ 222
៣. មុទិតា........................................ 223
៤. ឧបេក្ខា ........................................ 224
២៥. បញ្ញាចេតសិក........................................228

-ម្នាលភិក្ខុទាំងឡាយ បញ្ញា តើដូចម្តេច?........................................ 228
-តើមុនទៅធ្វើ វិបស្សនា គួរទៅរៀនអ្វី?........................................ 229
-ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី តើដូចម្តេច? ......232
-អវិជ្ជា គឺសេចក្តីមិនដឹងក្នុងធម៌ ៨ យ៉ាង ........................................ 233
-វិជ្ជា គឺការដឹងច្បាស់ក្នុងធម៌ ៨ យ៉ាង........................................ 233
-ការកំណត់នូវអវិជ្ជា........................................................ 234
-លក្ខណាទិចតុក្កៈរបស់ បញ្ញា ........................................ 235
-លក្ខណាទិចតុក្កៈរបស់ បញ្ញា ន័យម៉្យាងទៀត.................................. 236
-ហេតុនាំឱ្យកើតបញ្ញាមាន ៣ យ៉ាងគឺ ៖ ........................................ 242
-តើការស្តាប់ធម៌ក៏អាចសម្រេចមគ្គផលបានដែរ? ................................ 243
III. លំដាប់នៃព្រះសទ្ធម្ម មាន ៣ គឺ ៖ ........................................ 245
-ការចាំធម៌ ការយល់ធម៌ ការបដិបត្តិធម៌ ការចាក់ធ្លុះធម៌ ...................... 246
-ព្រះអស្សជិពោលធម្មបរិយាយចំពោះបរិព្វាជកឈ្មោះសារីបុត្ត.............. 248
-ធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធសម្តែងចុះ ២ លក្ខណៈគឺ ៖ .............. 248
-អរិយមគ្គអង្គ ៨ ប្រការ អង្គធម៌ បានដល់អ្វីខ្លះ?.................................. 250
IV. ចេតសិក ៥២ ដោយសង្ខេប........................................................ 251
ក. អញ្ញសមានាចេតសិក ១៣ ...................................................251

**ខ. អកុសលចេតសិក ១៤**......................................................................252

**គ. សោភណចេតសិក ២៥**......................................................................253

-ថ្ងៃល្អនៃជីវិត ........................................................................ 258

-ពាក្យខមាទោសចំពោះព្រះរតនត្រៃ .............................................. 259

-ការផ្សាយមេត្តាចំពោះសព្វសត្វ.................................................... 260

# មេរៀនចេតសិកបរមត្ថ

-ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយ ឱ្យបានដឹង សង្ខារទាំងឡាយ មានសេចក្ដីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងឡាយទាំងពួងឱ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ៕

-សូមសាធុជនទាំងឡាយ សិក្សាដោយចិត្តរីករាយ ដែលមានចិត្តភក្ដី ចំពោះព្រះរតនត្រៃ សូមអនុមោទនានូវបុណ្យរបស់ខ្ញុំដែលសម្រេចហើយដោយប្រការយ៉ាងនេះ។

-ខ្ញុំបាទ សូមឧទ្ទិសកុសលជូនមាតាបិតាជាព្រះអរហន្តបច្ចុប្បន្ន ព្រមទាំង អតីតកាលផង ពួកញាតិក្នុងសង្សារវដ្តផង និងសព្វសត្វក្នុងត្រៃលោកផង លោកគ្រូទាំងពីរផងគឺ ៖

លោកម្ចាស់គ្រូ វជិរប្បញ្ញោ សាន សុជា

លោកគ្រូ ធម្មាចារ្យ អ៊ឹម រ៉ៃយ៉ា

កណ្ដាល ថ្ងៃ ២ រោច ខែ អាសាឍ ឆ្នាំ ឆ្លូវ ព.ស.២៥៦៥

រៀបរៀងដោយ ឧបាសក គួច គុងហ៊ីម

ជួយកែសម្រួលអក្សរដោយ ឧបាសិកា វ៉ាត សុខហ៊ាង

# សិក្សាព្រះអភិធម្ម

## I. បរមត្ថធម៌

-ពាក្យថា បរមត្ថ មកពី បរម + អត្ថ = បរមត្ថ

-បរម ប្រែថា ប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត

-អត្ថ ប្រែថា អត្ថ សេចក្តី ឬន័យ

-រួមពាក្យទាំងពីរចូលគ្នា បានជា បរមត្ថ ប្រែថា អត្ថ ឬសេចក្តីដ៏ប្រសើរ។

### ក. អត្ថរបស់ពាក្យថាបរមត្ថធម៌មាន ៣ យ៉ាងគឺ៖

១. ជាអត្ថដ៏ប្រសើរ ឬមិនវិបរិត ឬប្រែប្រួល។

២. ជាប្រធាននៃបញ្ញត្តិធម៌។

៣. ជាទីគោចរនៃញាណដ៏ប្រសើរ (គឺអរិយញ្ញាណ) ដែលជាលោកុត្តរ មគ្គញាណគឺជាញាណដ៏ប្រសើរដែលមានព្រះនិព្វានជាទីគោចរ ឬជាអារម្មណ៍។

## ខ. ព្រះបរិយត្តិមាន ៣ យ៉ាងគឺ ៖

១. អលគទ្ទូបរិយត្តិ បរិយត្តិប្រៀបដូចអាសិរ្ពិសកាច។

២. និស្សរណបរិយត្តិ បរិយត្តិដើម្បីត្រូវការរលាស់ខ្លួនចេញ។

៣. ភណ្ឌាគារិកបរិយត្តិ បរិយត្តិប្រៀបដូចជានាយឃ្លាំង។

(សម្រាប់តែព្រះអរហន្តទាំងឡាយ លោកសិក្សា រៀនសូត្រ ដើម្បីរក្សាសាសនាព្រះពុទ្ធ)។

-អ្នករៀនធម៌ យល់ដំបូងៗ គឺចូលចំណុចទី១ ហ្នឹងឯង គឺរៀនធម៌ដោយមានបំណងតែខាងលើកទោសគេផង ដោយមានបំណងតែខាងដោះស្រាយនូវវាទៈ ដូច្នេះ ដូច្នោះផង។

ការសិក្សានូវបរិយត្តិធម៌ មិនបានល្អ គឺមានគ្រោះថ្នាក់ច្រើន មានវិបត្តិច្រើនប្រការ។

-ឧបមា ដូចជាមនុស្សចេះវិជ្ជាអ្វីមួយ វិជ្ជានឹងមិនអាក្រក់អីទេ ប៉ុន្តែបើមនុស្សអាក្រក់រៀនចេះ អាចធ្វើអំពើអាក្រក់...។

ឧទាហរណ៍ រឿងបុរសផ្ទាត់គ្រាប់ក្រួស ចំព្រះបច្ចេកពុទ្ធ...។

-ព្រះវិន័យ រៀនមិនល្អកើតមានះ ព្រះសូត្រ រៀនមិនល្អកើតទិដ្ឋិ ព្រះអភិធម្ម រៀនមិនល្អ ឆ្កួត។

(បិដកលេខ ២១ អលគទ្ទូបមសូត្រ ទំព័រ៣៩~៤៧ )

## គ.បរមត្ថធម៌មាន ៤ គឺ៖

១. ចិត្តបរមត្ថ បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង។

២. ចេតសិកបរមត្ថ បានដល់ ចេតសិក ៥២។

៣. រូបបរមត្ថ បានដល់ រូប ២៨។

៤. និព្វានបរមត្ថ បានដល់ ព្រះនិព្វាន។

## II. ចេតសិកបរមត្ថបរិច្ឆេទទី ២

-ចេតសិក គឺជាធម៌ដែលកើតអាស្រ័យនឹងចិត្ត ឬជាធម៌ប្រកបជាមួយនឹងចិត្ត ប្រៀបដូចសិស្សនិងគ្រូ ដែលត្រូវអាស្រ័យគ្នាទើបអាចញ៉ាំងថ្នាក់រៀនមួយឱ្យប្រព្រឹត្តទៅបាន។

-ចេតសិកំ ធម្មជាតិកើតក្នុងចិត្ត ឬប្រកបក្នុងចិត្ត ឈ្មោះថា ចេតសិក។

ឧទាហរណ៍ ដូចជាក្រុមហ៊ុនមួយអ៊ីចឹង មានប្រធាននិងអ្នកធ្វើការ រីឯចិត្តដូចជាប្រធានក្រុមហ៊ុន ចំណែកឯចេតសិក ដូចជាអ្នកធ្វើការជាមួយ...។

## -ចេតសិក មានអាការសម្គាល់ ៤ យ៉ាងគឺ ៖

១. ឯកុប្បាទៈ   កើតព្រមជាមួយនឹងចិត្ត។

២. ឯកនិរោធៈ  រលត់ទៅជាមួយនឹងចិត្ត។

៣. ឯកាលម្ពណៈ មានអារម្មណ៍តែមួយជាមួយនឹងចិត្ត គឺថា ចិត្តដឹងអារម្មណ៍ណា ចេតសិកក៏ដឹងនូវអារម្មណ៍នោះ។

៤. ឯកវត្ថុកៈ  មានវត្ថុតែមួយជាមួយនឹងចិត្ត គឺថា ចិត្តអាស្រ័យវត្ថុណា ចេតសិកក៏អាស្រ័យវត្ថុនោះ (វត្ថុមាន ៦ គឺ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ និង ហទយវត្ថុ)។

## -លក្ខណាទិចតុក្កៈរបស់ ចេតសិក

១. ចិត្តនិស្សិតលក្ខណំ  មានការអាស្រ័យនឹងចិត្ត ជាលក្ខណៈ។

២. អវិយោគុប្បាទនរសំ មានការកើតរួមជាមួយនឹងចិត្តជាកិច្ច។

៣. ឯកាលម្ពណបច្ចុប្បដ្ឋានំ មានអារម្មណ៍តែមួយជាមួយនឹង ចិត្ត ជាអាការប្រាកដ។

៤. ចិត្តុប្បាទបទដ្ឋានំ មានការកើតឡើងនៃចិត្ត ជាហេតុជិត។

## ចេតសិក ៥២

**អញ្ញសមានា ១៣**

១- ផស្សៈ
២- វេទនា
៣- សញ្ញា
៤- ចេតនា
៥- ឯកគ្គតា
៦- ជីវិតិន្ទ្រិយ
៧- មនសិការៈ
៨- វិតក្កៈ
៩- វិចារៈ
១០- អធិមោក្ខៈ
១១- វិរិយៈ
១២- បីតិ
១៣- ឆន្ទៈ

**អកុសលចេតសិក ១៤**

១- មោហៈ
២- អហិរិកៈ
៣- អនោត្តប្បៈ
៤- ឧទ្ធច្ចៈ
៥- លោភៈ
៦- ទិដ្ឋិ
៧- មានៈ
៨- ទោសៈ
៩- ឥស្សា
១០- មច្ឆរិយៈ
១១- កុក្កុច្ចៈ
១២- ថីនៈ
១៣- មិទ្ធៈ
១៤- វិចិកិច្ឆា

**សោភណចេតសិក ២៥**

១- សទ្ធា
២- សតិ
៣- ហិរិ
៤- ឱត្តប្បៈ
៥- អលោភៈ
៦- អទោសៈ
៧- តត្រមជ្ឈត្តតា
៨- កាយបស្សទ្ធិ
៩- ចិត្តបស្សទ្ធិ
១០- កាយលហុតា
១១- ចិត្តលហុតា
១២- កាយមុទុតា
១៣- ចិត្តមុទុតា
១៤- កាយកម្មញ្ញតា
១៥- ចិត្តកម្មញ្ញតា
១៦- កាយបាគុញ្ញតា
១៧- ចិត្តបាគុញ្ញតា
១៨- កាយុជុកតា
១៩- ចិត្តុជុកតា
២០- សម្មាវាចា
២១- សម្មាកម្មន្តៈ
២២- សម្មាអាជីវៈ
២៣- ករុណា
២៤- មុទិតា
២៥- បញ្ញា

17

មើលវីដេអូ ភាគទី 3

## អញ្ញសមានាចេតសិក ១៣ ចែកជាពីរពួក

**សព្វចិត្តសាធារណចេតសិក ៧**

| | |
|---|---|
| ១- ផស្សៈ | ការប៉ះខ្ទប់ |
| ២- វេទនា | ការសោយអារម្មណ៍ |
| ៣- សញ្ញា | ការចងចាំ |
| ៤- ចេតនា | ការតាំងចិត្ត |
| ៥- ឯកគ្គតា | ការមិនរវើរវាយ |
| ៦- ជីវិតិន្ទ្រិយ | ការរក្សាសហជាតធម៌ |
| ៧- មនសិការៈ | ការរួបរួមសហជាតធម៌ |

**បកិណ្ណកចេតសិក ៦**

| | |
|---|---|
| ១- វិតក្កៈ | ការលើកចិត្តឡើងកាន់អារម្មណ៍ |
| ២- វិចារៈ | ការពិចារណា |
| ៣- អធិមោក្ខៈ | ការដាក់ចិត្តស៊ប់ (សន្និដ្ឋាន) |
| ៤- វិរិយៈ | ការឧស្សាហ៍ |
| ៥- បីតិ | ការឆ្អែតចិត្ត |
| ៦- ឆន្ទៈ | ការប្រាថ្នាដើម្បីធ្វើ |

18

-ពាក្យថា អញ្ញសមានា ( អញ្ញ + សមានា ) ប្រែថា ស្មើនឹងធម៌ដទៃដែរ គឺជាចេតសិកនេះប្រកបនឹងចិត្តជាកុសល ក៏ជាកុសល បើប្រកបនឹងចិត្តជាអកុសល ក៏ជាអកុសល បើប្រកបនឹងចិត្តជាអព្យាកតៈ ក៏ជាអព្យាកតៈ ដោយហេតុនេះ ទើប ហៅថា អញ្ញសមានាចេតសិក ។

-ពាក្យថា សព្វចិត្តសាធារណៈ ( សព្វ + ចិត្ត + សាធារណៈ ) ប្រែថា ទូទៅដល់ចិត្តទាំងពួង គឺប្រកបនឹងចិត្តគ្រប់ទាំងអស់ ។

-ពាក្យថា បកិណ្ណកៈ គឺចេតសិកដែលច្របូកច្របល់បន្ទាប់បន្សំ មិនប្រកបនឹងចិត្តទាំងអស់ទេ គឺប្រកបបានចំពោះតែដួងខ្លះៗ ដែលគួរនឹងប្រកបប៉ុណ្ណោះ ។

-ពាក្យថា អកុសលចេតសិក បានដល់ ចេតសិកមិនល្អ ប្រកបនឹងចិត្តហើយ ក៏ធ្វើឱ្យចិត្តនោះទៅជាអកុសល សៅហ្មងជាដើម ។

-ពាក្យថា សោភណចេតសិក បានដល់ ចេតសិកដែលល្អ កាលណាប្រកបជាមួយចិត្តហើយ ក៏តែងធ្វើឱ្យចិត្តនោះ ឱ្យជាកាមាវចរសោភណចេតសិក ជារូបាវចរចិត្តខ្លះ ជាអរូបាវចរចិត្តខ្លះ និងជាលោកុត្តរចិត្តខ្លះ ។

# -សព្វចិត្តសាធារណចេតសិក ៧

## ១. ផស្សចេតសិក

ផុស្សតីតិ = ផស្សោ ធម៌ដែលឈ្មោះថា ផស្សៈ ព្រោះអត្ថថាប៉ះខ្ទប់។ ម្យ៉ាងទៀត ផស្សចេតសិកនេះ ព្រះនាគសេនត្ថេរ បានវិសជ្ជនាឱ្យស្ដេច ព្រះបាទមិលិន្ទជ្រាបថា ប្រៀបដូច ពពៃ ២ ពពៃមួយដូចជាអាយតនៈខាងក្នុង (ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត) ពពៃមួយទៀតដូចជាអាយតនៈខាងក្រៅ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍) ផស្សៈ ដូចជាការជល់គ្នានៃពពៃទាំងពីរនោះឯង។

-ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅថា ផស្សៈ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណាប៉ះពាល់ ពាល់ត្រូវ ការទង្គក់ទង្គិច ការប៉ះខ្ទប់ ណាក្នុងសម័យនោះ នេះហៅថា ផស្សៈ ។

-តួនាទីរបស់ ផស្សៈ គឺការប៉ះខ្ទប់អារម្មណ៍ដែលចិត្តដឹង និងជាបច្ច័យឱ្យធម៌ ៣ ប្រជុំគ្នា គឺ អារម្មណ៍ វត្ថុ និង វិញ្ញាណ។

**-ធម៌ ៣ ប្រជុំគ្នាគឺ អារម្មណ៍ វត្ថុ និង វិញ្ញាណ ។**

## -លក្ខណាទិចតុក្កៈរបស់ ផស្សៈ

១. ផុស្សនលក្ខណោ មានការប៉ះខ្ទប់ ជាលក្ខណៈ។

២. សង្ឃដ្តនរសោ មានការធ្វើឱ្យចិត្ត និងអារម្មណ៍ប៉ះខ្ទប់គ្នា ជាកិច្ច។

៣. សន្និបាតបច្ចុប្បដ្ឋានោ មានការប្រជុំរវាងអារម្មណ៍ វត្ថុ ចិត្ត ជាអាការប្រាកដ។

៤. អាបាថគតវិសយបទដ្ឋានោ មានអារម្មណ៍មកកាន់គន្លង ជាហេតុជិត។

## -វត្ថុមាន ៦ គឺ ៖

១. ចក្ខុវត្ថុ (ភ្នែក) អង្គធម៌ ចក្ខុបសាទរូប

២. សោតវត្ថុ (ត្រចៀក) អង្គធម៌ សោតបសាទរូប

៣. ឃានវត្ថុ (ច្រមុះ) អង្គធម៌ ឃានបសាទរូប

៤. ជិវ្ហាវត្ថុ (អណ្តាត) អង្គធម៌ ជិវ្ហាបសាទរូប

៥. កាយវត្ថុ (កាយ) អង្គធម៌ កាយបសាទរូប

៦.ហទយវត្ថុ (បេះដូង) អង្គធម៌ហទយវត្ថុរូប

## -អារម្មណ៍មាន ៦ គឺ ៖

១.រូបារម្មណ៍ (រូប) ២. សទ្ទារម្មណ៍ (សំឡេង)

៣. គន្ធារម្មណ៍ (ក្លិន) ៤. រសារម្មណ៍ (រស)

៥. ផោដ្ឋព្វារម្មណ៍ (បឋវី តេជោ វាយោ) ៦. ធម្មារម្មណ៍

## -វិញ្ញាណមាន ៦ គឺ ៖

១. ចក្ខុវិញ្ញាណ ២. សោតវិញ្ញាណ

៣. ឃានវិញ្ញាណ ៤. ជីវ្ហាវិញ្ញាណ

៥. កាយវិញ្ញាណ ៦. មនោវិញ្ញាណ

## -ម្នាលភិក្ខុទាំងឡាយ ផស្សាហារ ត្រូវយល់ដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ ផស្សាហារត្រូវយល់ដូចជា មេគោអត់ស្បែក ។

១. បើឈរផ្អែកនឹងជញ្ជាំងក៏ត្រូវពួកសត្វអាស្រ័យជញ្ជាំងនោះខាំ។

២. បើឈរផ្អែកនឹងដើមឈើក៏ត្រូវពួកសត្វអាស្រ័យនឹងដើមឈើនោះខាំ។

៣. បើឈរត្រាំក្នុងទឹក ក៏ត្រូវពួកសត្វអាស្រ័យនៅក្នុងទឹកនោះ

ខាំ ទិច ចឹក ។

៤. បើឈរនៅកណ្តាលអាកាស ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងអាកាសខាំស៊ី។

-ម្នាលភិក្ខុទាំងឡាយ មេគោដែលឈរនៅក្នុងទីណាៗក៏ត្រូវសត្វដែលអាស្រ័យនៅទីនោះៗខាំស៊ីដែរ យ៉ាងណាមិញម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវយល់ថាផស្សាហារក៏យ៉ាងនោះដែរ ។

-ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងនូវផស្សាហារ ហើយក៏ឈ្មោះបានកំណត់ដឹងនូវវេទនាទាំង ៣ ដែរ កាលបើកំណត់ដឹងនូវវេទនាទាំង ៣ ហើយ តថាគតពោលថា កិច្ចការណាមួយដែលអរិយសាវ័ក ត្រូវធ្វើតទៅទៀតមិនមានឡើយ ។

-ផ្ទះដែលប្រក់ខ្ចីខ្ចាហើយ តំណក់ទឹកភ្លៀងរមែងលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោត យ៉ាងនោះឯង ។

-ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតយ៉ាងនោះឯង ។

(បិដកលេខ ៥២ យមកវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះព្រះនន្ទត្ថេរ)

# ២. វេទនាចេតសិក

-ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណារងនូវអារម្មណ៍ ឬក៏សោយនូវអារម្មណ៍ ធម្មជាតិនោះហៅថា វេទនា ។

-ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅ វេទនា តើដូចម្ដេច?

-ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណារងនូវអារម្មណ៍ ធម្មជាតិនោះហៅថា វេទនា ។

## -ចុះធម្មជាតិនោះ រងនូវអ្វីខ្លះ?

-រងនូវសុខក៏មាន រងនូវទុក្ខក៏មាន រងនូវអទុក្ខមសុខក៏មាន។

-បិដកអដ្ឋកថាលេខ ១៥ ចូឡវេទល្លសូត្រទី៤ ទំព័រ៤៥១~៤៩១

## -ព្រះនាងធម្មទិន្នាថេរី ជាឯតទគ្គៈ ផ្នែកខាងធម្មកថិក

-បពិត្រព្រះនាងម្ចាស់ ចុះសុខវេទនា តើដូចម្ដេច?

-បពិត្រព្រះនាងម្ចាស់ ចុះទុក្ខវេទនា តើដូចម្ដេច?

-បពិត្រព្រះនាងម្ចាស់ ចុះអទុក្ខមសុខវេទនា តើដូចម្ដេច?

-ម្នាលអាវុសោវិសាខ ធម្មជាតិណាដែលទទួលរងនូវអារម្មណ៍ជាសុខដ៏ឆ្ងាញ់ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្តក្ដី នេះហៅថា សុខវេទនា ។

-ម្នាលអាវុសោវិសាខ ធម្មជាតិណាដែលទទួលរងនូវអារម្មណ៍ជាទុក្ខមិនឆ្ងាញ់ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅនៅក្នុងចិត្តក្តី នេះ ហៅថា ទុក្ខវេទនា ។

-ម្នាលអាវុសោវិសាខ ធម្មជាតិណាដែលទទួលរងនូវអារម្មណ៍ឆ្ងាញ់ក៏មិនមែន មិនឆ្ងាញ់ក៏មិនមែន ប្រព្រឹត្តទៅក្នុងកាយក្តីប្រព្រឹត្តទៅក្នុងចិត្តក្តី នេះ ហៅថា អទុក្ខមសុខវេទនា ។

-បពិត្រព្រះនាងម្ចាស់ តើសុខវេទនាមានអ្វីជាសុខ មានអ្វីជាទុក្ខ?

-ម្នាលអាវុសោវិសាខ សុខវេទនាមានកិរិយាឋិតនៅដដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ។

-ម្នាលអាវុសោវិសាខ ទុក្ខវេទនាមានកិរិយាឋិតនៅដដែលជាទុក្ខ មានការប្រែប្រួលទៅវិញជាសុខ ។

-ម្នាលអាវុសោវិសាខ អទុក្ខមសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹងជាទុក្ខ ។

-ការកំណត់វេទនា វេទនាណាមានបច្ច័យឱ្យកើតឡើងមុនកំណត់មុន ព្រោះវេទនាអាចកើតឡើងម្តងបានតែមួយទេ ។

-សម័យណាបុគ្គលទទួលនូវ សុខវេទនា សម័យនោះមិនទទួល ទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនា ក្នុងសម័យនោះទទួល ចំពោះតែ សុខវេទនា ។

-សម័យណាបុគ្គលទទួលនូវ ទុក្ខវេទនា សម័យនោះមិនទទួល សុខវេទនា មិនទទួលអទុក្ខមសុខវេទនា ក្នុងសម័យនោះ ទទួលចំពោះតែ ទុក្ខវេទនា ។

-សម័យណាបុគ្គលទទួលនូវ អទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនា ក្នុងសម័យនោះ ទទួលចំពោះតែ អទុក្ខមសុខវេទនា ។

## -វិសាខឧបាសក បពិត្រព្រះនាងម្ចាស់

១. ចុះសុខវេទនា មានអ្វី ជាគ្រឿងប្រៀបផ្ទៀបឱ្យប្រហែលគ្នា?

២. ចុះទុក្ខវេទនា មានអ្វី ជាគ្រឿងប្រៀបផ្ទៀប?

៣. អទុក្ខមសុខវេទនា មានអ្វីជាគ្រឿងប្រៀបផ្ទៀប?

## -ព្រះនាងធម្មទិន្នាថេរី ម្នាលអាវុសោវិសាខ

១. សុខវេទនា មានរាគៈជាគ្រឿងប្រៀបផ្ទៀប។

២. ទុក្ខវេទនា មានបដិឃៈជាគ្រឿងប្រៀបផ្ទៀប។

៣. អទុក្ខមសុខវេទនា មានអវិជ្ជាជាគ្រឿងប្រៀបផ្ទៀប។

៩. អវិជ្ជា មានវិជ្ជាជាគ្រឿងប្រៀបធៀប។

-វេទនាណា ដែលយើងទទួលរងដោយអំណាចផស្ស: នៃអវិជ្ជា ការរងនូវវេទនាទាំង ៣ ដោយផស្ស: នៃអវិជ្ជា គឺតណ្ហារមែង កើតឡើង កាលណាសេចក្តីប្រាថ្នារមែងកើតឡើងហើយ បុគ្គលនោះក៏រមែងពិចារណា ឃើញថាវេទនាជាខ្លួន ឃើញថា វេទនាជារបស់ខ្លួន កាលបើឃើញបែបនេះ ដោយសារតែ មិន បានស្តាប់ធម៌ មិនបានសិក្សាធម៌ ជាប្រក្រតីនៃការទទួលរងនូវ អារម្មណ៍ហើយ តណ្ហារមែង កើតឡើង ។

-ដល់ពេលយើងបានស្តាប់នូវព្រះធម៌មក សុខវេទនាក្តី ទុក្ខ វេទនាក្តី អទុក្ខមសុខវេទនាក្តី គឺឃើញថាវេទនាទាំង ៣ នេះគឺ ជាធម៌ដែលកើតពីបច្ច័យគឺមានផស្ស:ជាបច្ច័យ នៃអវិជ្ជា បុគ្គល នោះពាល់ត្រូវហើយនូវវេទនាដូចគ្នា ដដែល ក៏ប៉ុន្តែបុគ្គលនោះ បានពិចារណាត្រឡប់បាននូវ សម្មាទិដ្ឋិ បានការយល់ត្រូវ មិន ពិចារណា ឃើញថាវេទនានោះជាខ្លួន ឃើញថាវេទនានោះជា របស់ខ្លួន គឺឃើញត្រឹមតែជាធម៌ដែលកើតពីបច្ច័យ គឺមានផ ស្ស:ជាបច្ច័យ ដែលមានអវិជ្ជាជាឫសគល់ ។

-ព្រះសម្មាសម្ពុទ្ធព្រះអង្គសម្តែង ជាមួយភិក្ខុចូលសួរព្រះអង្គ តើ បុគ្គលឃើញដូចម្តេច ដឹងដូចម្តេច ទើបអាចលះបង់អាសវ:ជា លំដាប់បាន?

-បុគ្គលដែលបានពិចារណាឃើញថា វេទនាទាំង ៣ នេះ មិនទៀង ជាទុក្ខ ជាអនត្តា ឃើញថា នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនរបស់អញ បុគ្គលនោះអាចលះបង់អាសវៈជាលំដាប់បាន បុគ្គលនោះ ឈ្មោះថា ដល់ព្រះនិព្វានក្នុងបច្ចុប្បន្ន ។

-កាលបើបុគ្គលបានឃើញថា បញ្ចក្ខន្ធ (ខន្ធ ៥) មិនទៀង ជាទុក្ខ ជាអនត្តា ឃើញថា នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនរបស់អញ បុគ្គលនោះ ឈ្មោះថា ដល់ព្រះនិព្វានក្នុងបច្ចុប្បន្ន ។

(បិដកអដ្ឋកថាលេខ ២៤ សុខិន្ទ្រិយវគ្គទី ៤ ទំព័រ២៥៣~២៧៦)

## -បើពោលដោយឥន្ទ្រិយមាន ៥ យ៉ាង

-ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះ មាន ៥ យ៉ាងគឺ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

# ១. សុខិន្ទ្រិយ

-ម្នាលភិក្ខុទាំងឡាយ ចុះ សុខិន្ទ្រិយ តើដូចម្ដេច?

-ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខ សេចក្ដីត្រេកអរ ឯណាដែលប្រព្រឹត្តទៅនៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្ដីសុខ និងសេចក្ដីត្រេកអរនោះដែលកើតអំពី កាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា សុខិន្ទ្រិយ ។

# ២. ទុក្ខិន្ទ្រិយ

-ម្នាលភិក្ខុទាំងឡាយ ចុះ ទុក្ខិន្ទ្រិយ តើដូចម្ដេច?

-ម្នាលភិក្ខុទាំងឡាយ សេចក្ដីទុក្ខ សេចក្ដីមិនត្រេកអរ ឯណាដែលប្រព្រឹត្តទៅនៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្ដីទុក្ខ និងសេចក្ដីមិនត្រេកអរនោះដែលកើតអំពី កាយសម្ផស្ស។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ទុក្ខិន្ទ្រិយ ។

# ៣. សោមនស្សិន្ទ្រិយ

-ម្នាលភិក្ខុទាំងឡាយ ចុះ សោមនស្សិន្ទ្រិយ តើដូចម្ដេច?

-ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខ សេចក្ដីត្រេកអរ ឯណាដែលប្រព្រឹត្តទៅនៅក្នុងចិត្ត បុគ្គលក៏បានសោយនូវសេចក្ដីសុខ និង

សេចក្តីត្រេកអរនោះដែលកើតអំពី មនោសម្ផស្ស ។ ម្នាលភិក្ខុ ទាំងឡាយ នេះ ហៅថា សោមនស្សិន្ទ្រិយ ។

# ៤. ទោមនស្សិន្ទ្រិយ

-ម្នាលភិក្ខុទាំងឡាយ ចុះ ទោមនស្សិន្ទ្រិយ តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីមិនត្រេកអរ ឯណា ដែលប្រព្រឹត្តទៅនៅក្នុងចិត្ត បុគ្គលក៏បានសោយនូវសេចក្តីទុក្ខ និងសេចក្តីមិនត្រេកអរនោះដែលកើតអំពី មនោសម្ផស្ស។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ទោមនស្សិន្ទ្រិយ។

# ៥. ឧបេក្ខិន្ទ្រិយ

-ម្នាលភិក្ខុទាំងឡាយ ចុះ ឧបេក្ខិន្ទ្រិយ តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ បុគ្គលបានសោយនូវអារម្មណ៍មិនជាទីត្រេកអរក៏មិនមែន ជាទីត្រេកអរក៏មិនមែន ឯណា ដែលប្រព្រឹត្តទៅក្នុងកាយក្តី ប្រព្រឹត្តទៅក្នុងចិត្តក្តី ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ឧបេក្ខិន្ទ្រិយ ។

-ម្នាលភិក្ខុទាំងឡាយ បណ្តា ឥន្ទ្រិយទាំងនោះ សុខិន្ទ្រិយ និង សោមនស្សិន្ទ្រិយ បណ្ឌិតគប្បីឃើញថាជា សុខវេទនា ។

-ម្នាលភិក្ខុទាំងឡាយ បណ្តា ឥន្ទ្រិយទាំងនោះ ទុក្ខិន្ទ្រិយ និង ទោមនស្សិន្ទ្រិយ បណ្ឌិតគប្បីឃើញថាជា ទុក្ខវេទនា ។

-ម្នាលភិក្ខុទាំងឡាយ បណ្ដា ឥន្ទ្រិយទាំងនោះ ឧបេក្ខិន្ទ្រិយ បណ្ឌិតគប្បីឃើញថាជា អទុក្ខមសុខវេទនា។

-ឥន្ទ្រិយ ៥ បង្រួមមកជា ៣ ក៏បាន ចែកចេញជា ៥ ក៏បាន ដោយបរិយាយដូច្នេះឯង ។

## -សួរថា ភិក្ខុពិចារណាឃើញ វេទនាក្នុងវេទនា តើដូចម្ដេច?

-ឆ្លើយថា ពិចារណាឃើញ សុខវេទនា (ថាជាទុក្ខ) ឃើញទុក្ខវេទនា (ថាដូចជា កូនសរ ជាព្រួញសម្រាប់បាញ់ បាញ់ចំពេលណាកើតទុក្ខពេលនោះ) ឃើញអទុក្ខមសុខវេទនា (ថាជារបស់មិនទៀង)។ ភិក្ខុនោះឯង ជាអ្នកឃើញត្រូវ និងជាអ្នកស្ងប់ ហើយត្រាច់ទៅ ។

## -លក្ខណាទិចតុក្កៈរបស់ វេទនា

១. អនុភវនលក្ខណា មានការសោយអារម្មណ៍ ជាលក្ខណៈ ។

២. វិសយរសសម្ភោគរសា មានការបរិភោគរសអារម្មណ៍ ជាកិច្ច (មិនថារស ល្អ ឬក៏អាក្រក់ទេ គឺបរិភោគទាំងអស់)។

៣. សុខទុក្ខបច្ចុប្បដ្ឋានា មានសុខ និងទុក្ខ ជាអាការប្រាកដ ។

៤. ផស្សបទដ្ឋានា មានផស្សៈ ជាហេតុជិត។

## -លក្ខណាទិចតុក្កៈរបស់ សុខវេទនា

១. ឥដ្ឋផោដ្ឋព្វានុភវនលក្ខណា មានការសោយនូវផោដ្ឋព្វៈ

គួរជាទីប្រាថ្នា ជាលក្ខណៈ ។

២. សម្បយុត្តានំ ព្រូហនរសា មានការធ្វើឱ្យសម្បយុត្តធម៌

ចម្រើន ជាកិច្ច ។

(ធម៌ដែលសម្បយុត្តជាមួយគ្នា សុខទាំងអស់) ។

៣. កាយិកអស្សាទបច្ចុប្បដ្ឋានា មានការត្រេកអរផ្លូវកាយ ឬ

សេចក្ដីសប្បាយកាយ ជាអាការប្រាកដ ។

៤. កាយិន្ទ្រិយបទដ្ឋានា មានកាយបសាទ ជាហេតុជិត ។

## -លក្ខណាទិចតុក្កៈរបស់ ទុក្ខវេទនា

១. អនិដ្ឋផោដ្ឋព្វានុភវនលក្ខណា មានការសោយនូវផោដ្ឋព្វៈ

មិនគួរជាទីប្រាថ្នា (ដូចឈឺធ្មេញជាដើម) ជាលក្ខណៈ ។

២. សម្បយុត្តានំ មិលាបនរសា មានការធ្វើឱ្យសម្បយុត្តធម៌

ចុះខ្សោយឬសៅហ្មង ជាកិច្ច ។

(ធម៌ដែលសម្បយុត្តជាមួយគ្នា សៅហ្មងទាំងអស់) ។

៣. កាយិកាពាធបច្ចុប្បដ្ឋានា មានការអាពាធផ្លូវកាយ ឬ ការមិនសប្បាយកាយ ជាអាការប្រាកដ ។

៤. កាយិន្ទ្រិយបទដ្ឋានា មានកាយបសាទ ជាហេតុជិត ។

## -លក្ខណាទិចតុក្កៈរបស់ សោមនស្សវេទនា

១. ឥដ្ឋារម្មណានុភវនលក្ខណា មានការសោយនូវអារម្មណ៍ ជាទីប្រាថ្នា ជាទីគាប់ចិត្ត ជាលក្ខណៈ ។

២. ឥដ្ឋាការសម្ភោគរសា មានការប្រសព្វនឹងអារម្មណ៍ ដែលគួរជាទីប្រាថ្នា ជាកិច្ច ។

(គឺជួបនឹងអារម្មណ៍ល្អ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ល្អៗ) ។

៣. ចេតសិកអស្សាទបច្ចុប្បដ្ឋានា មានការត្រេកអរផ្លូវចិត្ត ជាអាការប្រាកដ (ញញឹម ឬ សើច )។

៤. បស្សទ្ធិបទដ្ឋានា មានការស្ងប់កាយ ជាហេតុជិត។

## -លក្ខណាទិចតុក្កៈរបស់ ទោមនស្សវេទនា

១. អនិដ្ឋារម្មណានុភវនលក្ខណា មានការសោយនូវអារម្មណ៍ មិនជាទីប្រាថ្នា មិនជាទីគាប់ចិត្ត ជាលក្ខណៈ ។

២. អនិដ្ឋាការសម្ភោគរសា មានការប្រសព្វនឹងអារម្មណ៍ ដែលមិនគួរជាទីប្រាថ្នា ជាកិច្ច ។

(គឺជួបនឹងអារម្មណ៍មិនល្អ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍មិនល្អៗ) ។

៣. ចេតសិកាពាធបច្ចុប្បដ្ឋានា មានការអាពាធផ្លូវចិត្ត ឬការមិនសប្បាយចិត្ត  ជាអាការប្រាកដ ។

៤. ឯកន្តេយេវហាទយវត្ថុបទដ្ឋានា មានហាទយវត្ថុតែម៉្យាង ជាហេតុជិត ។

ឧទាហរណ៍ ខឹងកើតឡើងវាញ័រទ្រូងតែម្តង ខឹងខ្លាំងញ័រខ្លាំង គឺនៅត្រង់បេះដូង....។

## -លក្ខណាទិចតុក្កៈរបស់ ឧបេក្ខាវេទនា

១. មជ្ឈត្តវេទយិតលក្ខណា មានការសោយនូវអារម្មណ៍ ជាកណ្ដាល ជាលក្ខណៈ ។

២. សម្បយុត្តានំ នាតិឧបព្រូហនមិលានរសា មានការរក្សាសម្បយុត្តធម៌ មិនឱ្យចម្រើន និងមិនឱ្យសាបសូន្យ ជាកិច្ច ។

៣. សន្តភាវបច្ចុប្បដ្ឋានា មានការស្ងប់ ជាអាការ ប្រាកដ ។

៤. និប្បីតិកចិត្តបទដ្ឋានា មានចិត្តដែលមិនប្រកបដោយបីតិ ជាហេតុជិត។

## -ព្រះសម្មាសម្ពុទ្ធសួរព្រះសារីបុត្ត ថាអ្នកជាកូនព្រាហ្មណ៍មហាសាល....?

## -យំកិញ្ចិ វេទយិតំ តំ ទុក្ខស្មឹ

« ការសោយនូវអារម្មណ៍ណា ការសោយអារម្មណ៍នោះជាទុក្ខ (ទាំងអស់) » ទាំងសុខវេទនា ទុក្ខវេទនា ឧបេក្ខាវេទនា សុទ្ធតែជាទុក្ខទាំងអស់ព្រោះថាប្រែប្រួល វាអត់តាំងនៅបាន។

-បុគ្គលគប្បីឃើញ វេទនាទាំង ៣ សុខវេទនាក្តី ទុក្ខវេទនាក្តី អទុក្ខមសុខវេទនាក្តី ថាមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខរបស់នោះ មិនមែនជាខ្លួន។

**-បុគ្គលគប្បីមានប្រាជ្ញាដ៏ប្រពៃឃើញ វេទនាតាមសេចក្តីពិត យ៉ាងនេះថា ៖**

-នុ៎ះមិនមែនអញ (មិនប្រកាន់ដោយមានះ)

-នុ៎ះមិនមែនជារបស់អញ (មិនប្រកាន់ដោយតណ្ហា)

-នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ (មិនប្រកាន់ដោយទិដ្ឋិ)

-ឯសេវន្តោ ទុក្ខស្ស នេះឯងជាទីបំផុតនៃសេចក្តីទុក្ខ៕

-វេទនា ធម្មជាតិណាវេងនូវអារម្មណ៍ ឬក៏សោយនូវអារម្មណ៍ ធម្មជាតិនោះ ហៅថា វេទនា ។

-នៅក្នុងអដ្ឋកថា លោកលើកឧទាហរណ៍ថា វេទនាហ្នឹងបានជាគេយកជាខន្ធមួយដែរ ពីព្រោះវាប្រាកដជាងចេតសិកដទៃផ្នែកខាងដឹងសុខ ទុក្ខ ។

-ក្នុងអត្ថសាលិនី ប្រៀបវេទនាហ្នឹងដូចជាព្រះរាជាសោយព្រះក្រយាហារ ចំណែកចិត្តនិងចេតសិកដទៃៗដែលកើតរួមជាមួយ ប្រៀបដូចជាអ្នកដាំស្លឱ្យព្រះរាជា មានសិទ្ធិត្រឹមតែភ្លក

ក្សអាហារនោះតិចតួច តាមសមគួរប៉ុណ្ណោះ មិនដូចព្រះរាជា មានសិទ្ធិបរិបូរណ៍ក្នុងការសោយទេ។

## ៣. សញ្ញាចេតសិក

ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅសញ្ញា តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណាចងចាំ ឬចំណាំនូវអារម្មណ៍ ធម្មជាតិនោះហៅថា សញ្ញា ។

## -ចុះចំណាំនូវអ្វី?

-ចំណាំនូវពណ៌ខៀវក៏មាន ចំណាំនូវពណ៌លឿងក៏មាន

-ចំណាំនូវពណ៌ក្រហមក៏មាន ចំណាំនូវពណ៌សក៏មាន ។

-សញ្ញានេះ ប្រៀបដូចថ្ងៃបណ្តើរកូន ។

- ចំណាំនូវរូបថា នេះជាឪពុក ជាម្តាយ ជាកូនជាដើម។

-ចំណាំ ឬក៏ការចងចាំនូវ សំឡេង ក្លិន រស....។

-ចំណុចពិសេសត្រង់ថា នៅពេលចំណាំអារម្មណ៍ឃើញការចង ចាំអារម្មណ៍ ហ្នឹងជាបុគ្គល ឬក៏ជាសញ្ញាខន្ធ?

ឧទាហរណ៍ ដូចជាម៉ូតូ ឡាន ទូរស័ព្ទ យើងចំណាំគ្រាន់តែចង ចាំ ឬយើងសម្គាល់ហើយជារបស់បុគ្គលមែន?

-សញ្ញាមានពិត ប៉ុន្តែបុគ្គលដែលមានសញ្ញាមិនមាន ។

-ការចងចាំមាន ប៉ុន្តែអ្នកដែលចងចាំមិនមាន ។

-ពេលខ្លះយើងប្រឹងចាំតែរឿងអត់ប្រយោជន៍នាំឱ្យកើតសេចក្តីទុក្ខ ។

## -លក្ខណាទិចតុក្កៈរបស់ សញ្ញា

១. សញ្ជាននលក្ខណា មានការចងចាំ (ឬសម្គាល់) ជាលក្ខណៈ។

២. បុនសញ្ជាននបច្ចយនិមិត្តករណរសា មានការស្គាល់ និងធ្វើនូវការសម្គាល់ទុក ជាកិច្ច (ដូចជាងឈើធ្វើនូវសញ្ញាសម្គាល់ត្រង់ដើមឈើជាដើម)។

៣. យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុប្បដ្ឋានា មានការអាស្រ័យនូវនិមិត្តតាមដែលបានកំណត់ទុក (ឬចាំបាន) ជាអាការប្រាកដ។

៤. យថាឧបដ្ឋិតវិសយបទដ្ឋានា មានអារម្មណ៍ដែលប្រាកដជាហេតុជិត (ដូចចំណាំរូបឡាន ចំណាំសំឡេងចាបជាដើម)។

## -សញ្ញាមាន ៣ គឺ ៖

១. សញ្ញាគូសលើថ្ម (រឿងអាក្រក់ខ្លាំង ល្អខ្លាំង)។

ឧទាហរណ៍ មនុស្សស្រឡាញ់ខ្លាំង និងមនុស្សស្អប់ខ្លាំង។

២. សញ្ញាគូសលើទឹក (រឿងធម្មតាៗ)។

## ៣. សញ្ញាគូសលើដី។

-រឿងអាក្រក់ៗហ្នឹងនិយាយពីចាំណាស់ ដូចគូសនៅលើថ្មអីចឹង ដូចជាគេជេរ ជាដើម តែរឿងល្អហ្នឹងអត់សូវចាំ...។

-សញ្ញា គឺការចងចាំ ដោយសារតែវាជាអនិច្ចំ (វាមិនទៀង) វាក៏ជាទុក្ខ ដូចជារឿងពិបាកចិត្តយើងអត់ចង់ចាំទេ តែភ្លេចអត់? អត់ភ្លេច ដល់រឿងរៀនធម៌ ស្ដាប់ធម៌ហើយហ្នឹងចង់ឱ្យតែចាំ តែអត់ចាំ អ្នកខ្លះចាំហើយភ្លេចវិញ ឃើញសញ្ញាហ្នឹងការចងចាំហ្នឹងមិនស្ដាប់បង្គាប់យើងទេ? អត់ទេ វាជាអនត្តា ។

-មនុស្សយើងបានជួបគ្នាម្ដងៗ មិនសូវចាំទេ តែបើយើងជួបញឹកៗញយៗ ស្គាល់យូរទៅគ្រាន់តែក្រឡេកឃើញដឹងថាអ្នកណាតែម្ដងដូចជាឪពុកម្ដាយ កូនជាដើម ឬក៏មនុស្សដែលយើងស្រឡាញ់ខ្លាំងហ្នឹង គឺមិនងាយភ្លេចទេ។

-បើយើងចាំខុស សម្គាល់ខុស (កូនអញ ទ្រព្យអញ លុយអញ ឡានអញជាដើម) នេះហៅថា សញ្ញាវិបល្លាស ។

-សញ្ញាវិបល្លាស »»» ទិដ្ឋិវិបល្លាស »»» ចិត្តវិបល្លាស ។

-ការប្រកាន់នៅក្នុងសញ្ញាខន្ធ (ការចងចាំ ឬក៏ការសម្គាល់) ប្រកាន់ថាលុយអញ ឡានអញ ប្ដីអញ ប្រពន្ធអញ ទូរស័ព្ទអញ អាវអញ ដីអញ ផ្ទះអញជាដើម សម្គាល់សញ្ញាហ្នឹងថាជាខ្លួន។

-នៅពេលដែលយើងចងចាំ ការកំណត់ មើលម៉ោងហូបបាយ ម៉ោងសម្រាក ម៉ោងក្រោក ការកំណត់ពេលទៅធ្វើការ ការកំណត់ ត្រូវលោតប្រឡាយ... ចងចាំ ឪពុកម្តាយចាំអ្វីៗទាំងអស់ តើយើងអ្នកចងចាំ ឬក៏សញ្ញាខន្ធកើតឡើងចងចាំ? ជាសញ្ញាខន្ធ ។

-សញ្ញា ដែលចងចាំខាងក្នុងហ្នឹង គឺចង្រៃតែម្តង ចាំខុស សម្គាល់ខុស ចាំថាលុយអញជាដើម ការចាំថាជាខ្លួន ចាំថា (រូបជាខ្លួន វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន) ។

យើងចាំថាខ្លួនយើងឈឺ តាមការពិតទុក្ខវេទនាកើតឡើងសោះ។

-សញ្ញា ក៏ជាមេនៃខន្ធ ៥ ហ្នឹងដែរ សញ្ញាហ្នឹងជាបបញ្ចសញ្ញា គឺសញ្ញាជាគ្រឿងនាំឱ្យយឺតយូរ ដល់អីចឹងទៅបានដឹងថាសញ្ញានេះជាមេចង្រៃមែនទែន។

-សញ្ញា គឺជាបច្ច័យពិសេស ជាបច្ច័យសំខាន់នៃវិញ្ញាណ វិញ្ញាណ ប្រសិនបើអត់មានការកំណត់សម្គាល់របស់សញ្ញាទេ គឺចប់តែម្តងគឺឡេឡឺ ធ្វើការអីមិនកើតទេ។

-អីចឹងបានព្រះសម្មាសម្ពុទ្ធសម្តែងថា ចិត្តសង្ខារ បានដល់ វេទនា និងសញ្ញា ចិត្តសង្ខារគឺជាសភាវៈ ដែលតាក់តែងចិត្ត ដល់វេទនា និងសញ្ញាហ្នឹងគឺសំខាន់ណាស់ក្នុងការតាក់តែង ចិត្តឱ្យសម្រេចក្នុងកិច្ចរបស់ខ្លួន ដោយបច្ច័យពីរហ្នឹង។

-និមិត្ត គឺគ្រឿងសម្គាល់ ឬគ្រឿងចំណាំជាដុំធំ (ការសម្គាល់ថា ជាបុរស ជាស្ត្រី រូបម៉ូត...)។

-អនុព្យញ្ជនៈ គឺសំដៅលើរូបរាង សណ្ឋាន អវយវៈតូច ធំ ទូទាំងកាយ (មុខអញ្ចេក មុខអញ្ចុះ...)។ ឧទាហរណ៍ យើងមើលដើមទ្រូងគេធំ... រួចវិនិច្ឆ័យនាំឱ្យកើតរាគៈ មើលទៅគេសាច់សខ្ចី មុខខ្យូត ទៅដល់មើលស្រមើលស្រមៃទៅនាំឱ្យកើតរាគៈ...។

-ជនពាលតែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន (ព្រោះមិនអាចនឹងការពារទុកបាន ចំណងបើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបានទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

(បិដកលេខ ៥២ ពាលវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះអានន្ទសេដ្ឋី)

-អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀតអ្នកណាជាមនុស្សពាល មានសេចក្តី ប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថា ជាមនុស្សពាលដោយពិត។

(បិដកលេខ ៥២ ពាលវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចោរអ្នកទម្លាយនូវបង្វិចទ្រព្យ)

## -ពាលមាន ៣ កម្រិត គឺ៖

១. ពាលោ បុគ្គលគ្រាន់តែល្ងង់ក៏ហៅថាពាលដែរ។

២. ពាលោខោ បុគ្គលល្ងង់ហើយធ្វើអាក្រក់ដោយចិត្ត ហៅថា ពាលមានពិស (ពាលថ្នាក់កណ្ដាល)។

៣. អតិពាលោខោ បុគ្គលល្ងង់ហើយ ធ្វើអំពើអាក្រក់ដោយ កាយ វាចា ចិត្តដ៏ខ្លាំងក្លា (ពាលនេះអាក្រក់ក្រៃលែង កែមិនបានទេ)។

## -អកុសលសញ្ញា ៣ យ៉ាង

១. កាមសញ្ញា បានដល់ការចងចាំ កិរិយាដែលចាំ សភាពដែលចាំ ទាក់ទងដោយកាមនេះហៅថា កាមសញ្ញា។

២. ព្យាបាទសញ្ញា បានដល់ការចងចាំ កិរិយាដែលចាំ សភាពដែលចាំទាក់ទងដោយការព្យាបាទនេះហៅថាព្យាបាទសញ្ញា។

៣. វិហិង្សាសញ្ញា បានដល់ការចងចាំ កិរិយាដែលចាំ សភាពដែលចាំ ទាក់ទងដោយការបៀតបៀននេះហៅថា វិហិង្សាសញ្ញា ។

-កាមសញ្ញា គឺការចងចាំថាអាត្មាអញមានលុយ ពាម៉ឺនដុល្លារ ខ្សែក ២ តម្លឹង មានដី ២ ហិចតា ចាំវត្ថុដែលយើងមាន ចាំថា

យើងមានកូន យើងមានចៅ មានឡានជាដើម។ ប៉ុន្តែយើង
ប្រឡំថាយើងអ្នកចាំ តាមពិតកាមសញ្ញាសោះ។

-តើកាមសញ្ញាជាអកុសល ឬក៏ជាកុសល? ជាអកុសល បើថា
ជាអកុសលអីចឹង ហើយម៉េចក៏យើងប្រឹងចាំម្ល៉េះ ប្រឹងចាំ
ណាស់ អ្នកសម្បូរទ្រព្យហ្នឹង ប្រឹងចាំណាស់ ចាំមិនអស់ប្រឹងធ្វើ
បញ្ជីអ្នកណាខ្ចីលុយខ្លះ អ្នកណាសងលុយខ្លះ អត់មានប្រឹងចាំ
នៅក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សោះ ចាំធម៌ល្អជាង នេះ
សុទ្ធតែជាកាមសញ្ញា មិនមែនជាយើងអ្នកចាំទេ។

ឧទាហរណ៍ អ្នកមានលុយក្នុងធនាគារហ្នឹងប្រឹងចាំណាស់ ប្រឹង
ចាំកុំឱ្យភ្លេច ប្រឹងចាំទាំងយប់ទាំងថ្ងៃ មើលមួយថ្ងៃមួយថ្ងៃហ្នឹង
យើងចម្រើនដោយអកុសលហ្នឹងសម្បើម ឬអត់? សម្បើម
ណាស់ មួយថ្ងៃៗហ្នឹង កូននឹងឱ្យ 50 ដុល្លារ 100 ដុល្លារ ដាក់ៗ
រាប់ៗខ្លាចភ្លេច ប្រឹងចាំណាស់ ។

-ព្យាបាទសញ្ញា ការចាំដោយការខឹងក្រោធ ។

ឧទាហរណ៍ ថាយើងចាំថា សម្លហ្នឹងយើងមិនចូលចិត្ត បុគ្គល
ហ្នឹងយើងមិនចូលចិត្ត គ្រាន់តែឃើញសម្លហ្នឹងមកដល់យើង
ម៉េច? យើងខឹងបាត់ គ្រាន់តែឃើញមុខបុគ្គលហ្នឹងមកម៉េច?

ខឹងបាត់ ។

-វិហិង្សាសញ្ញា គ្រាន់តែឃើញបុគ្គលដែលយើងស្អប់ កាយវាចា ចេញទៅបៀតបៀនគេបាត់...។

-គ្មាននរណាគេ អាចមិនឱ្យចាំបានទេ វាចាំតែអ៊ីចឹងឯងប៉ុន្តែកុលបុត្រត្រូវចខ្លួនត្រង់បានកំណត់ដឹងថា កាមសញ្ញាហ្នឹង មិនមែនជាខ្លួន ជាសភាវធម៌ រួចពីមិច្ឆាទិដ្ឋិ ដែលសម្គាល់ថាខ្លួនអ្នកចាំ ។

## ៤. ចេតនាចេតសិក

-ចេតនាចេតសិក ជាធម្មជាតិផ្គងចិត្ត គឺចាត់ចែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមជាមួយនឹងខ្លួន ឱ្យធ្វើកិច្ចរបស់ខ្លួន។

-ចេតនា ធម្មជាតិដែលឈ្មោះថា ចេតនា ព្រោះអត្ថថា តាំងចិត្ត គឺញុំាងសម្បយុត្តធម៌ ឱ្យព្រមព្រៀងជាមួយនឹងខ្លួនក្នុងអារម្មណ៍ ឬដែលឈ្មោះថា ចេតនា ព្រោះអត្ថថា ដល់នូវសេចក្ដីខ្វល់ខ្វាយក្នុងការតាក់តែងធម៌ដែលជាសង្ខតៈ។

-តួចេតនា គឺជាតួកម្ម (អំពើល្អ អាក្រក់) ព្រោះវាទៅរុញកគេ ទៅដាស់តឿនគេ ឱ្យមកធ្វើកម្មជាមួយវា ទៅដាស់គេ ឱ្យមកធ្វើការរៀងៗខ្លួន ដូចជា ផស្សៈឱ្យមកប៉ះខ្ទប់ វេទនាឱ្យមកសោយនូវអារម្មណ៍ សញ្ញាឱ្យមកចងចាំ លោភៈឱ្យមកជាប់ជំពាក់ ទិដ្ឋិឱ្យមកយល់ខុសជាដើម ឱ្យកើតឡើងជាមួយគ្នា ។

-រឿងបុណ្យ បាប គឺនៅលើចេតនានេះឯង ។

ឧទាហរណ៍ដូចជា លោភមូលចិត្ត ទោសមូលចិត្ត មោហមូលចិត្ត មហាកុសលចិត្ត ៨ ដួងជាដើម។

-ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះ ហៅថា សង្ខារ បានដល់ចេតនា ។

## -ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅ សង្ខារទាំងឡាយ តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះហៅថា សង្ខារ ។

## -សភាវៈទាំងឡាយ តាក់តែងនូវសង្ខតធម៌ តើដូចម្តេច?

-តាក់តែងនូវសង្ខតធម៌ គឺ រូប តាមសភាពវិនាស។

-តាក់តែងនូវសង្ខតធម៌ គឺ វេទនា តាមសភាពរងនូវអារម្មណ៍។

-តាក់តែងនូវសង្ខតធម៌ គឺ សញ្ញា តាមសភាពចំណាំនូវអារម្មណ៍។

-តាក់តែងនូវសង្ខតធម៌ គឺ សង្ខារទាំងឡាយ តាមសភាពតាក់តែង។

-តាក់តែងនូវសង្ខតធម៌ គឺ វិញ្ញាណ តាមសភាវៈដឹងច្បាស់។

-ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះ ហៅថា សង្ខារ ។

-តួចេតនា គឺជាតួកម្មបានដល់តួចេតនា ២៩ ។

-ចេតនា នេះហៅថា សង្ខារ ព្រោះអត្ថថា តាក់តែងនូវសង្ខតធម៌

-ចេតនា ហ្នឹង លោកពន្យល់ថា ដូចមេជាង ឬក៏ដូចកូនសិស្សជាប្រធានថ្នាក់ អឺចឹង ចាត់ចែងធ្វើកិច្ចការខ្លួនផង និងចាត់ចែងការងារឱ្យអ្នកដទៃផង។

ឧទាហរណ៍ ដូចជាមេចុងភៅ គាត់តាក់តែងយ៉ាងម៉េចឱ្យទៅជាសម្ល គាត់នឹងដាក់គ្រឿង ហើយចាត់ចែងអ្នកដទៃនឹងឱ្យធ្វើកិច្ចការតាមឯកទេសរៀងៗខ្លួន...។

ឧទាហរណ៍ ដូចជាអ្នកបើកឡានដឹកកម្មកររោងចក្រធ្វើការ អឺចឹង(គាត់ដើរប្រមូលគេ) ។

## -លក្ខណាទិចតុក្កៈរបស់ ចេតនា

១. ចេតនាភាវលក្ខណា មានការផ្គងចិត្ត ជាលក្ខណៈ

(គឺចេតនាល្អ ឬក៏អាក្រក់) ។

២. អាយូហនរសា មានការប្រមូលមក ជាកិច្ច ។

៣. សំវិធានបច្ចុប្បដ្ឋានា មានការចាត់ចែង ជាអាការប្រាកដ

(ដូចជាជាងធ្វើឈើធ្វើកិច្ចឱ្យសម្រេច) ។

៤. សេសខន្ធត្តយបទដ្ឋានា មានខន្ធ៣ ដែលនៅសល់ (វេទនា សញ្ញា វិញ្ញាណ) ជាហេតុជិត ។

-តើនៅពេលធ្វើទាន រក្សាសីល ចម្រើនភាវនា តើជាតួចេតនាឬ ក៏ជាបុគ្គលអ្នកធ្វើទាន អ្នករក្សាសីល អ្នកចម្រើនភាវនា? គឺជាតួ ចេតនានេះឯង គឺជា ធម៌ ។

## ៥. ឯកគ្គតាចេតសិក

-សម្មាសមាធិ អង្គធម៌បានដល់ ឯកគ្គតាចេតសិក ។

-ឯកគ្គតា ជាធម្មជាតិស្ងប់ (ក្នុងអារម្មណ៍តែមួយ) និងធ្វើឱ្យ សម្បយុត្តធម៌តាំងនៅក្នុងអារម្មណ៍តែមួយដូចគ្នា(ធ្វើឱ្យ សម្បយុត្តធម៌ទាំងអស់ ផ្តោតទៅលើអារម្មណ៍ណាមួយ ឬក៏ រឿងស្អីមួយ) ហើយអាចកើតឡើងបានទាំងផ្នែកកុសល និង អកុសលបានទាំងអស់។

-ឯកគ្គតា ព្រោះអត្ថថា មានអារម្មណ៍តែមួយ ព្រោះមិនមាន សេចក្តីរវើរវាយទៅក្នុងអារម្មណ៍ផ្សេងៗ ភាវៈនៃចិត្តមាន អារម្មណ៍តែមួយនោះឈ្មោះថា ឯកគ្គតា ។

-បើកើតនៅក្នុងអកុសលជា មិច្ឆាសមាធិ បើកើតនៅក្នុង កុសលជា សម្មាសមាធិ ។

ឧទាហរណ៍ សូម្បីតែចោរលួចគេហ្នឹងក៏មានសមាធិដែរ...។

ឧទាហរណ៍ ដូចជាគេជេរយើង ដោយសារតែយើងផ្តោតស្តាប់គេហ្នឹងទើបយើងដឹងថាគេជេរបាន ។

## -លក្ខណាទិចតុក្កៈរបស់ ឯកគ្គតា

១. អវិក្ខេបលក្ខណា មានការមិនរវើរវាយ ជាលក្ខណៈ ។

២ . សហជាតានំ សម្បិណ្ឌនរសា មានការប្រមូលសហជាតធម៌មក ជាកិច្ច (ប្រមូលមកឱ្យស្ងប់ជាមួយវា) ។

៣. ឧបសមបច្ចុប្បដ្ឋានា មានការចូលទៅស្ងប់ ជាអាការប្រាកដ ។

៤. សុខបទដ្ឋានា មានសុខវេទនា ជាហេតុជិត ។

## ៦. ជីវិតិន្ទ្រិយចេតសិក

-ជីវិតិន្ទ្រិយចេតសិក ជាធម៌រក្សាសម្បយុត្តធម៌គឺ ធ្វើឱ្យសម្បយុត្តធម៌ តាំងនៅ (មានន័យថា វាមិនឱ្យវិនាស ឬក៏ធម៌ដែលកើតរួមជាមួយនឹងអាចរស់បានទាំងអស់) និងប្រព្រឹត្តទៅ (ធម៌ដទៃចេះតែដំណើរការបានបន្តៗទៅទៀត) ។ ធម៌ដែលឈ្មោះថា ឥន្ទ្រិយ ព្រោះភាពជាធំក្នុងការរក្សាធម៌ដែលកើតរួមគ្នា ។

-ជីវិតិន្ទ្រិយំ ឈ្មោះថា ជីវិត ព្រោះអត្ថថាជាគ្រឿងតាំងនៅនៃសម្បយុត្តធម៌។ ជីវិតនោះឯង ជាធំក្នុងការរក្សាសហជាតធម៌គួរដល់សេចក្តីជាធំ ព្រោះដូច្នេះទើបឈ្មោះថា ជីវិតិន្ទ្រិយ។

# -លក្ខណាទិចតុក្កៈរបស់ ជីវិតិន្ទ្រិយ

១. សហជាតានំ អនុបាលនលក្ខណំ មានការតាមរក្សាសហ ជាតធម៌ជាលក្ខណៈ (ប្រៀបដូចទឹក រក្សាផ្កាឈូកជាដើម) ។

២. តេសំ បវត្តនរសា មានការញុំាងសម្បយុត្តធម៌ឱ្យប្រព្រឹត្តទៅ ជាកិច្ច (ដំណើរការ) ។

៣. តេសញ្ញេវ ឋបនបច្ចុប្បដ្ឋានំ មានការតាំងនៅនៃសហជាត ធម៌ជាអាការប្រាកដ ។

(ធម៌ដែលកើតរួមជាមួយនឹងអាចរស់បានទាំងអស់) ។

៤. សេសខន្ធត្តយបទដ្ឋានំ មានខន្ធ ៣ ដែលនៅសល់ (វេទនា សញ្ញា វិញ្ញាណ) ជាហេតុជិត ។

-អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះទៅក្នុងកាល ណាហើយ កាយនេះក៏ដល់នូវសេចក្តីមិនគួរនឹងទុកដាក់ឱ្យនៅលើ ផ្ទះសម្បែងបានឡើយ គេតែងនាំយកទៅចោលឱ្យដេកនៅលើផែន ដី ឬដុតកម្ទេចចោលក្នុងកាលនោះឯង ដូចជាអង្កត់ឧស រក ប្រយោជន៍គ្មានឡើយ ។

-ធម៌ ៣ យ៉ាង អាយុ ភ្លើងធាតុ និងវិញ្ញាណ កាលណាធម៌ ៣ យ៉ាងនេះអត់ទាន់រលត់ យើងហៅថាមនុស្សរស់ ប៉ុន្តែបើយើងពោលដោយបរមត្ថ តើមនុស្សរស់ ឬក៏ធម៌នឹងមិនទាន់រលត់? អាយុជាមនុស្សទេ? ភ្លើងធាតុមានលក្ខណៈក្តៅជាមនុស្សទេ? តើវិញ្ញាណជាមនុស្សទេ?

## -អាយុចែកចេញជា ២ យ៉ាង ៖

១. ជីវិតិន្ទ្រិយរូប គឺចិញ្ចឹមរូប ដែលកើតរួមជាមួយវា។

២. ជីវិតិន្ទ្រិយនាម គឺចិញ្ចឹមនាម ដែលកើតរួមជាមួយវា។

-ជីវិតិន្ទ្រិយនាម ហ្នឹងវាកើតបន្តគ្នា យើងឱ្យឈ្មោះថាអាយុ ប៉ុន្តែដល់ពេលជីវិតិន្ទ្រិយនាមនឹងដាច់ តើអាយុត្រូវអស់ ឬក៏មិនអស់? អស់

-កាលដែលរស់នៅបាននឹង តើសត្វអ្នករស់នៅ ឬក៏នៅមានជីវិតិន្ទ្រិយ? គឺនៅមានជីវិតិន្ទ្រិយ ។

-ភ្លើងធាតុ ធាតុក្តៅ (តេជោធាតុ) ត្រូវរលត់ ។

-វិញ្ញាណ គឺចិត្តរលត់ទៅហើយ វិញ្ញាណធាតុ ក៏ត្រូវរលត់ ។

# ៧. មនសិការចេតសិក

-មនសិការចេតសិក ជាធម្មជាតិនាំសម្បយុត្តធម៌ទៅកាន់អារម្មណ៍ ។

-តួពូកែគិត ពូកែច្នៃ ឆ្លាតនេះហៅថា មនសិការៈ មិនមែនជាបញ្ញាទេ ។

-មនសិការៈ បានដល់ ការធ្វើទុកក្នុងចិត្ត ។

ឧទាហរណ៍ នៅពេលខ្ញុំបាននិយាយជាមួយគាត់ និងបបួលគាត់ឱ្យធ្វើទាន រក្សាសីល រៀនធម៌ ស្តាប់ធម៌ និយាយធម៌នឹងជាមួយគ្នានេះហៅថា មនសិការៈ ។

-ចាំមើលខ្ញុំបានជួបគាត់ខ្ញុំនឹងសាកសួរឱ្យដឹងរឿងម្តងនេះហៅថា មនសិការៈ ។

-នៅពេលខ្ញុំបានជួបគាត់ខ្ញុំនឹងស្តីឱ្យគាត់ ជេរគាត់ឱ្យណាណីម្តងនេះហៅថា មនសិការៈ ។

-នៅពេលខ្ញុំបានជួបគាត់ខ្ញុំនឹងបបួលគាត់ស៊ីផឹកឱ្យណាណីម្តងនេះហៅថា មនសិការៈ ។

# -មនសិការចែកចេញជា ២ គឺ ៖

១. យោនិសោមនសិការ គឺការធ្វើទុកក្នុងចិត្តត្រូវ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ការធ្វើទុកក្នុងចិត្តត្រូវទំនង។

២. អយោនិសោមនសិការ គឺការធ្វើទុកក្នុងចិត្តខុស ការធ្វើទុកក្នុងចិត្តដោយមិនឧបាយនៃប្រាជ្ញា ការធ្វើទុកក្នុងចិត្តខុសទំនង ។

# -ការធ្វើទុកក្នុងចិត្តត្រូវ តើដូចម្ដេច?

១. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល មិនទៀងថាមិនទៀង ។

២. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល ជាទុក្ខថាជាទុក្ខ ។

៣. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល មិនមែនជាខ្លួន ថា មិនមែនជាខ្លួន (ជាអនត្តា) ។

៤. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល មិនស្អាតថាមិនស្អាត ។

-នេះ ហៅថា យោនិសោមនសិការ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។

-ការធ្វើទុកក្នុងចិត្តត្រូវ បានសុខ ។

-ការធ្វើទុកក្នុងចិត្តខុស កើតទុក្ខ ។

# -ការធ្វើទុកក្នុងចិត្តខុស តើដូចម្ដេច?

១. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល មិនទៀងថាទៀង។

២. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល ជាទុក្ខថាជាសុខ។

៣. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល មិនមែនជាខ្លួន ថាជាខ្លួន (ជាអត្តា)។

៤. ធ្វើទុកក្នុងចិត្តនូវរបស់ណាដែល មិនស្អាតថាស្អាត។

-នេះ ហៅថា អយោនិសោមនសិការ ការធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញា។

-យោនិសោមនសិការ « អ្នកសិក្សាគប្បីមានចិត្តកើតឡើងយ៉ាងនេះថា អ្នកដទៃសិក្សាក្ដី មិនសិក្សាក្ដី អាត្មាអញនឹងសិក្សាក្នុងធម្មវិន័យរបស់ព្រះតថាគតដោយពិត »។

-សេចក្ដីឧបមា យោនិសោមនសិការនឹងដូចជាអរុណពណ៌មាស នៃព្រះអាទិត្យ តាមធម្មតាព្រះអាទិត្យមុននឹងរះឡើងវាជះរស្មីពណ៌មាសមកមុនហើយសម្គាល់ថាបន្តិចទៀត ព្រះអាទិត្យនឹងរះឡើង យ៉ាងណាមិញបុគ្គលណាដែលមាន យោនិសោមនសិការនេះ គឺជានិមិត្តនៃព្រះនិព្វាន ថាបន្តិចទៀតកុលបុត្រនោះបានសម្រេចនូវ ព្រះនិព្វាន ហើយដោយអំណាចនៃ យោនិសោមនសិការ ។

## -លក្ខណាទិចតុក្កៈរបស់ មនសិការៈ

១. សារណលក្ខណោ មានការធ្វើឱ្យសម្បយុត្តធម៌ត្រាច់ទៅជាលក្ខណៈ។

២. សម្បយុត្តានំ អារម្មណេ សំយោជនរសោ មានការញ៉ាំងសម្បយុត្តធម៌ឱ្យប្រកបក្នុងអារម្មណ៍ ជាកិច្ច។

៣. អារម្មណាភិមុខីភាវបច្ចុប្បដ្ឋានោ មានការធ្វើឱ្យសម្បយុត្តធម៌ តម្រង់មុខឆ្ពោះទៅទល់នឹងអារម្មណ៍ ជាអាការប្រាកដ (ដូចនាយសារថីនាំសេះឱ្យទៅកាន់ទិសដែលត្រូវការ)។

៤. អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត។

-អារម្មណ៍មាន ៦ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍)។

## -ចេតនា និង មនសិការចេតសិក

-ចេតសិកទាំង២នេះ មានសភាពស្រដៀងគ្នា ប៉ុន្តែមិនដូចគ្នាទេ។ ចេតនា មានតួនាទីតាក់តែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួន ឱ្យធ្វើកិច្ចរបស់ខ្លួន។ ចំណែកមនសិការចេតសិក មានតួនាទីប្រាថ្នានាំសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួនឱ្យប្រព្រឹត្តទៅ។

## -មនសិការៈ និងបញ្ញាមានលក្ខណៈដូចគ្នា ឬក៏ខុសគ្នា?

-ព្រះនាគសេន និងស្ដេចក្រុងមិលិន្ទ ៖

-មហាបពិត្រ មនសិការៈ និងបញ្ញា ធម៌ពីរនេះគឺផ្សេងគ្នា

មនសិការៈ (យោនិសោមនសិការ) គឺប្រៀបដូចជាដៃដែលចាប់កួរស្រូវដែលកណ្ដៀវត្រកងយកមកល្អហើយ រួចដៃចាប់ឱ្យជាប់ដើម្បីកាត់ នៅត្រង់ដៃក្រសោបចាប់ដើមស្រូវឱ្យជាប់ ដូចជាយោនិសោមនសិការៈ។ ហើយត្រង់មុខកណ្ដៀវដែលកាត់ផ្ដាច់ ដូចជា បញ្ញា។ ធម៌ទាំងពីរនេះផ្សេងគ្នា ប៉ុន្តែធម៌ទាំងពីរនេះមានឧបការៈដល់គ្នានឹងគ្នា។

-សតិ ដូចគ្នានឹងមនសិការៈ ដោយអាការប្រាកដ គឺសតិ ទល់នឹងអារម្មណ៍ដោយអំណាចការមិនភ្លេច (រឭក) រីឯមនសិការៈ ទល់នឹងអារម្មណ៍ដោយការធ្វើទុក ការចងទុក ការប្រកប។

-សតិ ដូចជាដៃទៅចាប់កួរស្រូវ (ចាប់បានមិនរបូតទេ) ។

-រីឯបញ្ញា ដូចជាមុខកណ្ដៀវដែលកាត់ផ្ដាច់។

## -អាហាររបស់អវិជ្ជា  អាហាររបស់វិជ្ជានិង វិមុត្តិ

-ការសេពគប់អសប្បុរស → មិនបានស្ដាប់ព្រះសទ្ធម្ម

→ មិនមានសទ្ធា → មានអយោនិសោមនសិការ

→ មិនមានសតិ សម្បជញ្ញៈ → មិនមានការសង្រួមឥន្ទ្រិយ

→ មានទុច្ចរិត ៣ → នីវរណធម៌ ៥ → មានអវិជ្ជា

-ការសេពគប់សប្បុរស → បានស្ដាប់ព្រះសទ្ធម្ម

→ មានសទ្ធា → មានយោនិសោមនសិការ

→ មានសតិ សម្បជញ្ញៈ → មានការសង្រួមឥន្ទ្រិយ

→ មានសុចរិត ៣ → សតិប្បដ្ឋាន ៤

→ មានពោជ្ឈង្គ ៧ → មានវិជ្ជា និងវិមុត្តិ

(បិដកលេខ ៥០ អង្គុត្តរនិកាយ ទសកនិបាត យមកវគ្គទី ២ ទំព័រ ២៤៦~ ២៥៣)

-ចេតសិកទាំង ៧ នេះ ប្រកបជាមួយនឹងចិត្តគ្រប់ដួង ព្រោះសភាពរបស់ចិត្តនោះ កើតឡើងដើម្បីដឹងអារម្មណ៍ ការដែលនឹងដឹងអារម្មណ៍បានព្រោះ ៖

១. ផស្សៈ ធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍ ។

២. វេទនា ការសោយអារម្មណ៍ ។

៣. សញ្ញា ធ្វើកិច្ចចាំអារម្មណ៍ ។

៤. ចេតនា ធ្វើកិច្ចខ្វល់ខ្វាយឱ្យសម្រេច ឬដាស់តឿន ។

៥. ឯកគ្គតា ធ្វើសម្បយុត្តធម៌ដែលកើតព្រមគ្នាឱ្យតាំងនៅក្នុងអារម្មណ៍តែមួយ ។

៦. ជីវិតិន្ទ្រិយ ជាធម៌រក្សាសម្បយុត្តធម៌ឱ្យប្រព្រឹត្តទៅ ។

៧. មនសិការៈ ការនាំសម្បយុត្តធម៌ទៅកាន់អារម្មណ៍ ។

-បើចេតសិកទាំង ៧ នេះ មិនកើតទេ ចិត្តក៏មិនអាចកើតឡើងបានដែរ ដូច្នេះ ចេតសិកទាំង ៧ នេះទើបមានឈ្មោះថា សព្វចិត្តសាធារណចេតសិក ។

**ចប់សព្វចិត្តសាធារណចេតសិក ៧**

# -បកិណ្ណកចេតសិក ៦

-បកិណ្ណក ប្រែថា រាត់រាយ មិនច្បាស់ ។

## ១. វិតក្កចេតសិក

-សម្មាសង្កប្ប: អង្គធម៌ បានដល់ វិតក្កចេតសិក ។

-វិតក្កោ ធម៌ណារមែងត្រិះរិះ (នឹក) ដល់អារម្មណ៍គឺ លើកសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ព្រោះហេតុនោះ ធម៌នោះឈ្មោះថា វិតក្ក: ។

### -អ្នកដែលចម្រើនឈាន ចូលឈានមានអង្គ ៥ គឺ ៖

១. វិតក្ក: ការត្រិះរិះ(នឹកគិត) ដល់អារម្មណ៍ ។

ឧទាហរណ៍ ដូចជាអ្នកនាំផ្លូវយើងទៅលេងផ្ទះមិត្តភក្តិ...។

ឧទាហរណ៍ ដូចជាអ្នកនាំផ្លូវចូលរាជវាំង...។

២. វិចារ: ការពិចារណាក្នុងអារម្មណ៍ ។

៣. បីតិ សេចក្តីត្រេកអរ រីករាយ ឆ្អែតកាយ ឆ្អែតចិត្ត ។

៤. សុខ: សេចក្តីសុខ (ផ្លូវកាយ ផ្លូវចិត្ត) ។

៥. ឯកគ្គតា គឺជាធម្មជាតិស្ងប់ ។

-ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា « ម្នាលកាម តថាគតរកអ្នកឯងឃើញហើយ តាមពិតអ្នកឯងនឹងកើតតែពីការត្រិះរិះ »។

## -លក្ខណាទិចតុក្កៈរបស់ វិតក្កៈ

១. អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ ។

២. អាហននបរិយាហននរសោ មានការធ្វើចិត្តឱ្យប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច ។

៣. អានយបច្ចុប្បដ្ឋានោ មានការនាំចិត្តទៅក្នុងអារម្មណ៍ជាអាការប្រាកដ ។

៤. អាបាថវិសយបទដ្ឋានោ មានអារម្មណ៍ក្នុងវិថី ជាហេតុជិត ។

## -ការត្រិះរិះខុសមាន ៣ ឬក៏អកុសលវិតក្កៈមាន ៣ គឺ៖

១. កាមវិតក្កៈ បានដល់សេចក្ដីត្រិះរិះ ការត្រិះរិះខុស ដែលទាក់ទងដោយកាម នេះ ហៅថា កាមវិតក្កៈ ។

២. ព្យាបាទវិតក្កៈ បានដល់សេចក្ដីត្រិះរិះ ការត្រិះរិះខុស ដែលទាក់ទងដោយការព្យាបាទ នេះ ហៅថា ព្យាបាទវិតក្កៈ ។

៣. វិហិង្សាវិតក្កៈ បានដល់សេចក្តីត្រិះរិះ ការត្រិះរិះខុស ដែលទាក់ទងដោយការបៀតបៀន នេះ ហៅថា វិហិង្សាវិតក្កៈ ។

## -កាមចែកចេញជា ២ គឺ ៖

១. វត្ថុកាម បានដល់ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ)។

២. កិលេសកាម បានដល់ លោភចេតសិក (សេចក្តីប្រាថ្នា សេចក្តីពេញចិត្ត សេចក្តីត្រេកអរ នៅក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ)។

-តើយើងរាល់ថ្ងៃនៅកណ្តាលវត្ថុកាម និងកិលេសដែរ ឬអត់?

នៅពេញតែម្តង ។

-បើពោលដោយបញ្ញត្តិ មានទ្រព្យសម្បត្តិ ដី ភរិយា ស្វាមី កូន នេះហៅថា វត្ថុកាម ដល់ពេលយើងមានសេចក្តីត្រេកអរ ពេញចិត្ត ដោយអំណាចលោភៈ ទៅនឹងទ្រព្យសម្បត្តិ ដី ឡាន កូន ភរិយា ស្វាមី សំឡេង... នេះហៅថា កិលេសកាម ។

-កាលណាយើងជាប់ជំពាក់ពេញចិត្ត ត្រេកអរ ក្នុងវត្ថុកាម និងកិលេសកាមនឹងនោះគឺ ជាភ័យធំ។

ឧទាហរណ៍ ថាយើងស្រឡាញ់កូន ស្រឡាញ់ចៅ ប្តី ប្រពន្ធ ស្រលាញ់ទ្រព្យសម្បត្តិនឹងយើងត្រៀមតែសោយសោក ត្រៀមតែកើតទុក្ខ ត្រៀមតែយំឱ្យហើយទៅ ថ្ងៃណាមួយភ័យនឹងមក

ដល់យើងហើយ យើងនឹងអង្គុយសម្រក់ទឹកភ្នែក យ៉ាងពិតប្រាកដ និងសោយសោកយ៉ាងពិតប្រាកដ កាលណាលោភៈនឹងមានហើយ មិនយូរ មិនឆាប់ទេ កាលណារបស់ទាំងអស់នោះប្រែប្រួល ។

**-កាមវិតក្កៈ** គឺសេចក្តីត្រិះរិះក្នុងកាមារម្មណ៍ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍)។

-តើយើងរាល់ថ្ងៃមានទេ? មាន អាចលះបង់បានដោយនេក្ខម្ម។

ឧទាហរណ៍ ថាត្រិះរិះចង់បានទូរស័ព្ទ ចង់បានម៉ូតូ ចង់បានឡាន អង្គុយសុខៗត្រិះរិះចង់បានប្រពន្ធ ចង់បានកូនជាដើម។

ឧទាហរណ៍ ថាត្រិះរិះទៅកាន់ស្រ្តីណាម្នាក់ ការត្រិះរិះថា ភ្នែកគេអញ្ចេះ មុខគេអញ្ចុះ បបូរមាត់ ច្រមុះ ធ្មេញ ថ្ពាល់ សាច់គេស ...រួចក៏ស្រឡាញ់គេទៅ ដល់ស្រឡាញ់គេហើយ តាំងដេកលែងលក់ ។

ឧទាហរណ៍ ភិក្ខុនីមួយអង្គ នាងជាព្រះអរហន្តី បុរសម្នាក់ចង់ចាប់ភិក្ខុនី ព្រោះនាងនឹងស្អាត មាណព ស្រឡាញ់នាងនឹងខ្លាំងណាស់ ហើយសារភាពថា ភ្នែកនាង ដូចភ្នែកកូនគោ ព្រះថេរី នាងដឹងថាបុរសនេះ ត្រូវកាមច្ឆន្ទៈ គ្របសង្កត់ហើយ ព្រះថេរីក៏សួរ តើភ្នែកនេះល្អមែនឬ? ល្អមែន តើអ្នកចង់បានឬ? ចង់បាន ក៏លូកដៃទាំងពីរនឹងខ្វេះភ្នែកចេញមកឱ្យ ហូរឈាម បុរស

នោះក៏លុតជង្គង់ថ្វាយបង្គំ សូមខមាលទោស ភិក្ខុនីខ្វេះភ្នែកចេញ ដើម្បីជួយមាណពហ្នឹង...។

-នេះមកពីការត្រិះរិះ ដោយ និមិត្ត និង អនុព្យញ្ជនៈ។

-តើកន្លែងណាដែលយើងស្រឡាញ់ពិត?

-ស្រឡាញ់ធ្មេញ ស្រឡាញ់ភ្នែក ស្រឡាញ់ដៃ ស្រឡាញ់ត្រចៀក... សាកគេឱ្យដៃយើង យក ឬអត់? អត់ គេដកធ្មេញឱ្យ ២ យើងយក ឬអត់? អត់ ។

ឧទាហរណ៍ មាននារីម្នាក់ ស្អាតនោះស្អាតទាស់តែមាត់ឆែប តែនាងពាក់ម៉ាស សំឡេងក៏ពីរោះ រាងក៏ស្អាត តែពេលនាងដោះម៉ាសចេញទៅឃើញមាត់ឆែបអ៊ីចឹង សួរថាតើយើងស្រឡាញ់នាង ឬអត់? អត់

ឧទាហរណ៍ ដូចជាភិក្ខុមួយអង្គ ជាប់ជំពាក់នឹងចីវរ ដល់ពេលសុគតទៅកើតជាចៃ...។

ឧទាហរណ៍ ថាបើអ្នកចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក ត្រី ហើយបើអ្នកចងការលុយឱ្យគេទៀតមួយថ្ងៃៗ គិតពីរឿងហ្នឹងឯងថារាល់ថ្ងៃហ្នឹង តើគាត់ចម្រើនតែអកុសល ឬក៏ចម្រើនកុសល?

**-ព្យាបាទវិតក្កៈ** ការត្រិះរិះព្យាបាទ គុំកួនអ្នកដទៃ (គិតចង់ឱ្យគេវិនាសតែម្តង) ។

-តើយើងរាល់ថ្ងៃមានទេ? មាន អាចលះបង់បានដោយមេត្តា ។

ឧទាហរណ៍ យីអានេះធ្វើអាក្រក់ណាស់ថ្ងៃណាងាប់ ។

-គិតចង់សម្លាប់គេ គិតចង់ទៅដុតផ្ទះគេ គិតចង់ឱ្យគេស្លាប់។

-ព្យាបាទ នៅក្នុងកម្មបថ មានអង្គ ២ ទី១ គឺមានអ្នកដទៃ ទី២ គឺគិតឱ្យគេវិនាស (ទោះបីជាគេវិនាស ឬក៏មិនវិនាសក៏ដោយ ក៏ឈ្មោះដាច់កម្មបថដែរ) ។

ឧទាហរណ៍ យើងខឹងនឹងស្រមោច ឬមូស បើបាបនេះឱ្យផលក៏អាចធ្លាក់នរកបានដែរ។ ពេលយើងខឹងនឹងស្រមោចជាចិត្ត

-ទោសៈ គិតចុះគិតឡើងចង់ឱ្យស្រមោចងាប់ឱ្យអស់ទៅ កុំឱ្យវាមករោមបាយ វាមានគំនិតចង់ឱ្យគេវិនាស នៅពេលហ្នឹងដាច់កម្មបថ ព្យាបាទ ដាច់បាត់ ធ្លាក់នរកបាន។

-តើរាល់ថ្ងៃនេះហេតុដែលទៅនរក មានច្រើន ឬទេ? មានច្រើនណាស់។

-វិហិង្សាវិតក្កៈ គឺការត្រិះរិះក្នុងការបៀតបៀន (ចង់ធ្វើឱ្យគេពិបាកចិត្ត) ។

-ការបៀតបៀន ដោយកាយ ដោយវាចា ដោយចិត្ត អាចលះបង់បានដោយ ករុណា ។

ឧទាហរណ៍ នៅពេលចិត្តយើង ងរសម្បូរទេ? អ្នកមានសង្សារ មានប្ដីប្រពន្ធ អីហ្នឹង រឹតតែសម្បូរ ។

ឧទាហរណ៍ ដូចជាឃើញគេធ្វើខុស (ក្នុងហ្វេសប៊ុក) យើងខឹងដង ផ្ដែផ្ដា បញ្ឆិតបញ្ឆៀងឱ្យគេ ចំអកឱ្យគេ បង្អាប់ឱ្យគេ ព្រោះមាន បំណងធ្វើឱ្យគេពិបាកចិត្ត។

-អើទៅខ្ញុំមិនចេះផ្អែមដូចឯង ទៅខ្ញុំវាខុស ឯងវាត្រូវ ។

ឧទាហរណ៍ ដូចយើងធ្វើការអ្វីមួយចឹងដល់ខឹងអ្នកណាម្នាក់ ទៅធ្វើការហ្នឹងបោកប្រាស់ ក្តូងក្តាំងពេញនឹង បំណងចង់ធ្វើឱ្យ គេម្នាក់ហ្នឹងពិបាកចិត្ត តើសម្បូរទេ?

ឧទាហរណ៍ ម៉ែឪពេលខ្លះខឹងកូន ងរ លែងហូបបាយ...។

ឧទាហរណ៍ ពេលខ្លះប្រើកូនឱ្យទិញថ្នាំ ឱ្យកោសខ្យល់ឱ្យ

ដល់កូនរវល់តិចតាំងធ្វើឯង ងរ។

ឧទាហរណ៍ ចៅកែយើងលម្អៀង ឱ្យប្រាក់ខែយើងអត់ស្មើគ្នា ដល់យើងត្រិះរិះទៅ រាងអន់ចិត្តជាមួយគាត់។

-គេជេរយើងតែម្ដងទេ តែដល់យើងត្រិះរិះទៅខឹងរហូត។

-នៅពេលទៅទារលុយគេមិនបាន ដល់មកផ្ទះ យកមកត្រិះរិះ ទៅខឹង ជំពាក់លុយគេមិនងាយសង។

ឧទាហរណ៍ ថាគេនិយាយ ឬគេសរសេរផុស រួចយើងត្រិះរិះ យកមកគិត តិចគេនិយាយដៀមដាមអញទៅ គេសរសេរឌឺដង អញទៅ ត្រិះរិះហើយក៏ខឹង រួចក៏អន់ចិត្ត។

-រឿងយើងគិតត្រិះរិះ អាក្រក់ពីគេដោយចិត្ត ដល់ទៅជាកម្មនឹង គេគិតអាក្រក់មកលើយើងវិញ វាអត់ចេញតាមកាយ វាចាទេ គ្រាន់តែគិតក៏ជាកម្មមួយដែរ។

## -ការត្រិះរិះត្រូវមាន ៣ សម្មាសង្កប្បៈ

**១. នេក្ខម្មវិតក្កៈ** គឺសេចក្តីត្រិះរិះចេញចាកពីកាមារម្មណ៍ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍) ឬការត្រិះរិះដើម្បី សេចក្តីសុខស្ងប់ចេញចាកកាម។

-ការត្រិះរិះ ទៅកាន់អារម្មណ៍ ចេញចាកកាម លះនូវតណ្ហា។

-ការត្រិះរិះ ទៅកាន់អារម្មណ៍នៃនាម រូប លះនូវទិដ្ឋិ។

-ការត្រិះរិះ ទៅកាន់អារម្មណ៍នៃព្រះនិព្វាន លះជាសមុច្ឆេទ។

**-នេក្ខម្មវិតក្កៈ គឺការត្រិះរិះចេញចាកពីកាម រួមមាន៖**

-ការត្រិះរិះ ក្នុងការធ្វើទាន សីល ភាវនា (សតិប្បដ្ឋាន៤) ។

## -ការត្រិះរិះ នៅក្នុងអនុស្សតិ ១០ គឺ ៖

១. ការត្រិះរិះ ក្នុងគុណព្រះពុទ្ធ។

២. ការត្រិះរិះ ក្នុងគុណព្រះធម៌។

៣. ការត្រិះរិះ ក្នុងគុណព្រះសង្ឃ។

៤. ការត្រិះរិះ ក្នុងសីល។

៥. ការត្រិះរិះ ក្នុងចាគៈ។

៦. ការត្រិះរិះ ក្នុងសេចក្ដីស្លាប់។

៧. ការត្រិះរិះ ក្នុងគុណដែលនាំឱ្យកើតជាទេវតា។

៨. ការត្រិះរិះ ក្នុងគុណនៃព្រះនិព្វានដែលស្ងប់កិលេស។

៩. ការត្រិះរិះ ដល់កាយដែលមិនស្អាត។

១០. ការត្រិះរិះ ដល់ខ្យល់ដង្ហើមចេញចូល។

**២. អព្យាបាទវិតក្កៈ** ការត្រិះរិះមិនព្យាបាទ មិនគុំគួនអ្នកដទៃ (ត្រិះរិះធ្វើយ៉ាងម៉េចឱ្យអ្នកដទៃបានសេចក្ដីសុខ ប្រកបដោយចិត្តមេត្តា ករុណា)។

**ឧទាហរណ៍** ត្រិះរិះធ្វើយ៉ាងម៉េច រកវិធីម៉េចដើម្បីជួយពន្យល់ធម៌អ្នកដទៃឱ្យឆាប់យល់ឆាប់ចេះ ។

៣. អវិហិង្សាវិតក្កៈ គឺ ការត្រិះរិះមិនបៀតបៀនអ្នកដទៃ ប្រកបដោយចិត្តមេត្តា ករុណា ។

-ការត្រិះរិះ ក្នុងការបបួលគេរៀនធម៌ ស្តាប់ធម៌ ធ្វើទាន សីល ភាវនាជាដើម (សតិប្បដ្ឋាន៤) ។

## ២. វិចារចេតសិក

-វិចារៈ គឺចិត្តរមែងត្រាច់ទៅក្នុងអារម្មណ៍ ឬការពិចារណានៅក្នុងអារម្មណ៍ដោយធម៌ណា ព្រោះហេតុនោះឈ្មោះថា វិចារៈ។

## -លក្ខណាទិចតុក្កៈរបស់ វិចារៈ

១. អារម្មណានុមជ្ជនលក្ខណោ មានការពិចារណាក្នុងអារម្មណ៍ ជាលក្ខណៈ។

២. តត្ថ សហជាតានុយោជនរសោ មានការតាមប្រកប សហជាតធម៌ទុកក្នុងអារម្មណ៍ ជាកិច្ច។

៣. ចិត្តានុបពន្ធបច្ចុប្បដ្ឋានោ មានការចងចិត្តទុកក្នុងអារម្មណ៍ ជាអាការប្រាកដ។

៤. អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត។

## ៣. អធិមោក្ខចេតសិក

-អធិមោក្ខោ ការបង្អោនចិត្តទៅ (ឬជឿយ៉ាងស៊ប់) ឈ្មោះថា អធិមោក្ខៈ។ អធិមោក្ខៈ អាចកើតបានទាំងផ្នែកកុសលក៏បាន ផ្នែកអកុសលក៏បាន។

-ដូចសាធកៈ (ក្នុងគម្ពីរអដ្ឋកថា ពោលថា អធិមោក្ខមានលក្ខណៈចុះស៊ប់ក្នុងអារម្មណ៍ ដូចសសរខឿន ព្រោះរឹងមាំក្នុងអារម្មណ៍ (ក៏ទៅណាទៅនុងហើយ)។

ឧទាហរណ៍ ដូចអ្នកណាជឿជំនឿផ្តេសផ្តាស គឺជឿផ្កាប់មុខតែម្តង ដូចគេហៅថាអ្នកគាំទ្រផ្កាប់មុខ ។

ឧទាហរណ៍ ផ្នែកខាងល្អ ដល់ពេលយើងយល់ធម៌ យើងឈប់ជឿជំនឿផ្តេសផ្តាស ឈប់សម្លាប់សត្វ ឈប់ផឹកស្រាជាដើម យើងក៏ជឿយ៉ាងស៊ប់ ដាច់ខាតដែរ មិនផឹកស្រា មិនសម្លាប់សត្វ ទោះបីជាត្រូវស្លាប់ក៏គាត់មិនធ្វើដែរ។

ឧទាហរណ៍ ម្តាយខ្ញុំថាឱ្យខ្ញុំច្បាស់មែសអាច្បាស់ ។

## -លក្ខណាទិចតុក្កៈរបស់ អធិមោក្ខៈ

១. សន្និដ្ឋានលក្ខណោ មានការដាក់ចិត្តស៊ប់ ឬសម្រេច (សន្និដ្ឋាន) ជាលក្ខណៈ។

២. អសំសប្បនរសោ មានការមិនសង្ស័យ (ឬមិនឃ្លេងឃ្លោង) ជាកិច្ច។

៣. វិនិច្ឆយបច្ចុប្បដ្ឋានោ មានការចុះចិត្តស៊ប់ (ឬកាត់សេចក្តី) ជាអាការប្រាកដ។

៤. សន្និដ្ឋេយ្យធម្មបទដ្ឋានោ មានធម៌ដែលគប្បីសម្រេច (សន្និដ្ឋាន) ជាហេតុជិត។

*-អធិមោក្ខៈនេះជាបដិបក្ខនឹង វិចិកិច្ឆា ។*

## ៤. វីរិយចេតសិក

-សម្មាវាយាម អង្គធម៌ បានដល់ វីរិយចេតសិក ។

-*ភាវៈ* ឬការងាររបស់អ្នកអង់អាច ឈ្មោះថា វីរិយៈ ។

-មួយទៀត ធម្មជាតិណាដែលបុគ្គលគប្បីឱ្យមានដំណើរការទៅ គប្បីឱ្យប្រព្រឹត្តទៅដោយវិធី ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វីរិយៈ បានដល់សេចក្តីព្យាយាម។

-ព្រះអគ្គសាវ័ក របស់ព្រះសុខី បានប្រកាសសម្ដែងព្រះធម៌នៅព្រហ្មលោក ហើយឮរហូតដល់ផែនដី « អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម ក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់បង់នូវសេនានៃមច្ចុ ដូចជាដំរីញាំញីនៅផ្ទះបបុស អ្នកណាមិនប្រហែសធ្វេស ក្នុងធម្មវិន័យនេះ អ្នកនោះនឹងលះបង់នូវជាតិសង្សារ ធ្វើនៅទីបំផុតនៃសេចក្ដីទុក្ខបាន »។ អ្នកទាំងឡាយចូរព្យាយាមរូតរះឡើង កុំឱ្យមារដឹងថា អ្នកទាំងឡាយជាបុគ្គលមាននូវសេចក្ដីប្រមាទ ហើយនាំចូលមកកាន់អំណាចរបស់ខ្លួន រួចមារធ្វើតាមសេចក្ដីប្រាថ្នា ។

-មានតែពេលនេះទេ ដែលយើងមានឱកាសក្នុងសេចក្ដីព្យាយាមនៅក្នុងព្រះពុទ្ធសាសនា យើងមិនអាចធូរថយបានទេ ព្រោះពេលវេលាមានមិនច្រើនឡើយ ខិតទៅរកសេចក្ដីស្លាប់កាន់តែជិតណាស់ហើយ។ ដូច្នេះហើយយើងចូរជាអ្នកមាននូវសេចក្ដីព្យាយាមនៅក្នុងព្រះពុទ្ធសាសនា មានការស្ដាប់ធម៌ រៀនធម៌ ធ្វើទាន រក្សាសីល ចម្រើនភាវនា (មានសតិប្បដ្ឋាន៤) ជាដើម។ ក្នុងកាលឥឡូវនេះ យើងបានកើតជាមនុស្ស គួរដល់ការព្យាយាមក្នុងព្រះពុទ្ធសាសនា ក្នុងធម្មវិន័យ បើមិនបានធ្វើព្រះសទ្ធម្មឱ្យប្រាកដទេ យើងនឹងស្ដាយក្រោយជាក់មិនខានឡើយ។ កាលយើងកើតជាគោ ជាសេះ ជាមាន់ ជាក្របី ឆ្កែ ឆ្មា យើងមិនបានធ្វើសេចក្ដីព្យាយាមទេ ព្យាយាមអូសតែរទេះ...។

## -លក្ខណាទិចតុក្កៈរបស់ វិរិយៈ

១. ឧស្សាហលក្ខណំ មានការឧស្សាហ៍ ជាលក្ខណៈ ។

២. សហជាតានំ ឧបត្ថម្ភនរសំ មានការឧបត្ថម្ភដល់សហជាតធម៌ ជាកិច្ច។

៣. អសំសីទនភាវបច្ចុប្បដ្ឋានំ មិនមានការរាថយជាអាការប្រាកដ។

៤. សំវេគវត្ថុបទដ្ឋានំ មានសំវេគវត្ថុ ជាហេតុជិត។

## -សំវេគវត្ថុ ៨

-ហេតុជាទីតាំងនៃសេចក្តីសង្វេគហៅថា សំវេគវត្ថុ មាន ៨ គឺ៖

១. ការពិចារណាដល់ជាតិទុក្ខ ១

២. ការពិចារណាដល់ជរាទុក្ខ ១

៣. ការពិចារណាដល់ព្យាធិទុក្ខ ១

៤. ការពិចារណាដល់មរណទុក្ខ ១

៥. ការពិចារណាដល់អបាយិកទុក្ខ ១ (ទុក្ខក្នុងអបាយភូមិ)

៦. ការពិចារណាដល់អតីតវដ្តមូលកទុក្ខ ១ (កាលកើតជាគោ គេចាក់កបង្ហូរឈាម ឈាមនោះច្រើនជាងមហាសមុទ្រទាំង ៤)

៧. ការពិចារណាដល់អនាគតវដ្តមូលកទុក្ខ ១

៨. ការពិចារណាដល់ទុក្ខ ក្នុងការស្វែងរកអាហារក្នុងបច្ចុប្បន្ន ១

# -សម្មាវាយាម សម្មប្បធាន៤

១. សំវរប្បធាន ព្យាយាមសង្រួម ការពារមិនឱ្យអកុសលដែលមិនទាន់កើត មិនឱ្យកើតឡើង។

ឧទាហរណ៍ ដូចជា បាប អកុសលដែលមិនទាន់កើតឡើង (អកុសលចិត្ត ១២ ដួង មានលោភមូលចិត្តជាដើម អកុសលកម្មបថ ១០) មិនឱ្យទាន់កើតឡើងបាន។

២. បហានប្បធាន ព្យាយាមលះអកុសលដែលកើតឡើងហើយ មិនឱ្យកើតឡើងទៀត។

៣. ភាវនាបធាន ព្យាយាមញ៉ាំងកុសលដែលមិនទាន់កើតឡើង ឱ្យកើតឡើង។

ឧទាហរណ៍ ដូចជាកុសលថ្នាក់ទាន សីល ភាវនា ចម្រើនសតិប្បដ្ឋាន៤ជាដើម។ ព្យាយាម ចម្រើនសតិ បញ្ញា។

៤. អនុរក្ខនាបធាន ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឱ្យសាបសូន្យទៅវិញ។

ឧទាហរណ៍ កុសលថ្នាក់ទាន ថ្នាក់សីល ភាវនាជាដើម មិនឱ្យវាបាត់ទៅវិញ។ មិនឱ្យដាច់សីល ដាច់កម្មបថ និងមិនឱ្យសតិបញ្ញារលត់ទៅវិញ។

-ភាពនៃទឹកភ្នែកច្រើនជាងមហាសមុទ្រទាំង ៤ ដូច្នេះហើយ យើងគប្បីសង្វេគ មានសេចក្តីព្យាយាមធ្វើទាន រក្សាសីល ស្តាប់ធម៌ និងចម្រើនភាវនា។

-ធម្មសង្វេគ (បិដកលេខ ៣២ សំយុត្តនិកាយ និទានវគ្គ តិណកដ្ឋវគ្គ ទំព័រ៨១~៩៥

## ៥. បីតិចេតសិក

-បីតិ សេចក្តីត្រេកអរ រីករាយ ស្រស់ស្រាយ ឆ្អែតកាយ ឆ្អែតចិត្ត

បីតិ ធម្មជាតិដែលឈ្មោះថា បីតិ ព្រោះអត្ថថា ញ៉ាំងកាយ និងចិត្តឱ្យឆ្អែត ឱ្យរីករាយ ឬញុំាកាយ និងចិត្តឱ្យចម្រើន ដូចជាផ្កាបទុមរីកល្អហើយ។

## -លក្ខណាទិចតុក្កៈរបស់ បីតិ

១. សម្បិយាយនលក្ខណា មានការស្រស់ស្រាយ សប្បាយពេញចិត្ត ជាលក្ខណៈ។

២. កាយចិត្តសម្បីណនរសា មានការធ្វើឱ្យកាយ និងចិត្តឆ្អែត ជាកិច្ច។

៣. ឱទគ្យបច្ចុប្បដ្ឋានា មានការត្រេកអរ រីករាយ ជាអាការប្រាកដ។

៩. សេសខន្ធត្តយបទដ្ឋានា មានខន្ធ៣ ដែលនៅសល់ (វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ) ជាហេតុជិត។

## -បីតិ ៥ យ៉ាង ៖

១. ខុទ្ទកាបីតិ  សេចក្តីត្រេកអរតិច ត្រឹមព្រឺរោម ព្រឺស្បែក ដែលកើតឡើងម្តងម្កាល។

២. ខណិកាបីតិ សេចក្តីត្រេកអរមួយខណៈៗ ប្រាកដដូចជាផ្លេកបន្ទោរ (តាំងនៅមិនយូរ)។

៣. ឱក្កន្តិកាបីតិ សេចក្តីត្រេកអរមួយស្របក់ មានអាការប្រាកដដូចជាទឹករលកបោកខ្ទប់ច្រាំងហើយក៏បែកទៅ។

៤. ឧព្វេង្គាបីតិ សេចក្តីត្រេកអរខ្លាំង អាចញ៉ាំងកាយឱ្យអណ្តែតឡើង។

៥. ផរណាបីតិ សេចក្តីត្រេកអរធ្វើឱ្យផ្សព្វផ្សាយជ្រួតជ្រាបទូទៅក្នុងកាយដូចសំឡីជប់ទឹក។

ឧទាហរណ៍ ព្រះអានន្ទ  អ្នកស្តាប់ធម៌ទាំង ៥ នាក់...។

ឧទាហរណ៍ ដូចជារឿង ព្រះបាទសង្ខៈ សម័យព្រះពុទ្ធសិរីមត្តៈពុទ្ធៈ ...។

-ដូចដែលបានដឹងថា ព្រះមហាតិស្សត្ថេរ អ្នកគង់នៅក្នុងបុណ្ណវល្លិកវិហារ បានទៅកាន់លានព្រះចេតិយ វេលាល្ងាច លុះពេលព្រលប់បានឃើញពន្លឺព្រះចន្ទក្នុងថ្ងៃពេញបរមី ទើបបែរមុខទៅមហាចេតិយហើយរំពឹងគិតថា ក្នុងវេលាស្មើនេះ ពួកបរិស័ទទាំង ៤ កំពុងក្រាបថ្វាយបង្គំព្រមគ្នាហើយ ឧព្វេង្គាបីតិ ដែលមានព្រះពុទ្ធរូបជាអារម្មណ៍ឱ្យកើតឡើង ដោយសារអារម្មណ៍ដែលបានឃើញតាមប្រក្រតី ហើយបានអណ្តែតខ្លួនឡើងទៅឰដ៏អាកាស បានឈរនៅទីព្រះលានមហាចេតិយនោះឯង។

-រឿងមួយទៀត សូម្បីកុលធីតាម្នាក់ នៅក្នុងភូមិវត្តកាលកៈដែលជាទីគោចររបស់អ្នកទៅកាន់គិរិកណ្ឌកវិហារ

បានអណ្តែតខ្លួនទៅឰដ៏អាកាស ដោយឧព្វេង្គាបីតិ ដោយមានគុណព្រះពុទ្ធដ៏មានកម្លាំងជាអារម្មណ៍ ដូចបានឮមកថាមាតាបិតារបស់កុលធីតានោះ ត្រូវបានធ្វើដំណើរទៅព្រះវិហារ ដើម្បីនឹងបានស្តាប់ធម៌ក្នុងពេលព្រលប់ បានប្រាប់ថា ម្នាលកូនស្រីកូនមានគភ៌ចាស់ហើយ មិនអាចនឹងដើរទៅក្នុងពេលដែលមិនសមគួរនោះទេ ម៉ែនិងពុកឯង ទៅស្តាប់ធម៌ ពេលត្រឡប់មកវិញនឹងចែកបុណ្យដល់កូន។

-នាងកុលធីតាសូម្បីតែចង់ទៅយ៉ាងណាក៏ដោយ ក៏ពុំអាច ជំទាស់នឹងពាក្យរបស់មាតាបិតាបាន ទើបរង់ចាំនៅឯផ្ទះ បាន ទៅឈរនៅមាត់ទ្វារផ្ទះ បានក្រឡេកមើលព្រះចេតិយ ដែល នៅលើភ្នំគិរិកណ្ណកវិហារដោយពន្លឺព្រះចន្ទ បានឃើញការបូជា ដួងប្រទីបនៅព្រះចេតិយ និងបានឃើញបរិស័ទ ៤ ពួក ធ្វើការ បូជាព្រះចេតិយដោយវត្ថុទាំងឡាយ មានផ្កានិងគ្រឿងក្រអូប ជាដើម ហើយធ្វើការប្រទក្សិណ ថែមទាំងបានស្តាប់សំឡេង ស្វាធ្យាយព្រះធម៌ជាគណៈរបស់ព្រះសង្ឃ។

-លំដាប់នោះនាងបានគិតយ៉ាងនេះថា ឱ! អ្នកទាំងនោះមាន បុណ្យបាននាំគ្នាទៅកាន់គិរិកណ្ណកវិហារ បានប្រទក្សិណទី លានព្រះចេតិយ និងបានស្តាប់ធម្មកថាដំពីរោះយ៉ាងនេះ

ខណៈកំពុងសម្លឹងមើលព្រះចេតិយដូចកែវមុក្តានោះឯង

ឧព្វេង្គាបីតិក៏កើតឡើង នាងបានអណ្តែតទៅឰដ៍អាកាស ហើយចុះមកទីលានព្រះចេតិយ មុនមាតាបិតារបស់នាងដែល បានទៅដល់ហើយបានថ្វាយបង្គំព្រះចេតិយ ឈរស្តាប់ព្រះធម៌ ទីនោះ។

ពេលនោះមាតាបិតារបស់នាងក៏បានមកដល់ ហើយសួរកូននាងថា នែកូនស្រី កូនមកតាមផ្លូវណា? នាងក៏ឆ្លើយតបវិញថា បពិត្រមាតាកូនបានមកតាមផ្លូវអាកាស មិនបានមកតាមផ្លូវថ្មើរជើងទេ មាតាបិតារបស់នាងបានពោលថា នែកូនធម្មតាព្រះខីណាស្រពទាំងឡាយ ទើបធ្វើដំណើរតាមផ្លូវអាកាសបាន ម្តេចក៏កូនពោលយ៉ាងនេះ នាងតបថា កាលបើខ្ញុំឈរសម្លឹងព្រះចេតិយព្រមដោយពន្លឺព្រះចន្ទ បីតិមានកម្លាំងដោយប្រារព្ធព្រះពុទ្ធគុណជាអារម្មណ៍ក៏កើតឡើងក្នុងខណៈនោះ ខ្ញុំពុំបានជ្រាបថា ខ្លួនខ្ញុំឈរ ឬអង្គុយ ហើយក៏បានអណ្តែតទៅឰដ៏អាកាស ដោយកាន់យកនូវនិមិត្តនោះឯង ហើយបានឈរនៅទីលាន ព្រះចេតិយនោះឯង ឧព្វេង្គាបីតិ ធ្វើឱ្យអណ្តែតទៅឰដ៏អាកាសយ៉ាងនោះឯង។

## ៦. ឆន្ទចេតសិក

-ឆន្ទោ សេចក្តីពេញចិត្ត ឈ្មោះថា ឆន្ទៈ។

-ឆន្ទៈនេះ គឺសេចក្តីប្រាថ្នាដើម្បីនឹងធ្វើអ្វីមួយ (ប្រាថ្នាក្នុងការធ្វើកុសលក៏មាន អកុសលក៏មាន) ។

ឧទាហរណ៍ ខ្ញុំបាទមានឆន្ទៈ មានសេចក្តីប្រាថ្នា ដើម្បីចង់និយាយធម៌ ចង់ពន្យល់ធម៌ ចង់បង្រៀនធម៌...។

# -លក្ខណាទិចតុក្កៈរបស់ ឆន្ទៈ

១. កត្តុកម្យតាលក្ខណោ មានការប្រាថ្នាដើម្បីធ្វើ ជាលក្ខណៈ។

-ចង់ស្តាប់ធម៌ ចង់និយាយធម៌ ចង់ពន្យល់ធម៌ ចង់បង្រៀនធម៌។

២. អារម្មណបរិយេសនរសោ មានការស្វែងរកអារម្មណ៍ ជាកិច្ច

៣. អារម្មណេន អត្ថិកតាបច្ចុប្បដ្ឋានោ មានសេចក្តីប្រាថ្នាត្រូវការអារម្មណ៍ ជាអាការប្រាកដ ។

៤. អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត ។

# -ឆន្ទៈមាន ២ ប្រភេទ គឺ ៖

១. តណ្ហាឆន្ទ សេចក្តីប្រាថ្នា គឺចំណង់។

២. កត្តុកម្យតាឆន្ទ គឺសេចក្តីត្រូវការដើម្បីធ្វើ (ជាតម្រូវការ) ។

-ពាក្យខ្មែរយើងពាក្យថាប្រាថ្នាហ្នឹងគឺប្រែថាសុំ យើងអាចច្រឡំគ្នា ជាមួយ លោភៈ អត្ថថា ចង់បាន ប្រាថ្នាចង់បានអ្វីមួយ ចង់ទៅឋានសួគ៌ជាដើម។ នៅក្នុងន័យថាសេចក្តីប្រាថ្នាដើម្បីនិយាយ សេចក្តីប្រាថ្នាដើម្បីគិត សេចក្តីប្រាថ្នាដើម្បីឃើញ សេចក្តីប្រាថ្នាដើម្បីស្តាប់ជាដើម។

-តាមធម្មតាកាលបើ ឆន្ទៈមានកម្លាំងច្រើន រមែងមានកម្លាំងច្រើនជាងតណ្ហា ការពិតឆន្ទៈជា អធិបតី(ធម៌ដែលជាធំ) និងឥទ្ធិបាទធម៌ (ទីតាំងនៃការសម្រេច) តែបើនៅពេលណាឆន្ទៈនឹងមានកម្លាំងស្មើនឹងតណ្ហា ពួកសត្វត្រូវធ្លាក់ក្នុងអំណាចតណ្ហា បើត្រូវតណ្ហាគ្របសង្កត់ហើយ ក៏មិនអាចលះបង់ទ្រព្យសម្បត្តិ សេចក្តីសុខក្នុងរាជ្យសម្បត្តិ ឬសម្បត្តិក្នុងទេវលោកនិងព្រហ្មលោកដើម្បីចេញចាកវដ្តៈបានឡើយ ។

## -ឥទ្ធិបាទធម៌ ៤ (ធម៌ដែលនាំឱ្យសម្រេចជោគជ័យ

១. ឆន្ទៈ សេចក្តីពេញចិត្ត សេចក្តីប្រាថ្នាដើម្បីនឹងធ្វើអ្វីមួយ ឬការដាក់គោលដៅធ្វើអ្វីមួយ។ ឱ្យតែមានបំណង ប្រាកដជាមានផ្លូវ ។

២. វិរិយៈ គឺសេចក្តីព្យាយាម ។

៣. ចិត្តៈ ការយកចិត្តទុកដាក់ក្នុងកិច្ចការ ឬផ្ចិតផ្ចង់ ផ្ទៀងផ្ទាត់ ការផ្តោតចិត្តទៅលើការរពូក ការមានស្មារតី (តួសតិចេតសិក) សតិ នៅក្នុងសតិប្បដ្ឋាន ៤ នេះឯង ។

ឧទាហរណ៍ ថាកាយ វាចា ចិត្ត ចិត្តគំនិតគិតចេញទៅត្រូវផ្ទៀងផ្ទាត់ ថាការគិតនោះត្រូវ ឬខុស? គិតល្អ ឬគិតអាក្រក់? កាយធ្វើ

ចេញទៅត្រូវផ្ទៀងផ្ទាត់ ការធ្វើនោះត្រូវ ឬខុស? វាចានិយាយស្តី ចេញទៅត្រូវផ្ទៀងផ្ទាត់ ថានិយាយនោះត្រូវ ឬខុស?

-បើយើងបានផ្ទៀងផ្ទាត់រាល់ កាយ វាចា ចិត្ត ដែលចេញទៅ យើងដឹងច្បាស់ថាអ្វីគួរចម្រើន (កុសល) អ្វីគួរលះបង់ (អកុសល)។

៤. វីមំសា សេចក្តីឧស្សាហ៍ត្រិះរិះពិចារណា រកហេតុផលក្នុងកិច្ចការ។ ឬថាមានចំណេះដឹង ឈ្លាស ឆ្លាត ជំនាញ ចេះវិភាគ ចេះត្រិះរិះ ពិចារណា (រឿង ហេតុ ផល)។

-វីមំសា អង្គធម៌ បានដល់ បញ្ញាចេតសិក។ បុគ្គលនោះឈ្លាស

ក្នុងការសិក្សាធម៌ ស្តាប់ធម៌ ដឹងធម៌ណាសិក្សាទៅសមគួរដល់ ការបដិបត្តិធម៌ (សតិ បញ្ញាដឹងបាន) សមគួរដល់ បដិវេធ ។

-បកិណ្ណកចេតសិកទាំង ៦ នេះ ជាសង្ខារក្ខន្ធទាំងអស់ មិនចាំបាច់ចែកដោយន័យផ្សេងៗទេ ព្រោះប្រកបជាមួយនឹងចិត្តយ៉ាងណា ចេតសិកទាំង ៦ នេះក៏ជាយ៉ាងនោះ។

# ចប់ អញ្ញសមានាចេតសិក

## -អធិប្បាយ អកុសលចេតសិក ១៤

-អកុសលចេតសិកទាំង ១៤ នេះ ជាចេតសិកផ្នែកអាក្រក់ ជាបាប កាលបើប្រកបជាមួយនឹងចិត្ត រមែងធ្វើឱ្យចិត្តសៅហ្មង។ អកុសលចេតសិកទាំង ១៤ នេះ កើតតែនៅក្នុងចិត្តជាអកុសលចិត្ត ១២ ដួង ប៉ុណ្ណោះ។

## -អកុសលចេតសិកទាំង ១៤ មាន ៥ ន័យ

១. មោចតុក្កៈ បានដល់ ចេតសិក ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ។

២. លោតិកៈ បានដល់ ចេតសិក ៣ គឺ លោភៈ ទិដ្ឋិ មានៈ។

៣. ទោចតុក្កៈ បានដល់ ចេតសិក ៤ គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ។

៤. ថីទុកៈ បានដល់ ចេតសិក ២ គឺ ថីនៈ មិទ្ធៈ។

៥. ឯកវិចិកិច្ឆា បានដល់ ចេតសិក ១ គឺ វិចិកិច្ឆា។

-មោចតុក្កៈ ចេតសិក ៤ តែងប្រកបជាមួយអកុសលចិត្ត ១២ ដួង ដូច្នេះទើបមានឈ្មោះថា សព្វាកុសលសាធារណចេតសិក (ចេតសិកកើតទូទៅគ្រប់អកុសលចិត្ត) ។

# ១. មោហចេតសិក

-មោហោ អញ្ញាណំ ធម៌ដែលមានឈ្មោះថា មោហៈ ព្រោះអត្ថថា វង្វេងក្នុងអារម្មណ៍ បានដល់ អញ្ញាណ។

-មោហោ សភាវៈធ្វើឱ្យពពួកសត្វវង្វេង។

## -ម្នាលភិក្ខុទាំងឡាយ មោហៈ តើដូចម្តេច?

ការមិនដឹងច្បាស់ក្នុងទុក្ខ ការមិនដឹងច្បាស់ក្នុងហេតុដែលនាំឱ្យកើតទុក្ខ ការមិនដឹងច្បាស់ក្នុងទីរម្លត់ទុក្ខ ការមិនដឹងច្បាស់ក្នុងបដិបទាជាដំណើរទៅកាន់ទីរម្លត់ទុក្ខ។

-អវិជ្ជា បានដល់ សេចក្តីល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងជ្រប់ ការភ្លេចភ្លាំង ជំនន់ គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា(គ្រឿងត្រាំ) ការស្កាត់ដំណើរគឺអវិជ្ជា គន្លឹះ គឺអវិជ្ជា ការវង្វេងជាអកុសលមូលណាដែលមានសភាពបែប នេះ ហៅថា មោហៈ ។

-ព្រះពុទ្ធដីកា « អវិជ្ជាធាតុគឺជាធាតុធំ កាលណាដែលអវិជ្ជាជាធាតុធំនេះ គ្របសង្កត់ហើយ ងងឹតឈឹង មិនឃើញទិសដែលមិនមានភ័យ ហើយមិនឃើញផ្លូវ ទៅកាន់ទិសដែលមិនមានភ័យ »។

# -លក្ខណាទិចតុក្កៈរបស់ មោហៈ

១. អញ្ញាណលក្ខណោ មានការមិនដឹង (សភាវធម៌) តាមសេចក្តីពិត ជាលក្ខណៈ ។

-គឺមិនដឹងធម៌តាមសេចក្តីពិត មិនដឹងក្នុងធម៌ ៨ យ៉ាង ។

គឺមិនដឹងធម៌តាមសេចក្តីពិត ជាពិសេសរឿងហេតុ ផល សុខទុក្ខក្នុងជីវិតនេះឯង គឺអត់ដឹង។

ឧទាហរណ៍ ទៅជំជឿផ្តេសផ្តាស... យើងអត់ដឹងហេតុដែលនាំឱ្យកើតបញ្ហា ហេតុដែលនាំឱ្យអាយុវែង...។

២. អារម្មណសភាវច្ឆាទនរសោ មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច។ បិទបាំងយ៉ាងម៉េច?

-មានការបិទបាំងសភាវៈនៃអារម្មណ៍ មិនឱ្យឃើញអារម្មណ៍ទាំង ៦ តាមសេចក្តីពិត (មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍)។ អាយតនៈខាងក្នុង៦ (មានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត )។ អាយតនៈ ១២ នេះ មិនទៀង ជាទុក្ខ ឃើញថាទៀង ឃើញថាជាសុខទៅវិញវង្វេងពេញនឹង។

ឧទាហរណ៍ ដូចនៅពេលឃើញរូប អ៊ីចឹងតាមការពិតឃើញវណ្ណៈ(ពណ៌) ប៉ុន្តែយើងឃើញជាបុរស ជាស្ត្រីជាដើម រួចក៏កើតនូវសេចក្តីស្រឡាញ់ ពេញចិត្ត ជាប់ជំពាក់ មានការខឹង ស្អប់។

៣ អន្ទការបច្ចុប្បដ្ឋានោ មានភាពងងឹត(ល្ងង់)ជាអាការប្រាកដ។

៤. អយោនិសោមនសិការបទដ្ឋានោ មានអយោនិសោមន

សិការៈ ជាហេតុជិត។

*-មោហៈ គឺអវិជ្ជា បានដល់ការមិនដឹងតាមសេចក្តីពិត។*

**-ក្នុងទីនេះលោកសម្តែងដល់សេចក្តីមិនដឹងក្នុងធម៌ ៨ យ៉ាងគឺ៖**

១. ទុក្ខេ អញ្ញាណំ សេចក្តីមិនដឹងក្នុងទុក្ខសច្ចៈ។

២. ទុក្ខសមុទយេ អញ្ញាណំ សេចក្តីមិនដឹងក្នុងទុក្ខសមុទយសច្ចៈ។

៣. ទុក្ខនិរោធេ អញ្ញាណំ សេចក្តីមិនដឹងក្នុងទុក្ខនិរោធសច្ចៈ។

៤. ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ សេចក្តីមិនដឹងក្នុងមគ្គសច្ចៈ។

៥. បុព្វន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ជាអតីត។

៦. អបរន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ជាអនាគត។

៧. បុព្វន្តាបរន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ

ដែលជាអតីត និងអនាគត។

៨. ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ សេចក្តីមិនដឹងក្នុងបដិច្ចសមុប្បាទធម៌ គឺមិនដឹងក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នា

ទើបកើតឡើង (ធម៌កើតពីបច្ច័យ)។

-កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈជាដើម ឆេះទ្រលោងជានិច្ច ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹត គឺ អវិជ្ជា រួបរឹតហើយ (ម្ដេចឡើយ) ក៏មិនស្វែងរកប្រទីប គឺ ប្រាជ្ញា។

(បិដកលេខ ៥២ ជរាវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះពួកស្ត្រី ៥០០ នាក់ជាសម្លាញ់របស់នាងវិសាខា)

# -ការកំណត់នូវអវិជ្ជា

## -អវិជ្ជា មានវិជ្ជាជាគ្រឿងប្រៀបធៀប

-វិជ្ជា ដឹងនៅក្នុងសច្ចធម៌ ៤ មានទុក្ខសច្ចៈ ជាដើម។

-អវិជ្ជា មិនដឹងនៅក្នុងសច្ចធម៌ ៤ មានទុក្ខសច្ចៈជាដើម។

-វិជ្ជា ដឹងថាមិនទៀង ជាទុក្ខ ជាអនត្តា។

-អវិជ្ជា ដឹងថាទៀង ជាសុខ ជាអត្តា។

-វិជ្ជា ដឹងថា នុ៎ះមិនមែនអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។

-អវិជ្ជា ដឹងថា នុ៎ះជាអញ នុ៎ះជារបស់អញ នុ៎ះជាខ្លួនរបស់អញ។

## ២. អហិរិកចេតសិក

-អហិរិក: ព្រោះអត្ថថា មិនខ្មាសបាប មិនខ្ពើមបាប មិនរង្កៀសចំពោះបាប(បាបខ្លួនឯង)។ អហិរិក: មិនខ្មាសចំពោះ កាយទុច្ចរិតជាដើម។

-អហិរិក: គឺជាបដិបក្ខនឹង ហិរិ (សេចក្តីខ្មាស ស្អប់ ខ្ពើមបាប)។

## -លក្ខណាទិចតុក្កៈរបស់ អហិរិកៈ

១. កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ អលជ្ជនលក្ខណំ វា មានការមិនខ្ពើម ឬមិនខ្មាសនូវទុច្ចរិត មានកាយទុច្ចរិតជាដើមជាលក្ខណៈ។

២. បាបានំ ករណរសំ មានការធ្វើបាប (គឺអកុសលកម្មបថ១០) ជាកិច្ច ។

៣. អសង្កោចនបច្ចុប្បដ្ឋានំ មានការមិនថយចាកបាប ជាអាការប្រាកដ (គឺត្រូវធ្វើតែម្តង ត្រូវតែសម្លាប់សត្វ ត្រូវតែជេរជាដើម)។

៤. អត្តនិ អគារវបទដ្ឋានំ មានការមិនគោរពខ្លួនឯងគឺមិនខ្មាសដល់ចិត្តខ្លួនឯង ជាហេតុជិត។

ឧទាហរណ៍ យើងធ្វើអាក្រក់ (លួចគេ សម្លាប់គេ) ទៅ គឺសម្លាប់ខ្លួនឯង ធ្វើបាបខ្លួនឯង។ ដូចជាការផឹកស្រាទៅ វាឈឺ វាធ្វើបាបខ្លួនឯង ធ្វើអាក្រក់ទៅ វាឱ្យផលជាទុក្ខ វាធ្វើបាបខ្លួនឯង វាមិនគោរពខ្លួនឯង។

-អ្នកខ្លះថាធ្វើល្អបានល្អ ធ្វើអាក្រក់បានលុយ មួយទៀតគេថា បាបចោចបោចចាបអីទេ។

*-អហិរិក: មានការមិនស្អប់ មិនខ្ពើម មិនខ្មាសអំពើបាប ប្រៀបដូចជាសត្វត្មាត មិនខ្ពើមសាកសពដូច្នោះ។ ដូចជាសត្វរុយ មិនខ្ពើមលាមក។*

-បុគ្គលគួរប្រញាប់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថាកាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប។

(បិដកលេខ ៥២ បាបវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះចូឡេកសាដកព្រាហ្មណ៍)

## ៣. អនោត្តប្បចេតសិក

-អនោត្តប្បៈ ព្រោះអត្ថថា មិនតក់ស្លុត មិនខ្លាច មិនញញើត ចំពោះបាប។ អនោត្តប្បៈ មិនខ្លាចចំពោះផលនៃទុច្ចរិតកម្ម មានកាយទុច្ចរិតជាដើម។

-អនោត្តប្បៈ គឺជាបដិបក្ខនឹង ឱត្តប្បៈ (សេចក្ដីតក់ស្លុត ខ្លាច ឬ ញញើតចំពោះបាប) ។

## -លក្ខណាទិចតុក្កៈរបស់ អនោត្តប្បៈ

១. អនុត្តាសលក្ខណំ មានការមិនតក់ស្លុត ចំពោះបាប ជាលក្ខណៈ ។

២. បាបានំករណរសំ មានការធ្វើបាប (គឺអកុសលកម្មបថ១០) ជាកិច្ច ។

៣. អសង្កោចនបច្ចុប្បដ្ឋានំ មានការមិនថយចាកបាប ជាអាការប្រាកដ (គឺត្រូវធ្វើតែម្ដង ត្រូវតែសម្លាប់សត្វ ត្រូវតែជេរជាដើម)។

៤. បរាគារវបទដ្ឋានំ មានការមិនគោរពអ្នកដទៃ ជាហេតុជិត។

ឧទាហរណ៍ ចង់ទៅលួចទ្រព្យគេ លួចយកដីគេ តែអត់គិតសេចក្ដីទុក្ខគេ... សម្លាប់សត្វ ជេរគេ មើលងាយគេ... មិនគោរពអ្នកដទៃ (ក្នុងអកុសលកម្មបថ១០) ។

*-អហិរិកៈ មានការមិនខ្មើម កាយទុច្ចរិតជាដើម ដូចជ្រូកមិនខ្មើមលាមក ចំណែក អនោត្តប្បៈ មានការមិនខ្លាចក្រែង ចំពោះកាយទុច្ចរិតជាដើម ដូចសត្វមមាចមិនខ្លាចភ្លើង។*

ឧទាហរណ៍ ដូចជាមនុស្សលូកភ្លើង មិនខ្លាចរលាកភ្លើង។

ឧទាហរណ៍ ដូចមនុស្សដើរជាន់អំបែងកែវ មិនខ្លាចមុតជើង។

ឧទាហរណ៍ ដូចជាមិនខ្លាចចាប់ដុំដែកដែលក្តៅ ។

-បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗឡើយ កុំគប្បីធ្វើសេចក្តី ពេញចិត្តក្នុងបាបនោះ(ព្រោះថា ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឱ្យ។

-បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយៗ គួរធ្វើសេចក្តី ពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឱ្យ ។

(បិដកលេខ ៥២  បាបវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះនាងលាជទេវធីតា)

# ៤. ឧទ្ធច្ចចេតសិក

-ឧទ្ធច្ចំ ភាវៈនៃចិត្តដែលរវើរវាយ (មិនស្ងប់) ឈ្មោះថា ឧទ្ធច្ចៈ។ ឧទ្ធច្ចៈ មានការឆ្លាទៅឆ្លាមក នៃចិត្តចំពោះអារម្មណ៍គឺ រាយមាយ ប្រៀបដូចកន្ទុយទង់ត្រូវខ្យល់បក់។

## -បណ្ដាធម៌ទាំងនោះ ឧទ្ធច្ចៈ តើដូចម្ដេច?

-ការអណ្ដែតអណ្ដូង ការមិនស្ងប់រម្ងាប់ ការរាយមាយ ការភាន់ភាំងណានៃចិត្ត នេះ ហៅថា ឧទ្ធច្ចៈ ។

-តើត្រូវសង្កេតដូចម្ដេច ដើម្បីឱ្យយើងដឹងថានេះជាចិត្តរាយមាយ ជាចិត្តអណ្ដែតអណ្ដូង?

-គឺត្រូវសង្កេតឃើញថាចិត្តអណ្ដែតអណ្ដូងនេះ គឺជាចិត្តដែលមិនតាំងមាំនៅក្នុងអារម្មណ៍តែមួយ ។

## -លក្ខណាទិចតុក្កៈរបស់ ឧទ្ធច្ចៈ

១. អវូបសមនលក្ខណំ មានការមិនចូលទៅស្ងប់ ជាលក្ខណៈ (ដូចទឹករលកព្រោះខ្យល់បក់) ។

២. អនវដ្ឋានរសំ មានការមិនតាំងនៅនឹង ក្នុងអារម្មណ៍ ជាកិច្ច (ដូចកន្ទុយទង់ត្រូវខ្យល់បក់)។

៣. ភន្តត្តបច្ចុប្បដ្ឋានំ មានការភាន់ភាំង អណ្តែតអណ្តូងនៃចិត្ត ជាអាការប្រាកដ។

៤. អយោនិសោមនសិការបទដ្ឋានំ មានអយោនិសោមនសិការ ជាហេតុជិត។

## ៥. លោភចេតសិក

-លោភៈ ព្រោះអត្ថថា ចង់បាន។ លោភៈ មានការជាប់ជំពាក់នឹងអារម្មណ៍។ ចុះជាប់ជំពាក់នឹងអ្វីខ្លះ?

-ជាប់ជំពាក់នៅក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍ ។ ដូចជាគេសុំទូរស័ព្ទ ឱ្យគេទេ? អត់

-លោភៈនេះ កើតជាមួយនឹងលោភមូលចិត្ត ៨ ដួង ប៉ុណ្ណោះ។

## -ចង់បានមាន ២ យ៉ាង ៖

១. ចង់បាន ហើយជាប់ជំពាក់ នេះហៅថា លោភៈ ។

២. ចង់បាន តែមិនជាប់ជំពាក់ យកមកត្រឹមតែជាតម្រូវការ នេះមិនមែនជាលោភៈនោះទេ ។

## -លក្ខណាទិចតុក្កៈរបស់ លោភៈ

១. អារម្មណគ្គហណលក្ខណោ មានការកាន់យកនូវអារម្មណ៍ជាលក្ខណៈ (ដូចស្វាជាប់ជ័រ) ។

២. អភិសំគរសោ មានការជាប់ជំពាក់នឹងអារម្មណ៍ ជាកិច្ច (ដូចដុំសាច់ដែលជាប់លើអំបែងក្តៅ) ។

៣. អបរិច្ចាគបច្ចុប្បដ្ឋានោ មានការមិនលះបង់ជាអាការប្រាកដ (ដូចសំពត់ប្រឡាក់ប្រេង ឬទឹកថ្នាំពណ៌) ។

ឧទាហរណ៍ ថាប្រសិនបើ ជាប់ជំពាក់នឹងទូរស័ព្ទដៃហើយចាំតែឱ្យតើ។ ជាប់ជំពាក់នឹងលុយ...។

៤. សំយោជនីយធម្មេសុ អស្សាទទស្សនបទដ្ឋានោ

មានការមើលដោយសេចក្តីគាប់ចិត្តក្នុងធម៌ដែលជាអារម្មណ៍របស់សំយោជនៈ ជាហេតុជិត។

-លោភៈនេះ វាកាន់យកតែឥដ្ឋារម្មណ៍ (អារម្មណ៍ជាទីប្រាថ្នា ជាទីពេញចិត្ត រូបស្អាត សំឡេងពីរោះជាដើម)។

## -ក្នុងបរមត្ថទីបនី បានរៀបរាប់អំពីវេវចនៈនៃលោភៈ មាន ១០ យ៉ាងគឺ៖

១. តណ្ហា ចំណង់។

២. រាគៈ តម្រេក ការត្រេកត្រអាលខ្លាំងៗ (នៅក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍) ចង់បានភ្លាមៗតែម្តង។

៣. កាមៈ សេចក្តីប្រាថ្នា ឬស្រឡាញ់ (ដោយការជាប់ជំពាក់)។

៤. នន្ទិ សេចក្តីរីករាយ ភ្លើតភ្លើន (ពេលមនុស្សរាំ ច្រៀង រាំក្រលែងចង្កេះ រាំញីកែងជើង រាំអញ្ចេកៗ...។

៥. អភិជ្ឈា សម្លឹងរំពៃ (ចង់បានទ្រព្យរបស់គេ)។

ឧទាហរណ៍ ដូចជាខួរក្បាលយើងគិតស្រមៃចង់បានលុយគេ ប្តីគេ ប្រពន្ធគេ ហើយអ្នកលេងល្បែង សម្បូរចំណុចនឹងតែម្តងលេងបៀរ ចាក់កន្ទុយលេខជាដើម ។

៦. ជនេត្តី អ្នកបង្កើត (ជីវិតក្នុងសង្សារវដ្ត) ។

៧. បោនោព្ភវិកា អ្នកឱ្យកើតក្នុងភពថ្មី (លោភមូលចិត្តនេះជាតួ អកុសលកម្ម គឺជាតួកម្ម ជាអ្នកឱ្យកើតក្នុងភពថ្មី) ។

៨. ឥច្ឆា សេចក្តីប្រាថ្នាចង់បាន (ដោយការជាប់ជំពាក់) ។

៩. អាសា ការប៉ុនប៉ង ឬសង្ឃឹម (រឿងស្នេហាសង្ឃឹមថា គេស្រឡាញ់ខ្លួន សង្ឃឹមថាធ្វើអ្វីមួយបានជោគជ័យ...) ។

១០. សញ្ញោជនៈ គ្រឿងចងសត្វទុក។

-សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ ហើយសេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

(បិដកលេខ ៥២ បិយវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះនាងវិសាខា)

-សេចក្តីសោក កើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេក ហើយសេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា។

(បិដកលេខ ៥២ បិយវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះពួកស្តេចលិច្ឆវី)

-សេចក្តីសោក កើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា។

(បិដកលេខ ៥២ បិយវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះអនិត្ថិគន្ធកុមារ)

សេចក្តីសោក កើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា។

(បិដកលេខ ៥២ បិយវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះព្រាហ្មណ៍ម្នាក់)

ឧទាហរណ៍ ដូចជាព្រាហ្មណ៍ហ្នឹង ស្រូវគាត់វាខូចដោយទឹកជំនន់។ បញ្ហាមិនមែនរឿងស្រូវខូចទេ បញ្ហាត្រង់ចិត្តរបស់គាត់ជាប់ជំពាក់នឹងស្រូវហ្នឹងប៉ុណ្ណា?

-យើងគ្រប់គ្នាក៏ដូចគ្នា កូនស្លាប់ ប្ដីប្រពន្ធស្លាប់ ឪពុកម្ដាយស្លាប់ ហ្នឹងមិនមែនជាបញ្ហាទេ បញ្ហាត្រង់ចិត្តរបស់យើងជាប់ជំពាក់និងកូន ប្ដីប្រពន្ធ ឪពុកម្ដាយហ្នឹងប៉ុណ្ណា?

## ៦. ទិដ្ឋិចេតសិក

-ទិដ្ឋិ សេចក្ដីយល់ខុស ឈ្មោះថា ទិដ្ឋិ ។

-ទិដ្ឋិ ក្នុងទីនេះសំដៅយកតែមិច្ឆាទិដ្ឋិប៉ុណ្ណោះ ។

## -ទិដ្ឋិមាន ២ យ៉ាង ៖

១. សាមញ្ញទិដ្ឋិ បានដល់ សក្កាយទិដ្ឋិដែលមានសេចក្ដី យល់ខុសចាកសភាវធម៌ថា ជាមនុស្ស ជាសត្វ ជាអត្តា ។

-ទិដ្ឋិនេះ មានទូទៅសម្រាប់បុថុជ្ជន វៀរលែងតែ ព្រះអរិយៈប៉ុណ្ណោះ ទើបហៅថា សាមញ្ញទិដ្ឋិ ។

២. ទិដ្ឋិវិសេស បានដល់ ទិដ្ឋិ ៦២ (សម្បូរតែពួកអ្នកបានឈាន) និង និយតមិច្ឆាទិដ្ឋិ ៣ ជាដើម (វៀរសក្កាយទិដ្ឋិ) ព្រោះទិដ្ឋិនេះមានចំពោះមនុស្សពួកខ្លះ និងឱកាសខ្លះប៉ុណ្ណោះ។

## -មិច្ឆាទិដ្ឋិ ១០ យ៉ាងគឺ ៖

១. យល់ថា ទានមិនមានផល ។

២. យល់ថា ការបូជាតូចមិនមានផល ។

៣. យល់ថា ការបូជាធំមិនមានផល ។

៤. យល់ថា ផលវិបាករបស់កម្មដែលសត្វធ្វើល្អ និងអាក្រក់មិនមាន ។

៥. យល់ថា លោកនេះមិនមាន ។

៦. យល់ថា លោកដទៃមិនមាន ។

៧. យល់ថា មាតាមិនមានគុណ ។

៨. យល់ថា បិតាមិនមានគុណ ។

៩. យល់ថា សត្វជាឱបបាតិកៈកំណើតមិនមាន ។

១០. យល់ថា ពួកសមណៈ និងព្រាហ្មណ៍ក្នុងលោកដែលព្រមព្រៀងប្រព្រឹត្តប្រតិបត្តិធម៌ហើយពោលថា បានធ្វើឱ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខមិនមាន ។

## -លក្ខណាទិចតុក្កៈរបស់ ទិដ្ឋិ

១. អយោនិសោ អភិនិវេសលក្ខណា មានការប្រកាន់ទុកដោយ មិនត្រូវទំនង ជាលក្ខណៈ។

២. បរាមាសរសា មានការស្ទាបអង្អែលខុសពីសភាវៈ ជាកិច្ច។

៣. មិច្ឆាភិនិវេសនបច្ចុប្បដ្ឋានា មានការប្រកាន់មាំ ក្នុងផ្លូវខុស ជាអាការប្រាកដ។

៤. អរិយានំ អទស្សនកាមតាទិ បទដ្ឋានា មានការមិនបាន ឃើញព្រះអរិយៈជាដើម ជាហេតុជិត។

## -និយតមិច្ឆាទិដ្ឋិ ៣

## -និយតមិច្ឆាទិដ្ឋិ ៣ ការយល់ខុសធ្ងន់មាន ៣ គឺ៖

១. នត្ថិកទិដ្ឋិ  យល់ឃើញថា អំពើកម្មដែលធ្វើហើយមិនឱ្យ ផល។ ការបដិសេធផល(នៃកម្ម) ។ ធ្វើអាក្រក់ គ្មានបាបចោច បោចចាបស្អីទេ។

២. អហេតុកទិដ្ឋិ យល់ឃើញថា សុខ ឬទុក្ខ កើតឡើងដោយ ឯងៗ ដោយគ្មានហេតុ។ ការបដិសេធហេតុ (នៃកម្ម) ។ ឧទាហរណ៍ ថាយើងចេះ ដោយសារយើងរៀន ជាហេតុ ។

-យើងមាន ដោយសារយើងប្រឹងរក ជាហេតុ ។

-យើងបានសុខ ដោយសារកុសលកម្ម ជាហេតុ ។

-យើងកើតទុក្ខ ដោយសារអកុសលកម្ម ជាហេតុ ។

-យើងអាយុវែង ដោយសារយើងមិនសម្លាប់សត្វ ជាហេតុ។

៣. **អកិរិយទិដ្ឋិ** យើញថា គ្មានបាប គ្មានបុណ្យ ទោះជាធ្វើអាក្រក់ ឬល្អ ក៏ឈ្មោះថាមិនមែនជាការធ្វើបាប ឬបុណ្យដែរ។ ការបដិសេធទាំងហេតុ ទាំងផល។ គ្មាននរក គ្មានសួគ៌ស្ថានទេ។

-**និយតមិច្ឆាទិដ្ឋិ ៣** នេះទើបជាការដាច់នៅក្នុងកម្មបថ ប៉ុន្តែបើក្រៅពី **និយតមិច្ឆាទិដ្ឋិ ៣** នេះ គឺ មិនដាច់កម្មបថទេ ។

-**និយតមិច្ឆាទិដ្ឋិនេះ** សូម្បីតែព្រះសម្មាសម្ពុទ្ធក៏មិនអាចជួយបានដែរ នៅក្នុងអដ្ឋកថាលោកបានបញ្ជាក់ថា បុគ្គលដែលមាននិយតមិច្ឆាទិដ្ឋិ គឺអត់មានចំណែកនៃការរួចចាកផុតទុក្ខឡើយ គឺជាបុគ្គលនៃបាតវដ្តៈតែម្យ៉ាង។ លោកបញ្ជាក់ថា បុគ្គលដែលធ្លាក់ទៅក្នុងលោកន្តរនរកនេះ ព្រះអង្គមិនព្យាករណ៍យូរប៉ុណ្ណាទេ គឺយូរក្រៃលែងណាស់ បើអនន្តរិយកម្ម ព្រះសម្មាសម្ពុទ្ធ ព្រះអង្គព្យាករណ៍មួយកប្ប។

-បុគ្គលដែលមាននិយតមិច្ឆាទិដ្ឋិ ដល់ពេលបានវិលមកកើតជាមនុស្សវិញ និយតមិច្ឆាទិដ្ឋិហ្នឹង ក៏ដុះឡើងវិញ កន្លែងនឹងទើបចាត់ចូលទៅក្នុងមិច្ឆាវិមុត្តិ គឺរួចផុតខាងខុស។

-តើរាល់ថ្ងៃមានអត់? តើសម្បូរអត់? អាចមានច្រើនទៀតផង។

-បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានហាត់ចិត្តក្នុងធម៌របស់ព្រះអរិយៈ មិនឈ្លាសវៃចំពោះធម៌របស់សប្បុរស មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស រមែងពិចារណា ឃើញរូប ថាជាខ្លួនជាដើម (សក្កាយទិដ្ឋិ២០) ។

(បិដកលេខ ៧០ មហាវគ្គ ទិដ្ឋិកថា អត្តានុទិដ្ឋិ ទំព័រ២១~៤៧)

(អដ្ឋកថាលេខ ៧០ ទិដ្ឋិកថា អត្តានុទិដ្ឋិនិទ្ទេស ទំព័រ៣៥~៥១)

-ម្នាលគហបតី បុគ្គលមានកាយរសាប់រសល់ផង មានចិត្តរសាប់រសល់ផង តើដូចម្តេច?

-ម្នាលគហបតី បុគ្គលមានកាយរសាប់រសល់ផង តែចិត្តមិនរសាប់រសល់ផង តើដូចម្តេច?

-បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង...រមែងពិចារណាឃើញច្បាស់នូវ រូបថាជាខ្លួនជាដើម (សក្កាយទិដ្ឋិ២០) ។

(បិដកលេខ ៣៣ ខន្ធវារវគ្គ ទំព័រ៦~១១)

# -សក្កាយទិដ្ឋិ ២០

## -រមែងពិចារណានៅក្នុងរូបក្ខន្ធមាន ៤ គឺ៖

១. យល់ឃើញថា រូបជាខ្លួន

២. យល់ឃើញថា ខ្លួនមានរូប

៣. យល់ឃើញថា រូបមាននៅក្នុងខ្លួន

៤. យល់ឃើញថា ខ្លួនមាននៅក្នុងរូប

១. រូបជាខ្លួន (ប្រៀបដូចពន្លឺគឺអណ្តាត អណ្តាតគឺពន្លឺ)

-រូប បានដល់ រូបក្ខន្ធ (រូប ២៨) ជាខ្លួន បានដល់ ខន្ធ ៤ ដែលនៅសល់ (វេទនា សញ្ញា សង្ខារ វិញ្ញាណ)។

-ដូចជាបុគ្គលមានសេចក្តីសម្គាល់នូវ អណ្តាតគឺពន្លឺ (រូបហ្នឹងខ្លួនជារបស់តែមួយគឺ អញតែម្តង)។

ឧទាហរណ៍ ថាយើង ឃើញរូបហ្នឹងស្អាតទៅមានការសម្គាល់ថាខ្លួនឯងនឹងស្អាត អ៊ីចឹង (ចាប់ពីក្បាលដល់ចុងជើងនេះ) ជាខ្លួនទាំងអស់។ យើងឆ្លុះកញ្ចក់មើលមុខ មើលរាងរៅ មាត់ ភ្នែក ធ្មេញ ដៃ ជើង ហើយស្រឡាញ់រូបហ្នឹង មើលហើយស្រឡាញ់ខ្លួនអត់? ស្រឡាញ់ បើស្រឡាញ់ខ្លួន គឺយល់ថារូបជាខ្លួនអត់?

យល់ថារូបជាខ្លួន បើស្រឡាញ់ខ្លួនគឺស្រឡាញ់រូប ចុះរាល់ថ្ងៃនៅស្រឡាញ់? ស្រឡាញ់ ។

-សិតសក់ឱ្យខ្លួន កាត់សក់ឱ្យខ្លួន ផាត់មុខឱ្យខ្លួន លាបម៉េ្សាឱ្យខ្លួន... ធ្វើអ្វីៗឱ្យខ្លួនទាំងអស់។

-លោភៈហ្នឹងខ្លាំងណាស់សូម្បីតែសោតាបន្ន និងសកទា ក៏នៅស្រឡាញ់រូបហ្នឹងដែរ ទាល់តែព្រះអនាគាមី បានអស់សេចក្តីស្រឡាញ់ នៅក្នុងវត្ថុកាម អ៊ីចឹងបានយើងត្រូវសិក្សាឱ្យដឹងជាមុនសិន...។

២. ខ្លួនមានរូប (ប្រៀបដូចដើមឈើមានស្រមោល)

-ដើមឈើផ្សេង ស្រមោលផ្សេង ខ្លួនផ្សេង រូបផ្សេង ហើយខ្លួនហ្នឹងមានរូប ។

ឧទាហរណ៍ នៅពេលណា រូបនឹងប្រែប្រួលទៅ ចាស់ គ្រាំគ្រាទៅបុគ្គលនោះឃើញសភាពប្រែប្រួលរបស់រូប រួចគាត់ក៏លែងសម្គាល់ឃើញថា រូបជាខ្លួនទៀតហើយ គឺសម្គាល់ឃើញថាខ្លួនមានរូប ដូចជាសម្គាល់ ដើមឈើមានស្រមោលអ៊ីចឹង ។

-រូបនេះដល់ពេលស្លាប់ទៅគេយករូបនឹងទៅដុតចោល ហើយខ្លួននឹងទៅកើតទៀត មនុស្សយើងដ៏ច្រើនគឺយល់ខុសកន្លែងហ្នឹង នៅពេលដែលយើងស្លាប់ទៅ រូបនឹងបែកធ្លាយទៅតែសម្គាល់ថាខ្លួនកើតទៀត នេះចូលក្នុង សស្សតទិដ្ឋិ ។

## ៣. រូបមាននៅក្នុងខ្លួន (ប្រៀបដូចក្លិនមាននៅក្នុងផ្កា)

-ក្លិនដូចជារូប (រូបក្ខន្ធ) ផ្កាដូចជាខ្លួន (ខន្ធ ៤ ដែលនៅសល់ មានវេទនា សញ្ញា សង្ខារ វិញ្ញាណ)។

ឧទាហរណ៍ នៅពេលយើងហិតក្លិនផ្កា តែងតែសម្គាល់ថាក្លិនហ្នឹងមាននៅក្នុងផ្កា ដូច្នេះបុគ្គលដែលពិចារណា ឃើញថារូបមាននៅក្នុងខ្លួន គឺដូចជាក្លិនមាននៅក្នុងផ្កាអ៊ីចឹង។

-រូបមាននៅក្នុងខ្លួន កាលណាដែលខ្លួនចង់ដើរទៅមុខ ដើរទៅក្រោយ ខ្លួនចង់ដេក ខ្លួនចង់អង្គុយ ខ្លួនចង់ឈរ ខ្លួនចង់ដើរ

ក៏ញ៉ាំងរូបនឹងឱ្យប្រព្រឹត្តទៅ ខ្លួនគិតដើម្បីធ្វើអ្វីៗ ទៅណា រូបនោះ ក៏ប្រព្រឹត្តទៅតាមជាមួយដែរ ប្រៀបដូចជាក្លិនដែលមាននៅក្នុងផ្កា គេយកផ្កាទៅដល់ទីណា ក្លិនក៏ទៅដល់ទីនោះដែរ។

-មានន័យថា រូបនៅក្នុងអំណាចរបស់ខ្លួន

ឧទាហរណ៍ ថាខ្លួនទៅផ្សាររូបក៏ទៅផ្សារ ខ្លួនងូតទឹករូបក៏ទៅងូតទឹក ខ្លួនទៅហូបបាយរូបក៏ទៅហូបបាយ។

ឧទាហរណ៍ ខ្លួនទៅស្តាប់ធម៌ រូបក៏ទៅស្តាប់ធម៌ដែរ ខ្លួននិយាយធម៌ រូបក៏និយាយធម៌ដែរ ។

៤. ខ្លួនមាននៅក្នុងរូប (ប្រៀបដូចកែវមណីនៅក្នុងដប)

-កែវមណីដូចជាខ្លួន (ខន្ធ ៤ ដែលនៅសល់ មានវេទនា សញ្ញា សង្ខារ វិញ្ញាណ) រីឯ ដបដូចជារូប (រូបក្ខន្ធ) ។

-មានន័យថា រូបឋិតនៅក្នុងទីណា ខ្លួនក៏ឋិតនៅទីនោះដែរ

ដបឋិតនៅទីណា កែវមណីក៏ឋិតនៅទីនោះដែរ។

ឧទាហរណ៍ ថាបើរូបនឹងឈឺ ខ្លួនក៏ឈឺដែរ បើរូបប្រែប្រួលយ៉ាងណា ខ្លួនក៏ប្រែប្រួលទៅតាមរូបនោះដែរ ។

-មានន័យថា ខ្លួននៅក្រោមអំណាចរបស់រូបវិញម្តង

ឧទាហរណ៍ រូបទៅស្តាប់ធម៌ ខ្លួនក៏ទៅស្តាប់ធម៌ដែរ រូបនិយាយធម៌ ខ្លួនក៏និយាយធម៌ដែរ ។

## -វមែងពិចារណានៅក្នុងវេទនាខន្ធ មាន ៤ គឺ៖

១. យល់ឃើញថា វេទនាជាខ្លួន

២. យល់ឃើញថា ខ្លួនមានវេទនា

៣. យល់ឃើញថា វេទនាមាននៅក្នុងខ្លួន

៤. យល់ឃើញថា ខ្លួនមាននៅក្នុងវេទនា

១. វេទនាជាខ្លួន (ប្រៀបដូចពន្លឺគឺអណ្តាត)

-វេទនា បានដល់ វេទនាខន្ធ ជាខ្លួន បានដល់ ខន្ធ ៤ ដែលនៅសល់ (រូប សញ្ញា សង្ខារ វិញ្ញាណ)។

ឧទាហរណ៍ ខណៈពេលយើងសប្បាយចិត្តហ្នឹង យល់ថាខ្លួនជាអ្នកសប្បាយចិត្ត ខណៈពេលយើងកើតទុក្ខ យល់ថាខ្លួនអ្នកកើតទុក្ខ។

២. ខ្លួនមានវេទនា (ប្រៀបដូចដើមឈើមានស្រមោល)

-ដើមឈើផ្សេង ស្រមោលផ្សេង ខ្លួនផ្សេង វេទនាផ្សេង ហើយខ្លួនហ្នឹងមានវេទនា ។

ឧទាហរណ៍ នៅពេលដែលវេទនានឹងប្រែប្រួលទៅ បុគ្គលនោះឃើញសភាពប្រែប្រួលរបស់វេទនា រួចក៏លែង សម្គាល់ឃើញថា វេទនាជាខ្លួនទៀតហើយ គឺសម្គាល់ឃើញថាខ្លួនមានវេទនា ប្រៀបដូចជាសម្គាល់ ដើមឈើមានស្រមោលអ៊ីចឹង ។

ឧទាហរណ៍ ខ្លួនមានវេទនា ខ្លួនហ្នឹងវាចេះសុខ ចេះកើតទុក្ខ ចេះឈឺ ខ្លួនឈឺធ្មេញ ខ្លួនឈឺពោះ ខ្លួនឈឺក្បាល...។

៣. វេទនាមាននៅក្នុងខ្លួន (ប្រៀបដូចក្លិនមាននៅក្នុងផ្កា)

-ក្លិនដូចជាវេទនា បានដល់ (វេទនាខន្ធ) ផ្កាដូចជាខ្លួន បានដល់ ខន្ធ ៤ ដែលនៅសល់ (រូប សញ្ញា សង្ខារ វិញ្ញាណ)។

ឧទាហរណ៍ សេចក្តីសុខ សេចក្តីទុក្ខ មាននៅក្នុងខ្លួន ដូចជា យើងងូតទឹក ឱ្យខ្លួនទៅ វាត្រជាក់ដល់អីចឹងទៅវាបានសុខ។

-មានន័យថា វេទនានៅក្នុងអំណាចរបស់ខ្លួន

៤. ខ្លួនមាននៅក្នុងវេទនា (ប្រៀបដូចកែវមណីនៅក្នុងដប)

-កែវមណីដូចជាខ្លួន (ខន្ធ ៤ ដែលនៅសល់ មាន រូប សញ្ញា សង្ខារ វិញ្ញាណ) រីឯ ដបដូចជាវេទនា (វេទនាខន្ធ)។

-មានន័យថា វេទនាឋិតនៅក្នុងទីណា ខ្លួនក៏ឋិតនៅទីនោះដែរ ដបឋិតនៅទីណា កែវមណីក៏ឋិតនៅទីនោះដែរ។

ឧទាហរណ៍ នៅពេលសេចក្តីសុខកើតឡើង សេចក្តីទុក្ខកើតឡើងហ្នឹងខ្លួនអ្នកកើតទុក្ខ ខ្លួនក៏ជាអ្នកសុខដែរ។

-មានន័យថា ខ្លួននៅក្រោមអំណាចរបស់វេទនាវិញម្តង

## -រមែងពិចារណានៅក្នុងសញ្ញាខន្ធ មាន ៤ គឺ៖

១. យល់ឃើញថា សញ្ញាជាខ្លួន

២. យល់ឃើញថា ខ្លួនមានសញ្ញា

៣. យល់ឃើញថា សញ្ញាមាននៅក្នុងខ្លួន

៤. យល់ឃើញថា ខ្លួនមាននៅក្នុងសញ្ញា

## -វម៉ែងពិចារណានៅក្នុងសង្ខារក្ខន្ធ មាន ៤ គឺ៖

១. យល់ឃើញថា សង្ខារជាខ្លួន

២. យល់ឃើញថា ខ្លួនមានសង្ខារ

៣. យល់ឃើញថា សង្ខារមាននៅក្នុងខ្លួន

៤. យល់ឃើញថា ខ្លួនមាននៅក្នុងសង្ខារ

-សេចក្តីប្រកាន់ សង្ខារជាខ្លួនជាដើម ។

-សង្ខារ បានដល់ ចេតសិក ៥០ (វៀរ វេទនា សញ្ញា )

-ខ្លួន បានដល់ ខន្ធ ៤ ដែលនៅសល់ (មាន រូប វេទនា សញ្ញា វិញ្ញាណ)។

-រូប បានដល់ រូប ២៨ ។ វេទនា បានដល់ វេទនា ៣ ។

-សញ្ញា បានដល់ ការចងចាំច្រើនទៀត។

-វិញ្ញាណ បានដល់ ចិត្ត ៨៩ ដួង ឬ ១២១ ដួង។

ឧទាហរណ៍ សង្ខារជាខ្លួន សតិជាខ្លួន បញ្ញាជាខ្លួនជាដើម។

ឧទាហរណ៍ ខ្លួនមានសង្ខារ ខ្លួនរៀនពូកែ ឆ្លាត ខ្លួនមានបញ្ញា ខ្លួនមានការច្រណែន ខ្លួនចូលចិត្តខឹង ខ្លួនចូលចិត្តស្រឡាញ់ជាដើម មិនមែនពោលដោយវោហារទេគឺពោលដោយទិដ្ឋិមែនទែនតែម្តង ។

## -វមែងពិចារណានៅក្នុងវិញ្ញាណក្ខន្ធ មាន ៤ គឺ៖

១. យល់ឃើញថា វិញ្ញាណជាខ្លួន

២. យល់ឃើញថា ខ្លួនមានវិញ្ញាណ

៣. យល់ឃើញថា វិញ្ញាណមាននៅក្នុងខ្លួន

៤. យល់ឃើញថា ខ្លួនមាននៅក្នុងវិញ្ញាណ

-សេចក្តីប្រកាន់ វិញ្ញាណជាខ្លួនជាដើម ។

ឧទាហរណ៍ ចិត្តឃើញជាខ្លួន ចិត្តឮជាខ្លួន ចិត្តលោភៈជាខ្លួន ចិត្តទោសៈខ្លួន ទាំងអស់។

## -សក្កាយទិដ្ឋិ ២០ ដោយសង្ខេប

-(រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ជាខ្លួន ។

-ខ្លួនមាន (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ។

-(រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) មាននៅក្នុងខ្លួន ។

-ខ្លួនមាននៅក្នុង (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ។

-សក្កាយទិដ្ឋិ ២០ នេះ គឺការប្រកាន់ ដោយទិដ្ឋិ ។

-ការប្រកាន់ (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ជាអញ គឺការប្រកាន់ ដោយមានះ ។

-ការប្រកាន់ (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ថាជារបស់អញ គឺការប្រកាន់ ដោយតណ្ហា ។

-ការប្រកាន់របស់បុថុជ្ជន គឺប្រកាន់ដោយតណ្ហា ដោយទិដ្ឋិ ដោយមានះ ដូច្នេះឯង ។

## -ចុះព្រះអរិយបុគ្គលពិចារណា យ៉ាងម៉េចវិញ?

-ព្រះអរិយបុគ្គលពិចារណាឃើញថា រូបអតីត អនាគត បច្ចុប្បន្ន ជាដើម គ្រាន់តែជារូបប៉ុណ្ណោះ ព្រះអរិយៈដឹងច្បាស់ថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអតីត អនាគត បច្ចុប្បន្ននោះ គ្រាន់តែជាវេទនា សញ្ញា សង្ខារ វិញ្ញាណប៉ុណ្ណោះ ហើយវិញ្ញាណនោះគឺជាធម៌ដែលមានការកើតឡើងផ្សេង រលត់ទៅវិញផ្សេង ទាំងយប់ ទាំងថ្ងៃ ហើយការពិចារណាបែបនេះមិនមែនជាសក្កាយទិដ្ឋិ ហើយការរលត់ទៅនៃសក្កាយទិដ្ឋិនេះ ព្រះអរិយបុគ្គលឃើញថាជាសុខ តែសេចក្តីសុខនេះ រមែងជំទាស់ក្នុងលោកទាំងមូល ពីព្រោះ មនុស្សលោក ទេវតាលោក និងព្រហ្មលោក រមែងសម្គាល់ថា រូបជាខ្លួន ។

## -សក្កាយទិដ្ឋិ ២០

១. ការប្រកាន់រូបសុទ្ធ មាន១ គឺ រូបជាខ្លួន ។

២. ការប្រកាន់នាមថាជាខ្លួន មាន៧ គឺ ៖

-(វេទនា សញ្ញា សង្ខារ វិញ្ញាណ) ជាខ្លួន អស់ ៤ ។

-នៅ ៣ ទៀត ខ្លួនមានរូប រូបនៅក្នុងខ្លួន ខ្លួននៅក្នុងរូប ។

៣. ការប្រកាន់ទាំងរូប ទាំងនាម ច្រឡំគ្នា ថាខ្លួន មាន ១២ គឺ អ្វីដែលនៅសល់ពីខាងលើ ។

## -បើចែកជាឧច្ឆេទទិដ្ឋិ (វិភវទិដ្ឋិ មាន ៥ គឺ ៖

-នៅពេលប្រកាន់ខន្ធ៥ ហ្នឹងថាជាខ្លួន (រូបជាខ្លួន វេទនាជាខ្លួន សញ្ញាជាខ្លួន សង្ខារជាខ្លួន វិញ្ញាណជាខ្លួន) ដល់ខន្ធ ៥ ហ្នឹងបែកធ្លាយទៅ ខ្លួនហ្នឹងក៏ដាច់សូន្យដែរ នេះជា ឧច្ឆេទទិដ្ឋិ ។

## -បើចែកជាសស្សតទិដ្ឋិ (ភវទិដ្ឋិ មាន ១៥ គឺ ៖

-នៅពេលយល់ឃើញថា ខ្លួនមានរូប អ៊ីចឹង នេះមិនមែនរូបជាខ្លួនទេប៉ុន្តែ ខ្លួនមានរូប ដល់រូបហ្នឹងបែកធ្លាយទៅ ក៏ខ្លួនហ្នឹងទៅកើតទៀត ដែលមានគំនិតបែបហ្នឹង គឺជា សស្សតទិដ្ឋិ ។

-ទិដ្ឋិទាំងពីរនេះ កាលណាកើតឡើងក្នុងអារម្មណ៍ណា ដេកសម្ងំនៅក្នុងអារម្មណ៍ណា ផុសផុលនៅក្នុងអារម្មណ៍ណា បុគ្គលពិចារណាដោយប្រាជ្ញាដ៏ប្រពៃចំពោះអារម្មណ៍នោះថា នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនរបស់អញ នេះជាឧបាយក្នុងការលះនូវទិដ្ឋិទាំងពីរ ។

# ៧. មានចេតសិក

-មានោ ឈ្មោះថា មានះ ព្រោះអត្ថថាសម្គាល់ខ្លួនដោយលក្ខណៈ មានជាដើមថា « យើងជាអ្នកប្រសើរជាងគេ យើងស្អាតជាងគេ យើងឆ្លាតជាងគេ » ដូច្នេះ ជាដើម ។

-មានៈ ព្រោះអត្ថថា ការលើកតម្កើងខ្លួនជាដើម ។

-ការប្រកាន់ (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ជាអញ គឺជាការប្រកាន់ដោយមានះ ។

-សេចក្តីស្រវឹងទាំង ២៧ ប្រការ អង្គធម៌ គឺមានចេតសិក។

-បបញ្ចធម៌ គឺ ធម៌ធ្វើឱ្យយឺតយូរ ( តណ្ហា ទិដ្ឋិ មានៈ) ។

## -មានៈ មាន ២ យ៉ាង

-មានៈ ដែលព្រះសោតាបន្នលះ ហៅថា អយាថាវមានះ មាន ៦ គឺ៖

| | | |
|---|---|---|
| ១. ល្អជាងគេ | សម្គាល់ថាខ្លួនថា | ស្មើនឹងគេ |
| ២. ល្អជាងគេ | សម្គាល់ថាខ្លួនថា | ទាបជាងគេ |
| ៣. ស្មើនឹងគេ | សម្គាល់ថាខ្លួនថា | ល្អជាងគេ |
| ៤. ស្មើនឹងគេ | សម្គាល់ថាខ្លួនថា | ទាបជាងគេ |
| ៥. ទាបជាងគេ | សម្គាល់ថាខ្លួនថា | ល្អជាងគេ |

៦. ទាបជាងគេ សម្គាល់ថាខ្លួនថា ស្មើនឹងគេ ។

-មានះ ដែលព្រះអរហន្តលះ ហៅថា យាថាវមានះមាន ៣ គឺ ៖

១. ល្អជាងគេ សម្គាល់ថាខ្លួនថា ល្អជាងគេ

២. ស្មើនឹងគេ សម្គាល់ថាខ្លួនថា ស្មើនឹងគេ

៣. ទាបជាងគេ សម្គាល់ថាខ្លួនថា ទាបជាងគេ។

## -ម្យ៉ាងទៀត មានះ មានវេវចនៈ ច្រើនយ៉ាងដូច្នេះ គឺ ៖

១. ឈ្មោះថា អតិមានះ ការមើលងាយ បន្តុះបង្អាប់អ្នកដទៃ។

២. ឈ្មោះថា មានាតិមានះ សេចក្តីឆ្មើងកន្ទ្រើង ក្រអឺតក្រទម។

៣. ឈ្មោះថា ឱមានះ ការប្រកាន់ដំថោកទាប។

៤. ឈ្មោះថា អធិមានះ សម្គាល់ថា សម្រេចធម៌វិសេស។

៥. ឈ្មោះថា អស្មិមានះ សម្គាល់ថា មានអត្តា (មានតែអញ)។

៦. ឈ្មោះថា មិច្ឆាមានះ សម្គាល់ខុស។

## -លក្ខណាទិចតុក្កៈរបស់ មានះ

១. ឧន្នតិលក្ខណោ មានការលើកខ្លួន (អួតខ្លួន) ជាលក្ខណៈ។

២. សម្បគ្គហរសោ មានការលើកតម្កើងខ្លួន (ប្រកាន់ឫក) ជាកិច្ច ។

៣. កេតុកម្យតាបច្ចុប្បដ្ឋានោ មានសេចក្តីត្រូវការខ្ពស់ ដូចជាទង់ ជាអាការប្រាកដ។

៤. ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ មានលោភៈ មិនប្រកបដោយទិដ្ឋិ ជាហេតុជិត។

-បុគ្គលលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញគួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គល ដែលមិនជាប់ ជំពាក់ក្នុងនាម និង រូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ។

(បិដកលេខ ៥២ កោធវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះសត្តិយកញ្ញា ឈ្មោះ រោហិណី)

## ៨. ទោសចេតសិក

-ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយ។

ទោសៈ ព្រោះអត្ថថា ជាហេតុប្រទូសរ៉ាយសត្វ ឬឈ្មោះ ទោសៈ អត្ថថា ប្រទូសរ៉ាយខ្លួនឯង ឬថាត្រឹមតែប្រទូសរ៉ាយប៉ុណ្ណោះ ក៏ឈ្មោះថា ទោសៈ។

*ទោសៈ នេះគប្បីឃើញដូចជា ទឹកមូត្រស្អុយលាយដោយថ្នាំពិស។*

## -លក្ខណាទិចតុក្កៈរបស់ ទោសៈ

១. ចណ្ឌិកលក្ខណោ មានការកាច ជាលក្ខណៈ

(ដូចអាសិរ្វិស ដែលត្រូវគេវាយ) ។

២. វិសប្បនរសោ អត្តនោ និស្សយទហនរសោ វា មានការក្រហល់ក្រហាយជាកិច្ច (ដូចត្រូវថ្នាំពិសជ្រាបចូល) ឬមានការដុតកម្តៅទីនៅរបស់ខ្លួន ជាកិច្ច (ដូចភ្លើងឆេះព្រៃ) ។

៣. ទុស្សនបច្ចុប្បដ្ឋានោ មានការប្រទូសរ៉ាយ ជាអាការប្រាកដ

(ដូចសត្រូវមានឱកាស) ។

៤. អាឃាតវត្ថុបទដ្ឋានោ មានអាឃាតវត្ថុ ជាហេតុជិត។

## -អាឃាតវត្ថុ ១០

១. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ។

២. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ។

៣. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ។

៤. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់

ជាទីពេញចិត្តរបស់អាត្មាអញ។

៥. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជា
ប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់
ជាទីពេញចិត្តរបស់អាត្មាអញ។

៦. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជា
ប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់
ជាទីពេញចិត្តរបស់អាត្មាអញ។

៧. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជា
ប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់
មិនជាទីពេញចិត្តរបស់អាត្មាអញ។

៨. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជា
ប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់
មិនជាទីពេញចិត្តរបស់អាត្មាអញ។

៩. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជា
ប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់
មិនជាទីពេញចិត្តរបស់អាត្មាអញ។

១០. សេចក្តីក្រោធកើតឡើងក្នុងទីមិនគួរ ដូចពេលដែលដើរ
ជំពប់ជើង ជាន់បន្លា នៅពេលស្ទះចរាចរណ៍ ហាន់បន្លែមុតដៃឬ
ដើរបុកជញ្ជាំង ជាដើម។

ឧទាហរណ៍ ថាយើងកំពុងធ្វើអ្វីមួយទៅ កម្ទេច ធូលី ចូលភ្នែក រួចក៏ខឹង សរសេរអក្សរខុស វាយកំព្យូទ័រខុស កំពុងចុចទូរស័ព្ទលេងហ្វេសប៊ុក (face book) អ៊ីនធឺណិត(internet) ដើរឃើត ឬអេរើ (error) ទៅក៏ខឹងដែរ (ទោះបីខណៈពេលរៀនធម៌ ស្តាប់ធម៌នឹងក៏ដោយ) នៅសុខៗឈឺផ្ចេញ ឈឺពោះជាដើមក៏ខឹងដែរ។

ឧបមាថា ផ្ទះអ្នកជិតខាង ត្រូវភ្លើងឆេះ តើយើងត្រូវធ្វើដូចម្ដេច? យើងត្រូវជួយយកទឹកមកពន្លត់ ឬហៅអ្នកជិតៗនឹង ឱ្យជួយពន្លត់ ឬតេហៅឡានពន្លត់អគ្គីភ័យឱ្យមកជួយ។

-ចុះប្រសិនបើអ្នកដទៃកំពុងឆេះ ដោយសេចក្ដីក្រោធ តើយើងត្រូវទៅជួយពន្លត់ដូចម្ដេច? គឺជាអ្នកមិនខឹងតប មានមេត្តាមានសេចក្ដីអត់ធន់ (ខន្តី) និងជាអ្នកស្លូតបូត ។

-តើរាល់ដងមានបានជួយពន្លត់គ្នា ឬក៏ជួយដុតថែម?

-តើយើងយកឡានទឹកទៅពន្លត់ភ្លើង ឬក៏យកឡានសាំងមកបាញ់ថែម?

-បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាបរមែងត្រឡប់មករកបុគ្គលពាលមកវិញ ដូចធូលីល្អិត ដែលបុគ្គលបាចសាចទៅកាន់ទីច្រាសខ្យល់។

(បិដកលេខ ៥២ បាបវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះនាយព្រានសុនខ ឈ្មោះ កោក:)

-បុគ្គលណាឃាត់ សេចក្ដីក្រោធដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគត ហៅបុគ្គលនោះថា ជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ (មិនមែនសារថីឡើយ ។

(បិដកលេខ ៥២ កោធវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះភិក្ខុមួយរូប)

## ៩. ឥស្សាចេតសិក

-ឥស្សា ព្រោះអត្ថថា ច្រណែន។ ឥស្សា ព្រោះ ឫស្សា ឬ ច្រណែន។ ឥស្សា នេះច្រណែនគ្នា មិនឱ្យអ្នកដទៃបានលាភសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន និងការបូជាជាដើម។

ឧទាហរណ៍ ឪពុកម្ដាយ ស្រឡាញ់កូនអត់ស្មើគ្នា ស្រឡាញ់កូនពៅជាងកូនបង កូនបងច្រណែន។

-គេរកស៊ីមានជាងខ្លួនទៅច្រណែនគេ គេរៀនចេះជាង ។

-គេធ្វើការបានប្រាក់ខែច្រើនជាង គេយល់ធម៌ច្រើនជាង ។

-គេមានប្ដី មានប្រពន្ធ មានកូនល្អ គេសុខជាងយើងច្រណែន គេឃើញគេមានឡាន មានផ្ទះស្អាតជាងខ្លួនទៅច្រណែនគេ។

ឧទាហរណ៍ ឃើញគេមានទូរស័ព្ទ មានម៉ូតូ ស្អាតជាងខ្លួន ឃើញរូបគេស្អាត គេមានអ្នកស្រឡាញ់ច្រើនទៅច្រណែនគេ។

## -លក្ខណាទិចតុក្កៈរបស់ ឥស្សា

១. បរសម្បត្តីនំ ឧស្សូយនលក្ខណា មានការច្រណែនសម្បត្តិ (អ្វីដែលល្អ) របស់អ្នកដទៃ ជាលក្ខណៈ។

២. តត្ថេវ អនភិរតិរសា មានការមិនត្រេកអរក្នុងសម្បត្តិរបស់អ្នកដទៃ ជាកិច្ច។

៣. វិមុខភាវបច្ចុប្បដ្ឋានា មានការបែរមុខចេញ ជាអាការប្រាកដ។

៤. បរសម្បត្តិបទដ្ឋានា មានសម្បត្តិអ្នកដទៃ ជាហេតុជិត។

## ១០. មច្ឆរិយចេតសិក

-មច្ឆរិយំ ភាវៈនៃ បុគ្គលអ្នកកំណាញ់ ឈ្មោះថា មច្ឆរិយៈ។

*-បណ្ឌិតគប្បីឃើញមច្ឆរិយៈថាជាសេចក្តីពិការរបស់ចិត្ត។*

## -មច្ឆរិយៈ ៥ យ៉ាង ៖

១. សេចក្តីកំណាញ់អាវាស (កំណាញ់ផ្ទះ ឬវត្ត គេសុំទៅលេងផងមិនបានទេ គេសុំទៅដេកផងមិនបានទេ)។

២. សេចក្តីកំណាញ់ត្រកូល (កំណាញ់ការរាប់អាន យើងមិនរាប់អានអ្នកឯងទេ អ្នកឯងក្រ អ្នកឯងត្រកូលថោកទាប) ។

៣. សេចក្ដីកំណាញ់លាភ (លាភហ្នឹងសមតែបានអញ គេនោះមិនសមបានទេ) ។

-មនុស្សយើងជាធម្មតា គឺលាក់ល្បិចរកស៊ី លាក់ចំណេះដឹង មិនបង្ហាត់បង្រៀនគេទេ តែលាក់ទុកតែខ្លួនឯង។

ឧទាហរណ៍ មុខរបររកស៊ី កន្លែងរកស៊ីបាន អីចឹងគេសួរ មិនប្រាប់ឱ្យគេដឹងទេ។

៤. សេចក្ដីកំណាញ់វណ្ណៈ (ពណ៌សម្បុរ និងសេចក្ដីសរសើរ)។

ឧទាហរណ៍ ថាគេពោលធម៌ហ្នឹងបានត្រឹមត្រូវល្អហើយ មិនព្រមអនុមោទនាទេ មិនព្រមសរសើរគេទេ។

ឧទាហរណ៍ ខ្លួនមានផលិតផលឡេលាបស្បែក ឱ្យសស្អាត ប៉ុន្តែដល់គេសួរទៅអត់ហ៊ានប្រាប់គេទេ ខ្លាចគេស្អាតជាង ។

៥. សេចក្ដីកំណាញ់ធម៌ (បរិយត្តិធម៌ និងបដិវេធធម៌) ។

សេចក្ដីកំណាញ់បរិយត្តិធម៌ មានន័យថាចេះហើយអត់បង្រៀនគេទេ លាក់ទុកមិនបង្ហាញគេទេ សម្ងំរៀនតែឯង ពេលខ្លះទុកនិយាយខ្លួនឯងឱ្យគេដឹងថាអញហ្នឹងអ្នកចេះ។

ឧទាហរណ៍ យើងដឹងថា សតិប្បដ្ឋាន ៤ គឺជាផ្លូវដើម្បីរួចចាកផុតទុក្ខ ដើម្បីបដិវេធធម៌ ដល់យើងដឹង យើងអត់ប្រាប់គេ យើងលាក់ទុក នេះហៅថា សេចក្ដីកំណាញ់បដិវេធធម៌ ។

-សេចក្តីកំណាញ់បដិវេធធម៌ គឺសំដៅដល់ធម៌ដែលសម្រេចធម៌ ពេលលោកសម្រេចលោកសុខបែបណា លោកប្រាប់យើង លោកអត់ចេះលាក់ទេ។

ឧទាហរណ៍ អ្នកហាត់ក្បាច់គុន លាក់ក្បាច់ទុករហូត ។

## -លក្ខណាទិចតុក្កៈរបស់ មច្ឆរិយៈ

១. លទ្ធានំ វា លភិតព្វានំ អត្តនោ សម្បត្តីនំ និគូហណលក្ខណំ មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានហើយ ឬដែលគួរបាន ជាលក្ខណៈ។

២. តាសំយេវ បរេហិ សាធារណភាវអក្ខមនរសំ មានការមិនពេញចិត្តក្នុងការឱ្យសម្បត្តិរបស់ខ្លួនទៅជាសាធារណៈដល់ជនដទៃ ជាកិច្ច។

៣. សំកោចនបច្ចុប្បដ្ឋានំ មានការធ្វើមុខក្រញូវ ឬមិនអើពើជាអាការប្រាកដ។

៤. អត្តានោ សម្បត្តិបទដ្ឋានំ មានសម្បត្តិរបស់ខ្លួន ជាហេតុជិត

-អ្នកខ្លះមិនមែនកំណាញ់តែទ្រព្យរបស់ខ្លួនទេ គឺកំណាញ់ទាំងទ្រព្យរបស់គេទៀតផង ឃើញគេធ្វើបុណ្យ គឺអត់បាន គឺស្តាយទ្រព្យរបស់គេទៀត ម្ចាស់គេមិនស្តាយទ្រព្យរបស់គេផងនឹង។

# -ព្រះពុទ្ធដីកា

-សេចក្ដីកំណាញ់ គឺជាធម៌ធ្វើនូវសេចក្ដីអន្តរាយ មិនជាប្រយោជន៍ គឺជាសញ្ញោជនៈ ជានីវរណៈដែលរាំងក្នុងដំណើរទៅកាន់ឋានសួគ៌ និងព្រះនិព្វាន។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចគេនាំយកទៅទម្លាក់ ធម៌ ៥ យ៉ាង តើដូចម្ដេច?

-គឺភិក្ខុនីកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ (សេចក្ដីសរសើរ) ១ កំណាញ់ធម៌ ១ ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។

# -ព្រះអដ្ឋកថា

១. ភិក្ខុនីកំណាញ់អាវាស បានដល់ រមែងកំណាញ់អាវាស គឺឃើញអ្នកដទៃនៅក្នុងអាវាសនោះ អត់ធន់មិនបាន ។

២. កំណាញ់ត្រកូល បានដល់ រមែងកំណាញ់ត្រកូលឧបដ្ឋាក គឺឃើញអ្នកដទៃចូលទៅរកត្រកូលនោះ អត់ធន់មិនបាន ។

៣. កំណាញ់លាភ បានដល់ រមែងកំណាញ់លាភ គឺឃើញលាភកើតឡើងដល់អ្នកដទៃ ក៏អត់ធន់មិនបាន ។

៤. កំណាញ់គុណ បានដល់ រមែងកំណាញ់គុណ គឺសេចក្ដីល្អ គឺឃើញគេពោលគុណ គឺសេចក្ដីល្អរបស់អ្នកដទៃ ក៏អត់ទ្រាំមិនបាន ។

៥. កំណាញ់ធម៌ បានដល់ រមែងកំណាញ់បរិយត្តិធម៌ គឺមិនប្រាថ្នានឹងឱ្យដល់អ្នកដទៃ ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ធម៌ ៥ យ៉ាង តើដូចម្ដេច?

-គឺភិក្ខុនីមិនកំណាញ់អាវាស ១ មិនកំណាញ់ត្រកូល ១ មិនកំណាញ់លាភ ១ មិនកំណាញ់គុណ (សេចក្ដីសរសើរ) ១ មិនកំណាញ់ធម៌ ១ ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ។

(បិដកលេខ ៤៥ បញ្ចកនិបាត មច្ឆរិយសូត្រ ទំព័រ២៣~២៤)

(អដ្ឋកថាលេខ ៤៥ បញ្ចកនិបាត មច្ឆរិយសូត្រ ទំព័រ១៨)

-ការមានសេចក្ដីកំណាញ់ គឺនាំសត្វទៅកាន់ទីថោកទាប នាំយើងនឹងធ្លាក់ទៅកាន់នរក ហើយបើកើតជាមនុស្សវិញ កើតក្នុងត្រកូលអ្នកក្រខ្សត់ ព្រោះសេចក្ដីកំណាញ់ ។

-សេចក្តីកំណាញ់ យើងបានដឹងថាជាអកុសល ទើបយើងរកឧបាយដើម្បីកម្ចាត់បង់នូវសេចក្តីកំណាញ់ ។

-ហើយត្រូវអវិជ្ជា នឹងបិទបាំងមិនឱ្យឃើញសេចក្តីកំណាញ់ (សេចក្តីច្រណែន ជាដើម) នឹងជាអកុសល ថាជាធម៌ចងសត្វទុកក្នុងវដ្តៈ ។

-កាលដែលយើងមិនបានឃើញអកុសល គឺជាធម៌សៅហ្មងហ្នឹង ព្រោះអវិជ្ជានឹងបិទបាំងមិនឱ្យឃើញសេចក្តីពិត ។

-នៅពេលខ្លះ យើងយល់ថាកំណាញ់ គឺកំណាញ់តែទ្រព្យទេបានហៅថា កំណាញ់ ។ ក៏ប៉ុន្តែកំណាញ់ទាំងអស់ ៥ គឺ កំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់សេចក្តីសរសើរ កំណាញ់ធម៌ ។

-នៅពេលដែលយើងបានសិក្សាពីសេចក្តីកំណាញ់ ៥ យ៉ាងហ្នឹង ហើយយើងរៀនត្រួតមើល យើងរៀនត្រូវសង្កេតមើលដោយឋានៈ ៥ យ៉ាង ដើម្បីរកឃើញនូវសេចក្តីកំណាញ់ ៖

១. កំណាញ់អាវាស កំណាញ់ទីកន្លែង ដូចជាគេយើងធ្លាប់អង្គុយកន្លែងហ្នឹងរៀនធម៌ ដល់ថ្ងៃហ្នឹងយើងមកយឺត រួចឃើញគេមកអង្គុយនៅកន្លែងហ្នឹង យើងមានការចង្អៀតចិត្ត ទ្រាំអត់បាន ។

ឧទាហរណ៍ ថាយើងបើកឡាន បើកម៉ូតូ លើផ្លូវថ្នល់ ដល់គេប្រកាន់ខាងស្តាំ មិនបើកផ្លូវឱ្យគេទៅទេ នេះជាសេចក្តីកំណាញ់ទីកន្លែង ។

២. កំណាញ់ត្រកូល គឺនៅពេលដែលឃើញមានអ្នកដទៃមករាប់អាន ត្រកូលហ្នឹងដែរ គឺយើងទ្រាំមិនបាន ។

ឧទាហរណ៍ ថាយើងរាប់អានបុគ្គលណាម្នាក់ហើយ យើងមិនចង់ឱ្យបុគ្គលណាមួយ មករាប់អាននឹងបុគ្គលនឹងដែរទេ ។

៣. កំណាញ់លាភ គឺនៅពេលដែលឃើញមានអ្នកដទៃ បានលាភ គឺយើងអត់ធន់មិនបាន ។

៤. កំណាញ់ការសរសើរ គេធ្វើល្អហើយ និយាយល្អហើយ ពោលធម៌ត្រូវហើយ ប៉ុន្តែយើងមិនព្រមពោលសរសើរគេទេ នេះជាការកំណាញ់ហើយ ហើយពេលខ្លះយើងថែមទាំងមិនយល់ទៀតផង ។

-កំណាញ់សូម្បីតែចុចឡាយ ធម៌ សៃរធម៌ទៀតផង ឬក៏កំណាញ់នូវពាក្យថាសាធុ សាធុ សាធុ ទៀតផង ។

ឧទាហរណ៍ ថាឃើញអ្នកដទៃរៀនពូកែ ចេះដឹងធម៌ច្រើន នឹងមិនព្រមសរសើរគេទេ មិនព្រមសរសើរបញ្ញាគេទេ នេះជាការកំណាញ់ហើយ ។

-ព្រះអង្គទ្រង់ត្រាស់សម្តែងថា នៅពេលដែលយើងឃើញសព្រហ្មចារីយើងហ្នឹង ពូកែ ចេះដឹងធម៌ច្រើន មានបញ្ញា ព្រះអង្គឱ្យយើងធ្វើទុកក្នុងចិត្ត ថាសូមឱ្យយើងបានដូចជាបុគ្គលនោះដែរ មិនមែនទៅកំណាញ់ ទៅច្រណែនជាមួយគេទេ គឺត្រេកអរជាមួយនឹងគេដែលមានបញ្ញាច្រើន ។

-ព្រះអង្គសម្តែងថា ការសរសើរបុគ្គល ដែលគួរសរសើរ នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ។

-យើងត្រូវឃើញសេចក្តីកំណាញ់ ទៅតាមសេចក្តីពិត (ក្នុងសង្គមអ្នករៀនធម៌) បើបុគ្គលជាទីស្រឡាញ់ ជាទីចូលចិត្តរបស់យើង អារាធនា ពុទ្ធដីកា មក គឺយើងជ្រះថ្លា យើងសរសើរ យើងសាធុ ក៏ប៉ុន្តែបើបុគ្គលដែលមិនជាទីស្រឡាញ់ មិនជាទីចូលចិត្តរបស់យើង អារាធនា ពុទ្ធដីកា មក ក៏យើងមិនជ្រះថ្លា យើងមិនសរសើរ ពុទ្ធដីកា យើងមិនសាធុដែរ កន្លែងហ្នឹង គឺយើងកំណាញ់ហើយ ដូច្នេះប្រសិនបើយើងជាអ្នកមានសទ្ធានៅក្នុងព្រះពុទ្ធមែន ឱ្យតែជាព្រះពុទ្ធដីកា ពិតប្រាកដ ប្រាកដជាយើងសរសើរ ជ្រះថ្លា អនុមោទនា មិនចាំបាច់បុគ្គលនឹងជាទីស្រឡាញ់របស់យើងទើបយើងសរសើរទេ សូម្បីតែបុគ្គលនឹងមិនមែនជាទីស្រឡាញ់របស់យើង ក៏យើងសរសើរដែរ ឱ្យតែជាព្រះពុទ្ធដីកាពិត យើងត្រូវតែសរសើរ ជ្រះថ្លា អនុមោទនា សូម្បីតែបុគ្គលជាសត្រូវរបស់យើង សម្តែងក៏ដោយ ឱ្យតែជាព្រះពុទ្ធ

ដ៏ការពិត យើងត្រូវតែសរសើរ គឺសរសើរធម៌ព្រះអង្គ ក៏ប៉ុន្តែ មនុស្សភាគច្រើនភ្លេចកន្លែងហ្នឹង ។

-យើងត្រូវសង្កេតមើលចិត្តយើងរៀងៗខ្លួន សន្ទិដ្ឋិកោ ដឹងច្បាស់ដោយខ្លួនឯង ។

-ដូច្នេះយើងរកសេចក្តីកំណាញ់ ឱ្យឃើញ ដើម្បីរកឧបាយដើម្បីកម្ចាត់បង់នូវសេចក្តីកំណាញ់នឹងចោល មិនមែនយើងសិក្សាសន្ទនា រាវឱ្យឃើញទៅ គឺដើម្បីបង្អាប់បង្អោនអ្នកដទៃ ហើយលើកតម្កើងខ្លួនឯងទេ។

៥. កំណាញ់ធម៌ បានដល់ រមែងកំណាញ់បរិយត្តិធម៌ គឺមិនប្រាថ្នានឹងឱ្យដល់អ្នកដទៃ ។

-យើងគ្រប់គ្នាត្រូវសង្កេតកន្លែងហ្នឹង ដោយឋានៈ ៥ យ៉ាង ប្រាកដជាមាន បើមិនកំណាញ់អាវាស នៅមានកំណាញ់ត្រកូល បើមិនកំណាញ់ត្រកូល នៅមានកំណាញ់ការសរសើរជាដើម បើយើងអត់ឃើញ ព្រោះអវិជ្ជាមកបិទបាំងមិនឱ្យឃើញសេចក្តីពិត ។

# ១១. កុក្កុច្ចចេតសិក

-កុក្កុច្ចៈ ការក្តៅក្រហាយ ការស្តាយក្រោយ ។

## -បណ្តាធម៌ទាំងនោះ កុក្កុច្ចៈ តើដូចម្តេច?

ការសម្គាល់ថាគួរក្នុងរបស់មិនគួរ ការសម្គាល់ថាមិនគួរក្នុងរបស់គួរ ការសម្គាល់ថា ជាទោសក្នុងរបស់មិនមែនជាទោស ការសម្គាល់ថា មិនជាទោសក្នុងរបស់ជាទោស និងសេចក្តីរង្កៀស អាការរង្កៀស ភាពនៃចិត្តរង្កៀស ការក្តៅ ក្រហាយចិត្ត ការរសេមរសាមចិត្ត ណាដែលមានសភាពបែបនេះ នេះ ហៅថា កុក្កុច្ចៈ ។

-កុក្កុច្ចៈនេះ ជាកង្វល់ចិត្ត ដោយប្រារព្ធកម្ម គឺទុច្ចរិតដែលបានធ្វើហើយ និងសុចរិតដែលមិនទាន់បានធ្វើ ជាកម្មដែលបណ្ឌិតស្អប់ ។

-អ្នកមានវិប្បដិសារី គឺ កុក្កុច្ចៈនេះឯង ។

*-គប្បីឃើញ កុក្កុច្ចៈនេះ ដូចមនុស្សជាទាសៈ ដែលមិនអាចប្រព្រឹត្តតាមទំនើងចិត្តខ្លួន ។*

## -ការស្តាយក្រោយមាន ២ លក្ខណៈ គឺ៖

១. ការស្តាយក្រោយចំពោះ អំពើអាក្រក់ដែលធ្វើហើយ ។

២. ការស្តាយក្រោយចំពោះសេចក្តីល្អដែលមិនទាន់បានធ្វើ

ឧទាហរណ៍ ឪពុកម្តាយ កាលនៅរស់មិនកតញ្ញូជាមួយគាត់ទេ ដល់គាត់ស្លាប់ទៅតាំងស្តាយក្រោយ ។

-យើងទៅលួចគេដល់គេចាប់ដាក់គុកទៅ តាំងស្តាយក្រោយ។

ឧទាហរណ៍ មានប្រពន្ធល្អ មិនចេះថៃទេ នៅពេលប្រពន្ធលែងចោលទើបស្តាយក្រោយ។ ចាស់ហើយបានរៀនធម៌...។

## -លក្ខណាទិចតុក្កៈរបស់ កុក្កុច្ចៈ

១. បច្ឆានុតាបនលក្ខណំ មានការក្តៅក្រហាយចិត្តជាខាងក្រោយ ជាលក្ខណៈ ។

២. កតាកតានុសោចនរសំ មានការសោកសៅរឿយៗ ក្នុងអំពើបាបដែលធ្វើហើយ និងបុណ្យដែលមិនទាន់បានធ្វើ ជាកិច្ច ។

៣. វិប្បដិសារបច្ចុប្បដ្ឋានំ មានការស្តាយក្រោយ ជាអាការប្រាកដ ។

៤. កតាកតបទដ្ឋានំ មានបាបដែលធ្វើហើយ និងបុណ្យដែលមិនទាន់បានធ្វើ ជាហេតុជិត ។

# ១២. ថីនចេតសិក

-ថីនំ គឺសេចក្ដីធុញទ្រាន់ សេចក្ដីរួញរា ឈ្មោះថា ថីនៈ។

-ថីនៈ នេះគប្បីឃើញថា ជាធម៌បៀតបៀនចិត្ត ឱ្យថយចាក អារម្មណ៍ ឬជាសភាវធម៌គ្របសង្កត់ចិត្ត ធ្វើឱ្យចិត្តថយកម្លាំង។

ឧទាហរណ៍ តើយើងធ្លាប់ធុញទ្រាន់ធ្វើការងារទេ? ធុញទ្រាន់ធ្វើម្ហូបទេ? គេសម្ដែងធម៌យូរនោះយូរ...។

## -បណ្ដាធម៌ទាំងនោះ ថីនៈ តើដូចម្ដេច?

ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់នៅ ការសង្ងំនៅ សេចក្ដីរួញរា អាការរួញរា ភាពរួញរា សេចក្ដីធុញទ្រាន់ ការធុញទ្រាន់ ភាពធុញទ្រាន់ ណានៃចិត្ត នេះហៅថា ថីនៈ។

(បិដកលេខ ៧៩ នីវរណវគ្គ ទំព័រ ១៧៧ ដល់១៧៨)

## -លក្ខណាទិចតុក្កៈរបស់ ថីនៈ

១. អនុស្សាហានលក្ខណំ មានការមិនឧស្សាហ៍ (ឬមិនអង់អាច ឬខ្ជិល) ជាលក្ខណៈ។

-តើការខ្ជិលជាបុណ្យ ឬក៏ជាបាប? ជាបាប

-វាកើតនៅក្នុងលោភមូលចិត្ត ៤ ដួង ទោសមូលចិត្ត ១ ដួង។

ឧទាហរណ៍ ខែត្រជាក់ដេកស្រួល ខ្ជិលងើប ។

-ថីនៈ ដែលកើតនៅក្នុងទោសៈ ធុញទ្រាន់ ធុញថប់ ខ្ជិល ហើយ មួម៉ៅទៅទៀត ។

ឧទាហរណ៍ យើងទៅស្តាប់ធម៌ គេសម្តែងធម៌យូរអើយយូរ...។

២. វីរិយវិនោទនរស់ មានការកម្ចាត់បង់នូវការព្យាយាមជាកិច្ច។

-កាលណាថីនមិទ្ធៈ កើតឡើងហើយវីរិយៈខ្វាត ឬក៏មិនខ្វាត?

-យើងថាថីនមិទ្ធៈ គឺកម្ចាត់បង់នូវសេចក្តីព្យាយាម។

-ការខ្ជិល ចុះឧបមាថាចោរទៅលួចគេខំប្រឹង អត់ងងុយទាំង យប់ហើយទៅលួចគេមានព្យាយាម ឬអត់? មាន

-តើការព្យាយាមនោះជាកុសល ឬក៏ជាអកុសល? ជាអកុសល

-ការព្យាយាមនេះមិនមែនសុទ្ធតែកុសលតែម្យ៉ាងទេ ព្យាយាម ក្នុងកុសលក៏មាន ព្យាយាមក្នុងអកុសលក៏មាន។

-នៅក្នុង ថីនមិទ្ធៈ ដែលមានការកម្ចាត់បង់នូវវីរិយៈ នេះគឺវា កម្ចាត់បង់នូវវីរិយៈ ទាំងផ្នែកកុសល និងទាំងផ្នែកអកុសល។

ឧទាហរណ៍ ខ្ជិលទៅសូត្រធម៌ ខ្ជិលទៅរាំ ខ្ជិលទៅដើរលេង ខ្ជិល ទៅមើលគុន ខ្ជិលទៅជល់មាន់ ផឹកស្រា ទៅរកស្រី ខ្ជិលទៅ ជេរគេ (ខ្ជិលទៅនៅក្នុងអកុសលកម្មបថ ១០) វាកម្ចាត់បង់នូវ វីរិយៈ នៅក្នុងអកុសល។

ឧទាហរណ៍ ខ្ជិលទៅរៀនធម៌ ស្តាប់ធម៌ ធ្វើទាន ស្តាប់ធម៌ក៏ងោកទៀត (ខ្ជិលទៅនៅក្នុងកុសលកម្មបថ ១០) វាកម្ចាត់បង់នូវវិរិយៈ នៅក្នុងកុសល។

៣. សំសីទនបច្ចុប្បដ្ឋានំ មានការរួញរានៃចិត្តជាអាការប្រាកដ។ ការរួញរានៃចិត្ត មានន័យថា អត់ចង់ទៅទេ ។

ឧទាហរណ៍ គេបបួលទៅសូត្រធម៌ ទៅរាំ ទៅដើរលេង ទៅមើលគុន ទៅជល់មាន់ ទៅផឹកស្រា ទៅរកស្រី ទៅរៀនធម៌ ស្តាប់ធម៌ ធ្វើទាន អត់ចង់ទៅទេ មិនចង់ទៅទេ។

៤. អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ មាន អយោនិសោមនសិការៈ ក្នុងការមិនត្រេកអរ និងការរារែកជាដើម ជាហេតុជិត ។

ឧទាហរណ៍ ម្តាយឱ្យជួយធ្វើការងារអី ខ្ជិលណាស់ ដល់មានមិត្តភក្តិបបួលទៅផឹក និយាយពីលឿន។

# ១៣. មិទ្ធចេតសិក

-មិទ្ធៈ គឺ ការងោកងុយ ការងោកងក់ ការងងុយដេក ស្វាប ខ្ជិល ស្ពាក់ស្ពើរ នេះឈ្មោះថា មិទ្ធៈ ។

## -បណ្ដាធម៌ទាំងនោះ មិទ្ធៈ តើដូចម្ដេច?

ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់ ការស្រពោន ការងងឹតឈ្លប់ខាងក្នុង ការងោកងក់ ការសុបសៅ

អាការយឺតភ្លឹះៗ សេចក្ដីសុបសៅ អាការសុបសៅ ភាពសុបសៅ ណានៃកាយ នេះហៅថា មិទ្ធៈ ។

-អាការយឺតភ្លឹះៗ នៅពេលក្រោកពីដេកហ្នឹងរំកិលជណ្ដើរមួយកាំម្ដងៗហ្នឹង គឺអត់រហ័សរហួនទេ។

-សុបសៅ គឺការជ្រប់មុខចុះ ឬសំកុកសំកុលដោយកើតទុក្ខព្រួយចិត្តខ្លាំង ចេះតែសុបសៅងើបមុខមិនរួច កើតទុក្ខសុបសៅ ។

# -លក្ខណាទិចតុក្កៈរបស់ មិទ្ធៈ

១. អកម្មញ្ញតា លក្ខណំ មានភាពមិនគួរដល់ការងារ (មិនរហ័សរហួន) ជាលក្ខណៈ ។

ឧទាហរណ៍ ថាដើបឡើងនៅអែនអន ដើរអែនអន ពត់ខ្លួនអង្គុយសំកុកនៅកាំជណ្ដើរ ។

២. ឱនហានរសំ មានការបិទបាំងសហជាតិធម៌ ជាកិច្ច ។

ឧទាហរណ៍ ក៏ខ្ជិលហើយភ្នែកនឹងក៏បើកអត់រួចទេ ។

៣. លីនតាបច្ចុប្បដ្ឋានំ មានការរាថយ (រួញរា ងងុយងោកងក់) ជាអាការប្រាកដ ។

៤. អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ

មានអយោនិសោមនសិការៈ ក្នុងការមិនត្រេកអរ និងការរារែកជាដើម ជាហេតុជិត។

-ថីនៈ និង មិទ្ធៈ ចេតសិកទាំង ២ នេះ ប្រកបជាមួយនឹងចិត្តដែលជាសសង្ខារៈ ៥ ដួង គឺក្នុងលោភមូលចិត្ត ៤ដួង និងទោសមូលចិត្ត ១ ដួង។ ចេតសិកទាំង ២ នេះ កើតរួមគ្នាជានិច្ចដោយប្រៀប ថីនៈ ដូចអណ្ដាតភ្លើង មិទ្ធៈ ដូចពន្លឺ បើភ្លើងធំពន្លឺក៏ច្បាស់ បើភ្លើងតូច ពន្លឺក៏អន់ថយចុះ។

## ១៤. វិចិកិច្ឆាចេតសិក

-វិចិកិច្ឆា គឺសេចក្តីសង្ស័យ ។

-បណ្តាធម៌ទាំងនោះ វិចិកិច្ឆា តើដូចម្តេច?

-សេចក្តីសង្ស័យ ៨ យ៉ាងគឺ ៖

១. សេចក្តីសង្ស័យចំពោះព្រះពុទ្ធ (ពុទ្ធគុណទាំង ១០) ។

២. សេចក្តីសង្ស័យចំពោះព្រះធម៌ (ធម្មគុណទាំង ៦) ។

៣. សេចក្តីសង្ស័យចំពោះព្រះសង្ឃ (សង្ឃគុណទាំង ៩) ។

៤. សេចក្តីសង្ស័យចំពោះត្រៃសិក្ខា (សីល សមាធិ បញ្ញា) ។

៥. សេចក្តីសង្ស័យចំពោះ ខន្ធ ជាចំណែកខាងដើម ។

៦. សេចក្តីសង្ស័យចំពោះ ខន្ធ ជាចំណែកខាងចុង ។

៧. សេចក្តីសង្ស័យចំពោះ ខន្ធ ទាំងចំណែកខាងដើម ទាំងចំណែកខាងចុង ។

៨. សេចក្តីសង្ស័យចំពោះពួកធម៌ដែលកើតឡើងព្រោះអាស្រ័យ បច្ច័យនោះៗ (បដិច្ចសមុប្បាទធម៌) ។

និង សេចក្តីសង្ស័យ អាការសង្ស័យ ភាពនៃចិត្តសង្ស័យ

ការយល់ឆ្វេង ការសង្ស័យ ការបែកចិត្តជាចម្លាមពីរ ការបែកផ្លូវជាពីរ ការងឿងឆ្ងល់ ការប្រកាន់យកចំណែកដ៏ច្រើន ការសាញប្រដាញ ការប្រកាន់មិនដាច់ស្រេច ភាពនៃចិត្តរឹងរូស ការរសេមរសាមនៃចិត្តណា ដែលមានសភាព បែបនេះ

នេះ ហៅថា វិចិកិច្ឆា ។

ឧទាហរណ៍ ដូចជាជំនឿផ្តេសផ្តាស យើងនៅជាប់ មន្តអាគមផ្សំអាយូស បើមិនជឿកុំប្រមាថ វានៅក្រែងល បានសុខ សួរថាបានសុខ មែនឬ? គាត់អត់ច្បាស់ទេ។

## -លក្ខណាទិចតុក្កៈរបស់ វិចិកិច្ឆា

១. សំសយលក្ខណា មានការសង្ស័យ ជាលក្ខណៈ ។

២. កម្បនរសា មានការញាប់ញ័រ (ឃ្លេងឃ្លោង ស្ទាក់ស្ទើរ) ជាកិច្ច ។

៣. អវិនិច្ឆយបច្ចុប្បដ្ឋានា អនេកគាហ បច្ចុប្បដ្ឋានា វាមានការវិនិច្ឆ័យមិនដាច់ ជាអាការប្រាកដ ឬមានការកាន់យកចំណែកតែម្យ៉ាងមិនបាន ជាអាការប្រាកដ ។

៤. អយោនិសោមនសិការបទដ្ឋានា មានអយោនិសោមនសិការៈ ជាហេតុជិត ។

*-គប្បីឃើញថាវិចិកិច្ឆានេះ ជាធម្មជាតិធ្វើនូវសេចក្តីអន្តរាយ ដល់ការប្រតិបត្តិត្រឹមត្រូវតាមធម៌។*

## -សរុបអកុសលចេតសិក ១៤ មាន ៥ ន័យគឺ៖

១. មោចតុក្កចេតសិក ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ។

២. លោតិកចេតសិក ៣ គឺ លោភៈ ទិដ្ឋិ មានៈ។

៣. ទោចតុក្កចេតសិក ៤ គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ។

៤. ថីទុកចេតសិក ២ គឺ ថីនៈ មិទ្ធៈ។

៥. ឯកវិចិកិច្ឆាចេតសិក ១ គឺ វិចិកិច្ឆា។

## « ចប់អកុសលចេតសិក »

# -សោភណចេតសិក ២៥

## -សោភណចេតសិកចែកចេញជា ៤ ន័យ គឺ ៖

១. សោភណសាធារណចេតសិក ១៩ ២. វិរតិចេតសិក ៣

៣. អប្បមញ្ញាចេតសិក ២ ៤. បញ្ញាចេតសិក ១

## -អធិប្បាយ សោភណសាធារណចេតសិក ១៩

## ១. សទ្ធាចេតសិក

-សទ្ធា ប្រែថា ជឿជាក់ ទុកចិត្ត (ក្នុងកុសល សម្រាប់បុថុជ្ជន)។

-សទ្ធា ប្រែថា ការជឿមុតមាំ (សម្រាប់ព្រះអរិយៈ) ដោយសារមានបញ្ញា ដឹងច្បាស់ ជាក់ច្បាស់ ពាល់ត្រូវដោយខ្លួនឯង។

-សទ្ធា គឺការជឿចំពោះហេតុណាដែលគួរជឿដោយពិត ទើបចាត់ជាទ្រព្យដ៏ប្រសើរទៅបាន បើគ្រាន់តែជឿៗ ទៅមិនពិនិត្យរកហេតុ ផលផង ក៏មិនឱ្យឈ្មោះ សទ្ធា ទេ។

-សទ្ធា មានតែមួយ សទ្ធា អត់មាន ៤ ទេ ប៉ុន្តែ អារម្មណ៍របស់សទ្ធាមាន ៤ ។

## -អារម្មណ៍របស់សទ្ធាមាន ៤ យ៉ាងតាមន័យអភិធម្មគឺៈ

**១. កម្មស្សទ្ធា** ការជឿជាក់លើកម្ម ។

-កម្ម បានដល់ អភិសង្ខារ ៣ កម្មជវន ២៩ (អកុសលចិត្ត ១២ មហាកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤) ។ ដល់ពេលយើងឃើញថាកម្មមាន អ៊ីចឹងហើយ ផលប្រាកដ (មានហេតុ មានផល) ។

**២. វិបាកស្សទ្ធា** ការជឿជាក់លើផល ។

-ផល បានដល់ វិបាកចិត្ត ៣២ (អហេតុកចិត្ត ១៥ មហាវិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤)។

**៣. កម្មស្សកតាសទ្ធា** ការជឿជាក់ថាសត្វមានកម្មជារបស់ខ្លួន

-ឃើញថា កម្ម + វិបាក ទាំង ២ នេះចូលគ្នា (កម្ម + ផល)។

-ដល់យើងសង្កេតនិងពិសោធន៍បានក្នុងរឿង ៣ ខាងលើហើយក៏ជ្រះថ្លា ។

**៤. តថាគតពោធិស្សទ្ធា** ការជឿជាក់លើការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ។

## -អារម្មណ៍របស់សទ្ធាមាន ៤ យ៉ាងតាមន័យព្រះសូត្រគឺ៖

**១. កម្មសទ្ធា** ការជឿជាក់លើកម្ម ។

-គឺការជឿកម្ម ជាកុសល មានការឱ្យទាន រក្សាសីល ចម្រើនភាវនាជាដើម ជាហេតុនាំឱ្យបាននូវសេចក្តីសុខ។ ម្យ៉ាងទៀតគឺជឿកម្ម ជាអកុសល មានការប្រព្រឹត្តអាក្រក់ ដោយកាយ វាចា ចិត្ត គឺអកុសលកម្មបថ១០ មានការសម្លាប់សត្វជាដើម ជាហេតុនាំឱ្យកើតទុក្ខ ទោសក្នុងលោកនេះ និងលោកខាងមុខ ដោយជាក់ស្តែង។

-ការជឿចំពោះកម្មជាកុសល និងកម្មជាអកុសល ថាបានសុខ បានទុក្ខ អាស្រ័យមកពីកម្មប៉ុណ្ណោះនេះហៅថា កម្មសទ្ធា ។

**២. វិបាកសទ្ធា** ការជឿជាក់លើផល ។

-គឺជឿថាបុគ្គលណាដែលបានសេចក្តីសុខ ក៏សុទ្ធតែជាផលនៃបុណ្យ កុសល ដែលខ្លួនបានសន្សំទុកមកអំពីកាលមុន ហើយក្រោយមកវាចេញមុខឱ្យផល ទើបបានសុខ តាមលំដាប់ តាមថ្នាក់។ ម្យ៉ាងទៀត បុគ្គលណាដែលមានសេចក្តីវិនាសសាបសូន្យ កើតទុក្ខ ចាកផលប្រយោជន៍គ្រប់យ៉ាងក៏សុទ្ធតែជាផលនៃអកុសល ដែលខ្លួនបានសន្សំទុកមកអំពីកាលមុន ហើយក្រោយមកវាចេញមុខឱ្យផល ទើបទទួលរងនូវសេចក្តីទុក្ខ។

ការជឿជាក់លើផលនៃកម្ម ថាបានសុខ បានទុក្ខព្រោះ
អាស្រ័យមកពី ផលរបស់កម្មប៉ុណ្ណោះ នេះ ហៅថា

វិបាកសទ្ធា ។

## ៣. កម្មស្សកតាសទ្ធា ការជឿជាក់ថាសត្វមានកម្មជារបស់ខ្លួន

-ឃើញថា កម្ម + វិបាក ទាំង២នេះចូលគ្នា (កម្ម + ផល)។

-គឺជឿថាសព្វសត្វទាំងអស់ បានទទួលសេចក្ដីសុខ ទទួល
សេចក្ដីទុក្ខ ទាំងបច្ចុប្បន្ន ទាំងអនាគត ក៏សុទ្ធតែជាប់ទាក់ទង
ដោយកម្មទាំងអស់។

## -កុសលឱ្យផលផ្សេងៗគ្នា មាន ៧ យ៉ាងគឺ ៖

1. មានអាយុវែង ព្រោះមិនសម្លាប់សត្វ។
2. មិនមានរោគ ព្រោះមិនបៀតបៀនសត្វ។
3. មានសម្បុរល្អ ព្រោះមិនខឹងក្រោធ(មានមេត្តាច្រើន)។
4. មានសក្តិធំ ព្រោះមិនច្រណែន ឈ្នានីសគេ។
5. កើតក្នុងត្រកូលខ្ពង់ខ្ពស់ ព្រោះមិនរឹងត្អឹង មិនមើលងាយគេ មានការគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ។
6. មានភោគសម្បត្តិច្រើន ព្រោះឱ្យទាន មានបាយ ទឹក សំពត់ ស្លៀកដណ្ដប់ ទីជម្រកជាដើម។

7. មានបញ្ញាច្រើន ព្រោះបានសេពគប់សប្បុរស ឬក៏បានចូលទៅ រកសមណៈ ជាពហុស្សូត អ្នកស្ងប់រម្ងាប់ ស្តាប់ និងសិក្សាធម៌។

-ការជឿថាសត្វកើតឡើងសុទ្ធតែ ជាប់ជំពាក់ដោយកម្មទាំងអស់ សមដូចជា ពុទ្ធភាសិត សម្តែងថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមរតក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរឭក អាត្មាអញនឹងធ្វើនូវកម្មណាល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះពុំខានឡើយ។

ឧទាហរណ៍ យើងធ្លាប់ជេរគេ គេជេរវិញ យើងធ្លាប់សម្លាប់គេជាតិណាមួយ ពេលណាមួយ គេសម្លាប់យើងវិញ យើងធ្លាប់លួចគេ គេលួចវិញ។

## ៤. តថាគតពោធិសទ្ធា ការជឿជាក់លើការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ។

-គឺជឿជាក់ថា ព្រះអង្គត្រាស់ដឹងនូវធម៌ពិត ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ទាំង ៤ គឺ ទុក្ខសច្ចៈ ១ សមុទយសច្ចៈ ១ និរោធសច្ចៈ ១ មគ្គសច្ចៈ ១ ។

-នៅពេលយើងមានសទ្ធាជឿជាក់លើព្រះអង្គ ដល់ព្រះអង្គសម្ដែងថា នេះទុក្ខសច្ចៈ នេះជាហេតុដែលនាំឱ្យកើតទុក្ខ (សមុទយសច្ចៈ) នេះជាទីរលត់ទុក្ខ (និរោធសច្ចៈ ) នេះជាផ្លូវទៅកាន់ទីរលត់ទុក្ខ (មគ្គសច្ចៈ) យើងជឿជាក់លើព្រះអង្គ ទោះបីជាយើងមិនទាន់ពិសោធន៍បានក៏ដោយ បើយើងពិសោធន៍បានទៀត រឹតតែជឿមុតមាំ។

-ព្រះអង្គសម្ដែងថា កាយ វេទនា ចិត្ត ធម៌ មិនមែនជាខ្លួន យើងជឿតាមព្រះអង្គ បញ្ចក្ខន្ធ ជាទុក្ខ (មិនទៀង ជាទុក្ខ ជាអនត្តា) ។

## -លោកសន្និវាស មានប្រមាណ ៤ គឺ ៖

១. រូបប្បមាណោ អ្នកកាន់យករូបជាប្រមាណ ។

-អ្នកខ្លះជ្រះថ្លាជាមួយ រូបកាយព្រះអង្គស្អាតជាដើម ។

២. ឃោសប្បមាណោ អ្នកកាន់យកសំឡេងជាប្រមាណ ។

-អ្នកខ្លះជ្រះថ្លាជាមួយ សំឡេងព្រះសម្មាសម្ពុទ្ធ ជាដើម។

៣. លូខប្បមាណោ អ្នកកាន់យកភាពសៅហ្មងជាប្រមាណ ។

-គឺសំដៅលើលះបង់ទ្រព្យស្បង់ ចីវរចាស់ៗ ដូចព្រះសារីបុត្ត ព្រះកស្សបៈជាដើម ។

៤. ធម្មប្បមាណោ អ្នកកាន់យកធម៌ជាប្រមាណ ។

-គឺសំដៅលើបុគ្គលមានគុណធម៌ រួចហើយក៏ជ្រះថ្លា ។

# -លក្ខណាទិចតុក្កៈរបស់ សទ្ធា

១. សទ្ទហានលក្ខណា មានការជឿជាក់ ជាលក្ខណៈ

(សទ្ធារបស់បុថុជ្ជន) ។

-ឱកប្បនលក្ខណា វា ឬមានការជឿមុតមាំ ជាលក្ខណៈ

(សទ្ធារបស់ព្រះអរិយបុគ្គល) ។

-សម្បក្ខន្ទនលក្ខណា វា ឬមានការស្ទុះទៅ ជាលក្ខណៈ

(ក្លាហានស្ទុះទៅរកកុសល ស្ទុះចេញពីអកុសល) ។

២. សម្បសាទនរសា មានការធ្វើឱ្យផូរផង់(ជ្រះថ្លា) ជាកិច្ច

(ដូចកែវមណីធ្វើទឹកឱ្យថ្លា) ដូចជាសាច់ជូរអ៊ីចឹង ដាក់ចូលទៅ នៅក្នុងទឹក វាកាត់កករ ។

៣. អកាលុស្សិយបច្ចុប្បដ្ឋានា មានការមិនល្អក់កករ ជាអាការ ប្រាកដ។

៤. សទ្ធេយ្យវត្ថុបទដ្ឋានា មានវត្ថុជាទីតាំងនៃសេចក្ដីជឿជាក់ ជាហេតុជិត។

-(វត្ថុ ៤ គឺអារម្មណ៍របស់សទ្ធា ៤ យ៉ាង ខាងលើនេះឯង)។

-ខណៈពេលសទ្ធា កើតឡើង ចិត្តយើងនឹង គឺអត់ចេះកើតទុក្ខទេ ចិត្តនឹងថ្លាស្អាត។ បើយើងធ្វើអ្វីមួយ រួចហើយកើតទុក្ខនោះមិនមែនជាសទ្ធាឡើយ។

## -សទ្ធា មាន ២ យ៉ាងគឺ ៖

១. ចលសទ្ធា ជាសទ្ធានៅកម្រើក ឬញាប់ញ័រ (សទ្ធារបស់បុថុជ្ជន)។

-សទ្ធា ប្រែថា ជឿជាក់ ទុកចិត្ត (ក្នុងកុសល សម្រាប់បុថុជ្ជន) ។

២. អចលសទ្ធា ជាសទ្ធាមិនកម្រើក ឬតាំងមាំស៊ប់ មិនញាប់ញ័រ (សទ្ធារបស់ព្រះអរិយបុគ្គល) ។

-សទ្ធា ប្រែថា ការជឿមុតមាំ (សម្រាប់ព្រះអរិយៈ) ដោយសារមានបញ្ញា ដឹងច្បាស់ ជាក់ច្បាស់ ពាល់ត្រូវដោយខ្លួនឯង។

ឧទាហរណ៍ មានគេប្រាប់យើងថាកាហ្វេនេះឆ្ងាញ់ យើងក៏ជឿ តែយើងអត់បានផឹកទេ នេះហៅថា ចលសទ្ធា ដល់យើងជឿគេហើយ រួចបានផឹក រសជាតិយ៉ាងណាយើងក៏ដឹងច្បាស់

នេះ ហៅថា អចលសទ្ធា។

ឧទាហរណ៍ ថាយើងធ្លាប់មានសទ្ធាជ្រះថ្លាជាមួយភិក្ខុមួយអង្គ លោកបដិបត្តិ បានល្អ ដល់ក្រោយមក លោកធ្វើខុសវិន័យ ឬ លោកសឹកយកប្រពន្ធទៅខឹង លែងជ្រះថ្លាទៀតហើយ នេះជា (សទ្ធារបស់បុថុជ្ជន) ។

ឧទាហរណ៍ គេប្រាប់យើងថានៅក្នុងបន្ទប់ហ្នឹង មានមាសឬ មានលុយ ៣ ម៉ឺនដុល្លារ...។

ឧទាហរណ៍ បើយើងទៅរៀនមិនទុកចិត្តគ្រូទេ យើងរៀនអត់ចេះទេ ព្រោះយើងអត់មាននូវសទ្ធា...។

-ខ្ញុំក៏ដូចគ្នា បើគេអត់ទុកចិត្តលើខ្ញុំទេ(លក្ខណៈមើលងាយ) គេក៏មិនអាចយល់អត្ថន័យធម៌ពីខ្ញុំដែរ...។

ឧទាហរណ៍ ដូចជាគេថាធម៌ព្រះពុទ្ធល្អ...។ គេថាគ្រូគណិតហ្នឹងបង្រៀនល្អអីចឹង មុនដំបូងយើងត្រូវជឿជាក់ថាគ្រូនេះប្រហែលជាល្អ... នេះគឺជាសទ្ធា ...។

## -ចំណាំ

១. សទ្ធា ដូចជាដៃ

២. សទ្ធា ដូចជាទ្រព្យ

៣. សទ្ធា ដូចជាពូជ

១. សទ្ធា ដូចជាដៃ ក្នុងការកាន់យកនូវកុសលទាំងឡាយ។

-ដូចពុទ្ធវចនៈ ទ្វារនៃព្រះនិព្វាននោះ តថាគតបានបើកហើយ សត្វទាំងឡាយណា មានសោតប្រសាទ (ត្រចៀកនៅល្អ) ចូរបញ្ចេញនូវសទ្ធាមកចុះ។

(បិដកលេខ ៣០ សំយុត្តនិកាយ សគាថាវគ្គ ទំព័រ ៣០)

-មានន័យថា សម្មាទិដ្ឋិ ក្នុងអរិយសច្ចធម៌ប្រាកដក្នុងលោក ហើយមានទុក្ខអរិយសច្ចៈជាដើម។ កាលពីមុន គឺមិនមានអ្នកណាដឹងថារូបកាយ ចាប់ពីចុងសក់ដល់បាតជើងនេះជារូប មិនមែនជាបុរស ជាស្ត្រី មិនមែនជាសត្វ ជាបុគ្គល ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា នោះឡើយ គ្មានអ្នកណាដឹងទេ ទ្វារនៃព្រះនិព្វានត្រូវបានបិទ ដល់ពេលព្រះសម្មាសម្ពុទ្ធ ត្រាស់ដឹងក្នុងលោកទើបព្រះអង្គបានដឹង រួចបានបើកទ្វារនៃព្រះនិព្វាន ទើបព្រះអង្គត្រាស់ថា រូបមិនមែនជារបស់អ្នកទាំងឡាយទេ វេទនា សញ្ញាសង្ខារ វិញ្ញាណ មិនមែនជារបស់អ្នកទាំងឡាយទេ របស់ណាមិនមែនជារបស់អ្នកទាំងឡាយ អ្នកទាំងឡាយគួរលះបង់ចេញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជារបស់អ្នកទាំងឡាយទេ ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀងកាលណាវាមិនទៀង វាមានជាទុក្ខ កាលណាវាជាទុក្ខ វាជាអនត្តា បុគ្គលគប្បីមានប្រាជ្ញាដ៏ប្រពៃ ឃើញតាមសេចក្តី

ពិតដូច្នេះថា នុ៎ះមិនមែនអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនរបស់អញ។ អ្នកដែលស្តាប់ហើយបានអ្វី?

-គឺបាន សម្មាទិដ្ឋិនៅក្នុង កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិតនោះ គឺជាទ្វារនៃព្រះនិព្វាន។

-ទ្វារនៃព្រះនិព្វានបើកហើយ តើទ្វារនៃព្រះនិព្វានគឺជាអ្វី?

គឺបានដល់ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិ តើដូចម្តេច?

-គឺសម្មាទិដ្ឋិ យល់ត្រូវនៅក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ តាមសេចក្តីពិត ឬក៏យល់ត្រូវ នៅក្នុងសតិប្បដ្ឋាន ៤ យល់ត្រូវនៅក្នុង កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត នោះគឺជាទ្វារនៃព្រះនិព្វាន។

-កាលណាសម្មាទិដ្ឋិ កើតឡើងហើយ នាំឱ្យមានសម្មាសង្កប្បៈ នាំឱ្យមានសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាម សម្មាសតិ សម្មាសមាធិ។ ប៉ុន្តែសម្រាប់កុលបុត្រដែលប្រព្រឹត្តទៅនៅក្នុង សតិប្បដ្ឋាន ៤ បុគ្គលនោះ អាចសម្រេចបានអរិយមគ្គប្រកបដោយអង្គ ៥....។

-ព្រះអង្គបើកទ្វារនៃព្រះនិព្វាន គឺមាន ៤ កន្លែង នៅត្រង់កាយ ១ នៅត្រង់វេទនា ១ នៅត្រង់ចិត្ត ១ នៅត្រង់ធម៌ ១ ។

-សម្មាទិដ្ឋិ យល់ត្រូវនៅក្នុង កាយ តាមសេចក្តីពិត តួសម្មាទិដ្ឋិនេះឯងគឺជាទ្វារចេញពីកាយ ទៅកាន់ព្រះនិព្វាន។

-សម្មាទិដ្ឋិ យល់ត្រូវនៅក្នុង វេទនា តាមសេចក្តីពិត តួសម្មាទិដ្ឋិនេះឯងគឺជាទ្វារចេញពីវេទនា ទៅកាន់ព្រះនិព្វាន។

-សម្មាទិដ្ឋិ យល់ត្រូវនៅក្នុង ចិត្ត តាមសេចក្តីពិត តួសម្មាទិដ្ឋិនេះឯងគឺជាទ្វារចេញពីចិត្ត ទៅកាន់ព្រះនិព្វាន។

-សម្មាទិដ្ឋិ យល់ត្រូវនៅក្នុង ធម៌ តាមសេចក្តីពិត តួសម្មាទិដ្ឋិនេះឯងគឺជាទ្វារចេញពីធម៌ ទៅកាន់ព្រះនិព្វាន។

២. សទ្ធា ដូចជាទ្រព្យ ក្នុងការញ៉ាំងសម្បត្តិទាំងឡាយឱ្យដល់ព្រម ដូចព្រះបរមគ្រូទ្រង់ត្រាស់សម្តែងថា សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោក ។

ឧទាហរណ៍ ដូចជាពួកទេវតាផ្តាំគ្នាអឺចឹង...។

## -អានឡូវកយក្ស

-ក្នុងលោកនេះ អ្វីជាទ្រព្យដ៏ប្រសើររបស់បុរស?

-អ្វីដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្តីសុខមកឱ្យ?

-អ្វីមានរសឆ្ងាញ់ពិសាជាងរសទាំងឡាយ?

-បណ្ឌិតហៅជីវិតនៃអ្នករស់នៅបែបណា ថាជាជីវិតប្រសើរ?

## -ព្រះមានព្រះភាគត្រាស់ថា៖

-ក្នុងលោកនេះ សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរស។

-ធម៌ដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្ដីសុខមកឱ្យ។

-ពាក្យសច្ចៈ មានរសឆ្ងាញ់ពិសា ជាងរសទាំងឡាយ។

-បណ្ឌិត ហៅជីវិតនៃអ្នករស់នៅ ប្រកបដោយបញ្ញា ថាជាជីវិតប្រសើរ ។

## -អាឡវកយក្ស

-បុគ្គលឆ្លងអន្លង់បានដោយអ្វី? ឆ្លងមហាសមុទ្របានដោយអ្វី? កន្លងសេចក្ដីទុក្ខបានដោយអ្វី? បរិសុទ្ធបានដោយអ្វី?

## -ព្រះមានព្រះភាគត្រាស់ថា៖

សទ្ធាយ តរតិ ឱឃំ អប្បមាទេន អណ្ណវំ

វីរិយេន ទុក្ខមច្ចេតិ បញ្ញាយ បរិសុជ្ឈតិ ។

-បុគ្គលឆ្លងអន្លង់បានដោយ សទ្ធា ។

-ឆ្លងមហាសមុទ្របានដោយ សេចក្ដីមិនប្រមាទ ។

-កន្លងសេចក្ដីទុក្ខបានដោយ សេចក្ដីព្យាយាម ។

-បរិសុទ្ធបានដោយ បញ្ញា ។

(បិដកលេខ ៥៤ ទំព័រ ៦២)

# -អាឡវកយក្ស

-សួរថា អ្វីហ្ន៎ ជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ?

-អ្វីហ្ន៎ ដែលបុគ្គលសន្សំដោយប្រពៃហើយ តែងនាំសេចក្ដីសុខមកឱ្យ?

-របស់អ្វី ដែលមានរសឆ្ងាញ់ វិសេសជាងរសទាំងឡាយ?

-ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដូចម្ដេច ឈ្មោះថារស់នៅប្រសើរ?

# -ព្រះមានព្រះភាគត្រាស់ថា៖

-សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរសក្នុងលោកនេះ។

-សុចរិតធម៌ដែលបុគ្គលសន្សំដោយប្រពៃហើយ តែងនាំសេចក្ដីសុខមកឱ្យ។

-ពាក្យពិត ជារសឆ្ងាញ់វិសេសជាងរសទាំងឡាយ។

-ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដោយប្រាជ្ញា ឈ្មោះថារស់នៅប្រសើរ។

(បិដកលេខ ៣០ សំយុត្តនិកាយ សគាថវគ្គ ទំព័រ ២៣២)

# -អរិយទ្រព្យទាំង ៧ ប្រការ

-តើបុគ្គលដូចម្តេចឈ្មោះថា មិនទ័លក្រ?

គឺបុគ្គលដែលមានអរិយទ្រព្យទាំង ៧ ប្រការ នេះឯង ។

-ចុះហេតុអ្វី បានជាមានអរិយធម៌ទ្រព្យទាំង ៧ ប្រការនេះ មិនឈ្មោះថា ជាអ្នកមិនទ័លក្រ?

-ព្រះអង្គទ្រង់ត្រាស់សម្តែងថា បុគ្គលណា ទោះ ស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំងឡាយ ហៅ បុគ្គលនោះថា ជាអ្នកមិនទ័លក្រឡើយ ។

១. សទ្ធា អរិយសាវ័កក្នុងសាសនានេះ ជាអ្នកជឿជាក់ចំពោះការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ។

២. សីល អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសីល ៥ សីល ៨ ឬឧបោសថសីល ។

៣. ហិរិ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសេចក្តីអៀនខ្មាសបាប ខ្ពើមបាប ចំពោះសេចក្តីអាក្រក់ (មានកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត) ។

៤. ឱត្តប្បៈ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសេចក្តីខ្លាច ញញើត ឬ តក់ស្លុតចំពោះបាប ចំពោះសេចក្តីអាក្រក់ (មានកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត) ។

៥. សុតៈ អរិយសាវ័កក្នុងសាសនានេះ ជាពហុស្សុត ទ្រទ្រង់នូវចំណោះ សន្សំទុកនូវចំណោះ ធម៌ទាំងឡាយពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង រមែងប្រកាសព្រហ្មចរិយធម៌ ប្រកដដោយអត្ថនិងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយនោះដែលអរិយសាវ័កមានសភាពដូច្នេះ បានស្តាប់មកច្រើន បានទ្រទ្រង់ទុក បានចាំស្ទាត់រត់មាត់ បានចូលចិត្តជាច្បាស់លាស់ល្អ បានយល់ច្បាស់ដោយទិដ្ឋិ គឺបញ្ញា នេះហៅថា ទ្រព្យគឺសុតៈ ។

-ពីរោះបទដើម គឺនិយាយអំពីកម្មផល (មានទាន សីល ឋានសួគ៌ជាដើម) ។

-ពីរោះបទកណ្តាល គឺនិយាយអំពីសមាធិ (មានកម្មដ្ឋាន ៤០) ។

-ពីរោះបទចុង គឺការពោលអំពីសច្ចធម៌ (មានទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ មគ្គសច្ចៈ) និយាយអំពីព្រះនិព្វាន ជាទីរលត់ទៅនៃសេចក្តី ទុក្ខទាំងពួង ។

៦. ចាគៈ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានចិត្តប្រាស ចាកមន្ទិល គឺសេចក្តីកំណាញ់ បានបរិច្ចាគរួចហើយ មានដៃ លាងហើយ មានការត្រេកអរក្នុងការលះ ជាអ្នកគួរដល់ស្នូម ត្រេកអរក្នុងការចែករំលែកទាន រមែងនៅគ្រប់គ្រងផ្ទះ នេះ ហៅថា ទ្រព្យគឺ ចាគៈ ។

៧. បញ្ញា អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានបញ្ញា ជា គ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ នេះហៅថា ទ្រព្យគឺបញ្ញា ។

-តើអ្នកកើតទុក្ខ សួរថាជាអ្នកមានបញ្ញាឬក៏អត់បញ្ញា? គឺអត់ បញ្ញា ។

(បិដកលេខ ៤៧ សត្តកនិបាត ធនវគ្គ ទំព័រ៧~១១)

-បុគ្គលដែលក្រសម្បត្តិក្នុងលោកនេះ គឺជាការក្រល្មមទេប៉ុន្តែបុគ្គល ដែលមិនមានសទ្ធាគឺជាបុគ្គលដែលក្រក្នុងសង្សារវដ្ដ ។

៣. សទ្ធា ដូចជាពូជ ក្នុងការបានគ្រាប់កសិផលជា អមតៈ ព្រោះហេតុនោះព្រះបរមគ្រូទ្រង់ត្រាស់ថា សទ្ធាដូចជាគ្រាប់ ពូជ តបៈដូចជាទឹកភ្លៀង។

-តបៈ គឺការប្រព្រឹត្តធម៌ ការដុតកម្ដៅកិលេស (ការប្រព្រឹត្តធម៌ ដើម្បីកម្ចាត់បង់នូវអកុសល) ។

## -លក្ខណៈរបស់បុគ្គលមានសទ្ធា ៣ យ៉ាងគឺ ៖

១. ចង់ជួបអ្នកមានសីល (តើយើងចូលចិត្តចោរទេ? ចូលចិត្តមនុស្សអាក្រក់ទេ? ចូលចិត្តអ្នកអត់មានសីលទេ?

ឧទាហរណ៍ តើយើងចូលចិត្តទៅរកអ្នកតា ទៅរកគ្រូទាយ ទៅរកគ្រូស្រោចទឹក ចងអំបោះក្រហមឬទេ?

២. ប្រាថ្នាដើម្បីស្តាប់ធម៌ ឬក៏ចូលចិត្តស្តាប់ធម៌សប្បុរស (អត់ធុញទ្រាន់នឹងការស្តាប់ធម៌ទេ)។

៣. ជាអ្នកលះបង់នូវមច្ឆរិយៈ (សេចក្តីកំណាញ់) គឺចូលចិត្តធ្វើទាន (ចូលចិត្តផ្តល់សេចក្តីសុខឱ្យអ្នកដទៃ ទាំងទ្រព្យទាននិងធម្មទាន គឺអត់មានសេចក្តីកំណាញ់ធម៌ទេ)។

## -ពន្យល់អំពី សទ្ធាពិស្តារ

### -តាមន័យព្រះសូត្រ

**-ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយ តើដូចម្តេច?**

-ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគត ។ ព្រះដ៏មានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធបរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទូន្មាននូវបុរសដែលគួរទូ

ន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវ
អរិយសច្ចធម៌ លែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុ
ទាំងឡាយ នេះហៅថា សទ្ធិន្ទ្រិយ ។

(បិដកអដ្ឋកថាលេខ ២៤ វិភង្គសូត្រ ទំព័រ២១៣)

## -តាមន័យព្រះអភិធម្ម

-សទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច?

-ជំនឿ សេចក្តីជឿ សេចក្តីជឿស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា
សទ្ធិន្ទ្រិយ សទ្ធាពលៈណា ក្នុងសម័យនោះ នេះសទ្ធិន្ទ្រិយ កើត
មានក្នុងសម័យនោះ ។

(បិដកអដ្ឋកថាលេខ ៦៨ ទំព័រ៨២១)

-ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយ បណ្ឌិតគប្បីឃើញក្នុងទី
ដូចម្តេច? ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ។

-គេតែងពោលថា អង្គនៃសោតាបត្តិៗ ដូច្នេះ ម្នាលសារីបុត្ត ចុះ
អង្គនៃសោតាបត្តិ តើដូចម្តេច? គឺការសេពគប់សប្បុរស ១ ការ
ស្តាប់ធម៌សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា
១ សេចក្តីប្រតិបត្តិធម៌សមគួរដល់ធម៌ ១ ។

(បិដកលេខ ៣៩ សោតាបត្តិសំយុត្ត ទំព័រ៧៣)

-សោតាបត្តិយង្គៈ ៤ តើដូចម្តេច? គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ សេចក្តីប្រតិបត្តិធម៌សមគួរដល់ធម៌ ១ ។

(បិដកអដ្ឋកថា ២៤ ទំព័រ៧០៣-៧០៤)

# -អត្ថន័យថា សទ្ធា

-តើសេចក្តីជ្រះថ្លា នឹងបានដល់ធម៌អ្វី? គឺបានដល់សទ្ធា ។

-កាលដែលយើងពោលថាខ្ញុំមានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ មានសេចក្តីជ្រះថ្លាក្នុងព្រះធម៌ មានសេចក្តីជ្រះថ្លាក្នុង ព្រះសង្ឃ គឺបានដល់សទ្ធានេះឯង ។

-សទ្ធា គឺសេចក្តីជ្រះថ្លានេះ កើតឡើងអាស្រ័យ ការស្តាប់ព្រះសទ្ធម្ម គឺការស្តាប់ព្រះធម៌ ។

-សទ្ធា គឺជាគ្រឿងចងនូវកុសលធម៌ មិនមែនជាបុរស មិនមែនជាស្ត្រី ។

-អ្នកពោលធម៌ មានច្រើនដែរ តែអ្នកចូលដល់ធម៌មានតិច ។

-ការចេះធម៌ ចាំធម៌ ងាយជាង តែការដឹងធម៌ មិនងាយឡើយ។

-ធម៌ គឺសទ្ធានេះ បើគេត្រូវដឹង តើគេត្រូវដឹងដោយអ្វី? គឺគេត្រូវដឹងដោយបញ្ញា មិនមែនដឹងបានដោយភ្នែកធម្មតាទេ គឺគេត្រូវដឹងដោយភ្នែកបញ្ញា ។

ឧទាហរណ៍ ថាប្រសិនបើរូប មានពណ៌ស ពណ៌ខៀវ ក្រហម លឿងជាដើម គេត្រូវដឹងបាន ដោយភ្នែក...។

ឧទាហរណ៍ ដូចជាគ្រូពេទ្យ គាត់ដឹងថ្នាំហ្នឹងមិនមែនដឹងដោយភ្នែកទេ គឺគាត់ដឹងដោយវិជ្ជាពេទ្យរបស់គាត់...។

-តើយើងមានបញ្ញា ដឹងពីសទ្ធាដែលមាននៅខាងក្នុងខ្លួនយើងដែរឬអត់?

-សទ្ធា គឺសេចក្ដីជ្រះថ្លានេះ កើតឡើងអាស្រ័យ ការស្ដាប់ព្រះសទ្ធម្ម គឺការស្ដាប់ព្រះធម៌ ។

## -សទ្ធា បរិសុទ្ធដោយអាការ ប៉ុន្មានយ៉ាង?

## -សទ្ធា បរិសុទ្ធដោយអាការ ៣ យ៉ាង ៖

១. វៀរចាកបុគ្គលដែលមិនមានសទ្ធា

២. សេពគប់បុគ្គលដែលមានសទ្ធា

៣. ពិចារណានូវព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ។

(បិដកអដ្ឋកថា ៣៥ ទំព័រ៨៩៥)

-តើដើម្បីឱ្យយើងដឹងថាយើងជាអ្នកមានសទ្ធា ឬក៏ជាអ្នកមិនមានសទ្ធាទេ តើយើងគួរសង្កេតដូចម្ដេច? បុគ្គលជាអ្នកដែលមានសទ្ធា តើមានលក្ខណៈសម្គាល់ប៉ុន្មានយ៉ាង?

-ព្រះពុទ្ធដីកា កុលបុត្រដែលប្រកបដោយធម៌ ៣ ប្រការ ហៅថា ជាអ្នកដែលមានសទ្ធា ។

-ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធាជ្រះថ្លា បណ្ឌិតត្រូវដឹងដោយហេតុ ៣ យ៉ាង ។ ហេតុ ៣ យ៉ាង គឺអ្វីខ្លះ?

១. គឺបុគ្គលនោះ ចង់ឃើញបុគ្គលអ្នកមានសីល

២. ជាអ្នកចង់ស្តាប់នូវព្រះសទ្ធម្ម

៣. ជាអ្នកមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ មានការលះរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះ ជាអ្នកគួរដល់ស្មូម ជាអ្នកត្រេកអរក្នុងការឱ្យ និងការចែករំលែក ។

-ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធាជ្រះថ្លា បណ្ឌិតត្រូវដឹងដោយហេតុ ៣ យ៉ាងនេះ ។

(បិដកលេខ ៤១ តិកនិបាត ចូឡវគ្គ ទំព័រ១២០)

-នៅពេលដែលយើងមានសទ្ធានៅក្នុងព្រះរតនត្រ័យ ឈ្មោះថាដាំពូជដែលមានផ្លែ ជាព្រះនិព្វាន ដែលសទ្ធា ដូចជាគ្រាប់ពូជ សទ្ធា មានឫសគឺ សីល ការស្តាប់ព្រះធម៌ គឺជាការស្រោចទឹកដាក់ជី សុចរិត ៣ តាមផ្លូវកាយ វាចា ផ្លូវចិត្ត ដូចជាការជ្រោយដីដកស្មៅ....នឹងនូវសច្ចៈញាណ គឺព្រះនិព្វាន ។

-ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងកុលបុត្រ អ្នកមានសទ្ធានេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង ដូចម្តេចខ្លះ?

-ម្នាលភិក្ខុទាំងឡាយ ពួកសប្បុរស ដែលមានចិត្តស្ងប់ក្នុងលោក សប្បុរសទាំងនោះ កាលអនុគ្រោះ រមែងអនុគ្រោះតែបុគ្គល ដែលមានសទ្ធាជាដំបូង មិនអនុគ្រោះ បុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កាលចូលទៅជិត រមែងចូលទៅជិតតែបុគ្គលមានសទ្ធាជាដំបូង មិនចូលទៅជិតបុគ្គលមិនមានសទ្ធា ដូច្នោះទេ ១ កាលទទួល រមែងទទួលតែបុគ្គលមានសទ្ធាជាដំបូង មិនទទួលបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កាលសម្តែងធម៌ ក៏សម្តែងចំពោះតែបុគ្គលមានសទ្ធាជាដំបូង មិនសម្តែងធម៌ចំពោះបុគ្គលមិនមានសទ្ធាដូច្នោះទេ ១ កុលបុត្រមានសទ្ធាលុះបែកធ្លាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ១ ។

## -អានិសង្សរបស់សទ្ធា ៥ យ៉ាង៖

១. ពួកសប្បុរស មានចិត្តស្ងប់រមែងអនុគ្រោះមុន

២. ពួកសប្បុរស រមែងចូលទៅជិតមុន

៣. ពួកសប្បុរស រមែងទៅទទួលទានមុន

៤. ពួកសប្បុរស រមែងសម្តែងធម៌ឱ្យមុន

## ៥. កុលបុត្រមានសទ្ធា លុះបែកធ្លាយរាងកាយ រមែងទៅកាន់សុគតិសួគ៌ ទេវលោក

(បិដកលេខ ៤៤ បញ្ចកនិបាត សុមនវគ្គ ទំព័រ៨៣-៨៤)

## -អដ្ឋកថា ពន្យល់អំពីសទ្ធា

-សទ្ធា មានការជ្រះថ្លា ជាលក្ខណៈ ។

-សទ្ធា កាលកើតឡើងរមែងគ្រប់សង្កត់នីវរណៈទាំងឡាយ រមែងឱ្យកិលេសស្ងប់ រមែងឱ្យចិត្តផូរផង់ រមែងធ្វើចិត្តមិនឱ្យល្អក់ ដូចកែវមណីរបស់ស្តេចចក្កពត្តិ ដែលធ្វើទឹកឱ្យថ្លាស្អាត ។

-សទ្ធា មានការស្ទុះទៅ ជាលក្ខណៈ ។

-មេទ័ពចាត់ដាវដែលសំលៀងល្អហើយ ពោលថា ពួកលោកចូរមកខាងក្រោយយើង កុំខ្លាចឡើយ ហើយចុះទៅក្នុងស្ទឹង ការពារក្រពើជាដើម ដែលមកហើយ ធ្វើសួស្តីដល់ពួកមនុស្សទាំងឡាយ យ៉ាងណា កាលបុគ្គលឱ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ចម្រើនភាវនា សទ្ធារមែងជាប្រធាន ជាភារៈនាំមុនទៅ ។

(បិដកអដ្ឋកថា ៦៤ ទំព័រ៣៧៧)

# -ព្រះពុទ្ធដីកា

## -បុគ្គលជ្រះថ្លា ក្នុងព្រះសាស្តា មានសភាពដូចម្តេច?

**-សេចក្តីជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធ តើជ្រះថ្លាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន?**

-ម្នាលនាងចុន្ទី រាប់តាំងពីពួកសត្វឥតជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី ឥតរូបក្តី មានសញ្ញាក្តី ឥតសញ្ញាក្តី មិនមែនជាមិនមានសញ្ញាក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាង ពួកសត្វទាំងនោះ។

-ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លា ក្នុងព្រះពុទ្ធ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គល ជាអ្នកជ្រះថ្លាក្នុង បុគ្គលដ៏ប្រសើរ។

**-សេចក្តីជ្រះថ្លាក្នុងព្រះធម៌ តើជ្រះថ្លាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន?**

-ម្នាលនាងចុន្ទី ពួកសង្ខតធម៌ក្តី អសង្ខតធម៌ក្តី ទាំងប៉ុន្មាន វិរាគធម៌ គឺញុំាងសេចក្តីស្រវឹងឱ្យទ្រុឌទ្រោម នាំបង់នូវសេចក្តីស្រេកឃ្លាន គាស់រំលើងនូវសេចក្តីអាល័យ ផ្តាច់បង់នូវវដ្តៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់ទុក្ខ មិនមានគ្រឿងចាក់ដោត ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ។

-ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងវិរាគធម៌ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងធម៌ដ៏ប្រសើរផលដ៏ប្រសើរមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លា ក្នុងធម៌ដ៏ប្រសើរ ។

**-សេចក្តីជ្រះថ្លាក្នុងព្រះសង្ឃ តើជ្រះថ្លាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន?**

-ម្នាលនាងចុន្ទី សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃសាវ័ករបស់តថាគត បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុគ្គលមាន ៨ សង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគជាអ្នកទទួលចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះ ហើយនាំមកបូជា គួរទទួលអាគន្តុកទាន គួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកប្រាកដជាប្រសើរ ជាងសង្ឃឬគណៈទាំងនោះ ។

-ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លា ក្នុងព្រះសង្ឃ ពួកបុគ្គលនោះ ឈ្មោះថាជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ផលដ៏ប្រសើរមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ។

**-ជាអ្នកមានសីល ដែលប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន?**

-ម្នាលនាងចុន្ទី សីលដែលព្រះអរិយៈសរសើរទាំងអម្បាលម៉ាន ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលអ្នកជា ដែលវិញ្ញូជនសរសើរហើយ មិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ប្រព្រឹត្តទៅដើម្បីសមាធិ នេះប្រាកដជាប្រសើរ ជាងសីលទាំងនោះ ។

-ម្នាលនាងចុន្ទី ពួកបុគ្គលណា ជាអ្នកបំពេញក្នុងពួកសីល ដែលព្រះអរិយៈសរសើរហើយ ពួកបុគ្គលនោះ ពួកបុគ្គលទាំងនោះ ឈ្មោះថាបានបំពេញ ក្នុងសីលដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកបំពេញ ក្នុងសីលដ៏ប្រសើរ ។

(បិដកលេខ ៤៤ បញ្ចកនិបាត សុមនវគ្គ ទំព័រ៦៧~៧១)

# ២. សតិចេតសិក

-សម្មាសតិ អង្គធម៌ បានដល់ សតិចេតសិក ។

## -សតិ តើដូចម្តេច?

-ការរឭក សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង នេះ ហៅថា សតិ។

-សតិ ប្រែថា ការរឭក សេចក្តីរឭក ស្មារតី ។

-សតិ ជាគ្រឿងកំណត់ នូវ(កាយ វេទនា ចិត្ត ធម៌) ។

-នៅក្នុងសតិសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា៖

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវជាអ្នកមានស្មារតី ជាអ្នកដឹងខ្លួន នេះជាអនុសាសនី គឺជាពាក្យប្រៀនប្រដៅរបស់តថាគតចំពោះអ្នកទាំងឡាយ ។

-ស្មារតី អង្គធម៌ សតិចេតសិក។

-ដឹងខ្លួន គឺសម្បជញ្ញៈ អង្គធម៌ បញ្ញាចេតសិក។

-សតិមា គឺអ្នកមានស្មារតី គឺពោលទៅលើបុគ្គលបញ្ញត្តិ ដល់ពេល សតិ (ស្មារតី) គឺបានដល់ សតិចេតសិក ជាបរមត្ថ។

-អនុសាសនី គឺជាពាក្យប្រៀនប្រដៅរឿយៗ ទូន្មានហើយទូន្មានទៀត។ ទូន្មានម្តង ហៅថា ឱវាទ ។

-សម្បជានោ គឺអ្នកសេចក្តីដឹងខ្លួន គឺពោលទៅលើបុគ្គលបញ្ញត្តិដល់ពេល សម្បជញ្ញៈ (សេចក្តីដឹងខ្លួន) គឺបានដល់ បញ្ញាចេតសិក ជាបរមត្ថ ។

## -សិក្សា បទថា សតិ

**-ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី តើដូចម្តេច?**

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ១ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ពិចារណានូវចិត្តក្នុងចិត្តទាំងឡាយ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី យ៉ាងនេះឯង ។

## -ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួន តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងការដើរទៅមុខ និងថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលក្រឡេកមើលទៅខាងមុខ និងក្រឡេកមើលទិសផ្សេងៗ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលបត់ដៃជើង និងលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលទ្រទ្រង់នូវសំពត់សង្ឃាដិ បាត្រ និងចីវរ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលបរិភោគភោជន ផឹកទឹក ទំពាស៊ី (ខាទនីយវត្ថុ) ជញ្ជាប់រស ធ្វើនូវសេចក្តីដឹងខ្លួនក្នុងការបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលដើរ ឈរ អង្គុយ លក់ ភ្ញាក់ឡើង និយាយ និងនៅស្ងៀម ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួន យ៉ាងនេះឯង ។

-អនុសាសនី គឺជាពាក្យប្រៀនប្រដៅរឿយៗ ទូន្មានហើយទូន្មានទៀត។ ទូន្មានម្តង ហៅថា ឱវាទ ។

(បិដកអដ្ឋកថាលេខ ២៤ សតិសូត្រទី ២ ទំព័រ១៣~៤៥)

## -ពាក្យឧបមារបស់សតិ មាន ៤ យ៉ាង ៖

### ១. សតិ ប្រៀបដូចជាខ្សែ

-ចិត្តដូចជាគោ សតិដូចជាខ្សែ បង្គោលដូចជាអារម្មណ៍ (កម្មដ្ឋាន ៤០) ណាមួយឬក៏សតិប្បដ្ឋាន ៤ គឺ អារម្មណ៍ទាំង ៤ ដែលគួរពុក មាន (កាយ វេទនា ចិត្ត ធម៌) ។

-ចិត្តដូចជាគោ សតិដូចជាខ្សែ បង្គោលដូចជាអារម្មណ៍ ណាមួយ គឺ ចិត្ត ដែលយើងផ្តោត គោកាលណាអត់មានចំណង អត់មានបង្គោល សម្រាប់ចងវា វាចេះតែដើរស៊ីដំណាំគេផ្តេសផ្តាស ចិត្តហ្នឹងក៏ដូចគ្នា កាលណាមិនមានសតិ សម្បជញ្ញៈទេ វាតែងតែហូរទៅរក រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ (រឿងដែលចិត្តគិត ចង់ដឹងវាច្រើន)។

-សតិដូចជាខ្សែ ខ្សល់ដង្ហើមដូចជាបង្គោល ចំណែកឯចិត្តដូចជាសត្វស្វា មានន័យថា សតិ នេះឯងញ៉ាំងចិត្តឱ្យប្រព្រឹត្តទៅ

មកជាប់នឹងអារម្មណ៍ គឺខ្យល់ដង្ហើមវែង ខ្យល់ដង្ហើមខ្លី ដែលអារម្មណ៍ហ្នឹងដូចជាបង្គោល ចិត្តកាចដូចជាស្វាអ៊ីចឹង វាមិនអាចផ្តាច់ខ្សែ សតិ ដើម្បីទៅគិតនៅក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលខ្លួនធ្លាប់បាននៃបនិត្យមក វាផ្តាច់ខ្សែគឺ សតិ អត់បាន តើចិត្តហ្នឹង ត្រូវស្ងប់ ឬក៏មិនស្ងប់? ត្រូវស្ងប់

## ២. សតិ ប្រៀបដូចជានាយយាមទ្វារ

-អ្នកយាមទ្វារ ជាអ្នកមានបញ្ញា អ្នកស្គាល់បានឱ្យចូល អ្នកមិនស្គាល់មិនឱ្យចូលទេ រីឯសតិដូចជាអ្នកយាមទ្វារ ទាំង៦ យាម (ទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត)។

## ៣. សតិ ប្រៀបដូចជាហេរញ្ញិក

-អ្នករក្សាប្រាក់ អ្នកទុកប្រាក់...។

## ៤. សតិ ប្រៀបដូចជាចង្កូតទូក

ឧទាហរណ៍ ដូចជាចង្កូតទូក...។ ដូចជាឡានជាប់ផុង...។

-សតិ ដូចគ្នានឹង មនសិការៈ ដោយអាការប្រាកដ គឺសតិ ទល់នឹងអារម្មណ៍ដោយអំណាចការមិនភ្លេច (វព្ញក) រីឯ មនសិការៈ ទល់នឹងអារម្មណ៍ដោយ ការធ្វើទុក ការចងទុក ការប្រកប។

-សតិ ដូចជាដៃទៅចាប់កួរស្រូវ (ចាប់បានមិនរបូតទេ) ។

-រីឯបញ្ញា ដូចជា មុខកណ្ដៀវដែលកាត់ផ្ដាច់ ។

-ចំណាំ ក្នុងមិលិន្ទបញ្ហាថា សតិ មានការចាប់យក ជាលក្ខណៈ គឺដឹងនូវប្រយោជន៍ និងមិនប្រយោជន៍។

-បិដកលេខ ៣៧ ពោលថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលដល់សតិថា ជាធម៌ចាំបាច់ក្នុងកិច្ចទាំងពួង ។

-សតិ រឭកដឹងអំពីពោធិបក្ខិយធម៌ ៣៧ប្រការតាមសេចក្តីពិត។

-សតិ មានការពិចារណាការសម្រេចនៃធម៌ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ។

-សតិ ដឹងថា ធម៌មានកាយទុច្ចរិតជាដើម មិនជាប្រយោជន៍ រមែងកាត់បន្ថយនូវធម៌ដែលមិនជាប្រយោជន៍នោះ។

-សតិ ដឹងថា ធម៌មានកាយសុចរិតជាដើម ជាប្រយោជន៍ រមែងចម្រើននូវធម៌ដែលជាប្រយោជន៍នោះ។

-សតិ ប្រៀបដូចជានាយបរិនាយកកែវរបស់ស្តេចចក្រពត្តិ ដឹងនូវវត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលជាប្រយោជន៍ រមែងនាំយកវត្ថុមិនជាប្រយោជន៍ចេញទៅ និងបង្អោននូវវត្ថុដែលជាប្រយោជន៍ចូលមក។

-សតិ រមែងរក្សាចិត្តចេញពីអកុសលធម៌ និងញុំាងចិត្តឱ្យប្រកបដោយកុសលធម៌ ប្រៀបដូចមហាអាមាត្យអ្នកធ្វើកិច្ចរបស់ព្រះរាជាឱ្យសម្រេច សមដូចព្រះពុទ្ធវចនៈថា ៖

« ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវសតិថាមានឧបការច្រើនក្នុងទីទាំងពួង »។ សតិ គឺជាឈ្មោះនៃអប្បមាទធម៌ ។

# -លក្ខណាទិចតុក្កៈរបស់ សតិ

១. អបិលាបនលក្ខណា មានការរឰកបាន មិនរវើរវាយ ជាលក្ខណៈ ។

២. អសម្មោសរសា មានការមិនវង្វេងភ្លេច ជាកិច្ច ។

៣. វិសយាភិមុខភាវបច្ចុប្បដ្ឋានា មានការប្រាថ្នាចំពោះ អារម្មណ៍(ឬមានការរក្សាទុកនូវអារម្មណ៍មិនឱ្យ ចេញអំពីចិត្ត) ជាអាការប្រាកដ ។

៤. ថិរសញ្ញាបទដ្ឋានា មានការចងចាំប្រាកដ  ជាហេតុជិត ។

កាយាទិសតិបទដ្ឋានា វា ឬថាមានសតិប្បដ្ឋាន ដូចជា កាយានុបស្សនាសតិប្បដ្ឋានជាដើម ជាហេតុជិត ។

-សេចក្ដីមិនប្រមាទ(១ ជាផ្លូវនៃសេចក្ដីមិនស្លាប់(២ សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ(៣ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។

(១) បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះ ស្មារតី ដែលបានតាំងប្រុងជានិច្ច ។

(២) ពាក្យថាមិនស្លាប់នេះ ជាឈ្មោះ ព្រះនិព្វាន ព្រោះព្រះនិព្វាន មិនមានចាស់ មិនមានស្លាប់ ។

(៣) បានដល់ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការ លះបង់ស្មារតី ។

(បិដកលេខ ៥២ អប្បមាទវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធព្រះនាងសាមាវតី)

-បណ្ឌិតអ្នកមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿនដែលទៅចោល សេះដែលមានកម្លាំងទន់ទាបដូច្នោះឯង។

(បិដកលេខ ៥២ អប្បមាទវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធចំពោះភិក្ខុ ២អង្គជាសម្លាញ់នឹងគ្នា)

-ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទឬ ឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថាឋិតនៅក្នុងទីជិតនៃព្រះនិព្វាន។

(បិដកលេខ ៥២ អប្បមាទវគ្គ ព្រះសម្មាសម្ពុទ្ធប្រារព្ធព្រះនិគមវាតិស្សត្ថេរ)

# ៣. ហិរិចេតសិក

-ហិរិ ព្រោះអត្ថថា ខ្មាសបាប ខ្ពើមបាប រង្កៀសចំពោះបាប (បាបខ្លួនឯង) ។

-ហិរិ ព្រោះអត្ថថា ខ្មាស គឺ រង្កៀសចំពោះទុច្ចរិត ៣ មានកាយទុច្ចរិតជាដើម( អកុសលកម្មបថ ១០) ។

-ហិរិ ការខ្មាស ឬខ្ពើមអំពើបាបរបស់ខ្លួន ប្រៀបដូចជាបុគ្គលខ្ពើមលាមកជាដើម។

## -លក្ខណាទិចតុក្កៈរបស់ ហិរិ

១. បាបតោ ជិគុច្ឆនលក្ខណា មានការរង្កៀស (ខ្ពើម) ចំពោះបាបជាលក្ខណៈ។

២. បាបានំ អករណរសា មានការមិនធ្វើបាប ជាកិច្ច ។ (គឺមិនធ្វើអកុសលកម្មបថ ១០) ។

៣. បាបតោ អសង្កោចនបច្ចុប្បដ្ឋានា មានការថយចាកបាប ជាអាការប្រាកដ (គឺមិនធ្វើតែម្តង មិនសម្លាប់ មិនជេរជាដើម) ។

៤. អត្តគារវបទដ្ឋានំ មានការគោរពខ្លួនឯង គឺខ្មាសដល់ចិត្តខ្លួនឯង ជាហេតុជិត ។

-ខ្លាសបាប ខ្ពើមបាប ទាំងនៅចំពោះមុខគេ និងក្រោយខ្នងគេ។ ឧទាហរណ៍ មិនមែនខាងមុខគេធ្វើល្អ តែនៅខាងក្រោយខ្នងគេធ្វើអាក្រក់ទេ ដូចជាពុករលួយ កាប់ព្រៃឈើ លក់គ្រឿងញៀនជាដើម។

ឧទាហរណ៍ ថាយើងរកស៊ីជាមួយមិត្តភក្តិហ្នឹង យើងមិនកេងប្រវ័ញ្ចលើគេទេ។

ឧទាហរណ៍ អ្នកខ្លះនៅមុខយើងនិយាយឱ្យផ្អែម ដល់នៅក្រោយខ្នងយើងនិយាយដើមយើងឡើងកិល។ សូម្បីតែខ្ញុំបាទក៏ដូចគ្នា ម៉េចម៉ាជួយប្រាប់គ្នាផង...។

-បើមានមនុស្សណាម្នាក់និយាយដើមគេ យើងកុំថាកុំនិយាយដើមគេវាមិនល្អទេ មិនមែនជាឧបាយទេ វិធីសាស្ត្រដើម្បីផ្អាកបុគ្គលដែលនិយាយដើមគេ យើងត្រូវប្តូរប្រធានបទ សួរគាត់សំណួរផ្សេងៗឬក៏និយាយថា សត្វមានកម្មជារបស់ខ្លួន អ្នកណាធ្វើអាក្រក់នឹងទទួលផលអាក្រក់មកវិញ។

ឧទាហរណ៍ យើងធ្វើអាក្រក់ (លួចគេ សម្លាប់គេ )ទៅ គឺសម្លាប់ខ្លួនឯង ធ្វើបាបខ្លួនឯង។ ដូចជាការផឹកស្រាទៅ វាឈឺ វាធ្វើបាបខ្លួនឯង ធ្វើអាក្រក់ទៅវាឱ្យផលជាទុក្ខ វាធ្វើបាបខ្លួនឯង វាមិនគោរពខ្លួនឯង។

-ហិរិ ការខ្មាសបាបនេះ វាមានលក្ខណៈនៅខាងក្នុង ។

ឧទាហរណ៍ ព្រះបរមពោធិសត្វ ទៅរៀនវិជ្ជានៅ នគរតក្កសិលា គ្រូមានកូនក្រមុំមួយ...បម្រាមលួចកុំឱ្យមានអ្នកដឹង...។

-បើអ្នកប្រព្រឹត្ត អកុសលកម្មបថ ១០ ឈ្មោះថា មិនគោរពខ្លួនឯង។

-បើអ្នកប្រព្រឹត្ត កុសលកម្មបថ ១០ ឈ្មោះថា គោរពខ្លួនឯង ។

## ៤. ឱត្តប្បចេតសិក

-ឱត្តប្បៈ ព្រោះអត្ថថា តក់ស្លុត ខ្លាច ឬ ញញើតចំពោះបាប (បាបខ្លួនឯង) ។

-ឱត្តប្បៈ ការខ្លាចបាប ចំពោះទុច្ចរិត ៣ មានកាយទុច្ចរិតជាដើម (អកុសលកម្មបថ ១០) ។

ឧទាហរណ៍ ដូចមនុស្សមិនហ៊ានលូកភ្លើង ព្រោះខ្លាចរលាកភ្លើងដូច្នេះឯង។

ឧទាហរណ៍ ដូចជាមនុស្សមិនហ៊ានដើរជាន់អំបែងកែវ ព្រោះខ្លាចមុតជើង។

-ប្រៀបដូចបុគ្គលមិនហ៊ានចាប់ កាន់ដុំដែកដែលគេដុតឱ្យក្តៅ។

-ឱត្តប្បៈ ការខ្លាចបាបនេះ វាមានលក្ខណៈនៅខាងក្រៅ ។

ឧទាហរណ៍ ថាផឹកស្រាទៅ ខ្លាចឆាប់ស្លាប់ ។

-យើងប្រព្រឹត្តខុស ទៅសម្លាប់គេ លួចគេ... ខ្លាចគេវៃ ខ្លាចមានទោសគេចាប់ដាក់គុក ឬខ្លាចធ្លាក់នរក...។

## -លក្ខណាទិចតុក្កៈរបស់ ឱត្តប្បៈ

១. ឧត្តាសលក្ខណំ មានការតក់ស្លុតចំពោះបាប ជាលក្ខណៈ។

២. បាបានំ អករណរសំ មានការមិនធ្វើបាប ជាកិច្ច ។

(គឺមិនធ្វើអកុសលកម្មបថ ១០) ។

៣. បាបតោ សង្កោចនបច្ចុប្បដ្ឋានំ មានការថយចាកបាប ជាអាការប្រាកដ (គឺមិនធ្វើតែម្តង មិនសម្លាប់ មិនជេរជាដើម)។

៤. បរគារវបទដ្ឋានំ មានការគោរពអ្នកដទៃ ជាហេតុជិត ។

ឧទាហរណ៍ មិនទៅលួចទ្រព្យគេ លួចយកដីគេ ព្រោះគិតដល់សេចក្តីទុក្ខគេ... មិនសម្លាប់សត្វ មិនជេរគេ មិនមើលងាយគេ... គោរពអ្នកដទៃ (ក្នុងកុសលកម្មបថ ១០) ។

-បើអ្នកប្រព្រឹត្ត អកុសលកម្មបថ ១០ ឈ្មោះថា មិនគោរពខ្លួនឯង។

-បើអ្នកប្រព្រឹត្ត កុសលកម្មបថ ១០ ឈ្មោះថា គោរពខ្លួនឯង ។

*-ហិរិ មានការគោរពខ្លួន ទើបមិនធ្វើបាប ដោយខ្មាសដូចស្រីក្រមុំមានត្រកូលល្អរង្កៀស (ខ្ពើម) វត្ថុបដិកូល។*

*-ចំណែកឱត្តប្បៈ មានការគោរពអ្នកដទៃ ទើបមិនហ៊ានធ្វើបាប ព្រោះការកោតក្រែងខ្លាច ដូចស្រីពេស្យាមានការកោតខ្លាចអ្នកដទៃ។*

*-ហិរិ និង ឱត្តប្បៈ នេះ លោកហៅថា លោកបាលធម៌ (ធម៌តែងរក្សានូវសត្វលោក) ជាធម៌យ៉ាងស្ងប់ មិនរាយមាយ។*

**-សរុបសេចក្តីមក ការខ្មាសបាបក៏ដោយ ការខ្លាចបាបក៏ដោយ** មិនមែនបាបអ្នកដទៃទេ គឺខ្មាសបាប ខ្លាចបាបខ្លួនឯង។

-សួរថា នៅក្នុងសង្គមបច្ចុប្បន្ននេះ តើរាល់ថ្ងៃសួរថាយើងសម្លឹងមើលបាបរបស់គេឬក៏ សម្លឹងមើលបាបខ្លួនឯង មួយណាច្រើនជាង? គឺបាបគេ ដូច្នេះហើយទើបចេះតែខឹង ស្អប់ ទើសចិត្តទាស់ចិត្តច្រើន។

**-បើចិត្តអ្នកសង្គ្រោះ ឃើញគេធ្វើអាក្រក់មានតែអាណិត មានតែសង្វេគ ។**

# ៥. អលោភចេតសិក

-អលោភោ ធម៌ដែលបដិបក្ខនឹងលោភៈ ឈ្មោះថា អលោភៈ។

-ម៉្យាងទៀត សត្វមិនលោភដោយធម៌នោះ ហេតុនោះធម៌នោះ ឈ្មោះថា អលោភៈ ។

## -លក្ខណាទិចតុក្កៈរបស់ អលោភៈ

១. អលគ្គភាវលក្ខណោ មានការមិនជាប់ជំពាក់នឹងអារម្មណ៍ជាលក្ខណៈ (ដូចតំណក់ទឹកមិនជាប់នឹងស្លឹកឈូក) ។

២. អបរិគ្គហរសោ មានការមិនហួងហែង ជាកិច្ច ។

មិនហួងហែងរបស់ដែលខ្លួនមាន ថាជារបស់អញ កូនរបស់អញ ទ្រព្យរបស់អញ ប្រពន្ធរបស់អញឡើយ ។

-ទោះបីជាលោកមាន ក៏លោកមិនជាប់ជំពាក់ដែរ ។

៣. អនល្លីនភាវបច្ចុប្បដ្ឋានោ មានការមិនប្រកាន់មាំក្នុងអារម្មណ៍ ជាអាការប្រាកដ ។

ឧទាហរណ៍ មិនប្រកាន់ថាគេមើលងាយអញ គេស្តីឱ្យអញ គេជេរអញ គេមើលងាយអញឡើយ ។

ឧទាហរណ៍ កូនក្មេងវ៉ៃក្បាលយើង ដើរកន្លងជើងយើង...។

-ព្រះពុទ្ធ « តថាគត ពិចារណារកមិនឃើញ សេចក្តីប្រកាន់ ឯណានីមួយ ដែលមិននាំឱ្យកើតទុក្ខមិនមានឡើយ » ។

៤. យោនិសោមនសិការបទដ្ឋានោ មានយោនិសោមនសិការជាហេតុជិត។

## ៦. អទោសចេតសិក

-អទោសោ ធម៌ដែលបដិបក្ខនឹងទោសៈ ឈ្មោះថា អទោសៈ។

មេត្តា ក្នុងព្រហ្មវិហារធម៌ អង្គធម៌ បានដល់ អទោសៈ ហ្នឹងឯង។

-ខន្តី គឺ អំណត់ អត់ធន់ អង្គធម៌បានដល់ អទោសៈដែរ ។

## -លក្ខណាទិចតុក្កៈរបស់ អទោសៈ

១. អចណ្ឌិក្កលក្ខណោ មានការមិនកាច ជាលក្ខណៈ ។ (ដូចមិត្តអ្នកអនុគ្រោះប្រយោជន៍ដល់មិត្ត) ។

២. អាឃាតវិនយរសោ មានការកម្ចាត់អាឃាត (ឬមានការមិនចងគំនុំ) ជាកិច្ច ។

៣. សោមភាវបច្ចុប្បដ្ឋានោ មានសេចក្តីត្រជាក់ ជាអាការប្រាកដ (ដូចព្រះចន្ទពេញវង់) ។

៩. យោនិសោមនសិការបទដ្ឋានោ មានយោនិសោមនសិការជាហេតុជិត ។

## -មេត្តានិមិត្ត

-យើងយកព្រះសម្មាសម្ពុទ្ធជានិមិត្ត បុគ្គលដែលត្រូវចោរយករណាមានដងទាំង ២ ខាង យកមកអារជើង ប្រសិនបើបុគ្គលនោះ ញ៉ាំងចិត្តឱ្យប្រទូស្តជាមួយចោរ នោះឈ្មោះថា មិនរាប់អានតថាគត។ ធ្វើឱ្យយើងមានសេចក្តីអត់ធន់ ចំពោះសេចក្តីក្រោធនឹងបាន ពីព្រោះយើងស្រឡាញ់ព្រះអង្គ។

-ព្រះពុទ្ធដីកា « សត្វណាដែលមិនធ្លាប់ជាមាតាបិតា បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី កូនប្រុស កូនស្រី ជាញាតិរបស់យើង គឺគេកម្រនឹងរកបានណាស់ក្នុងសង្សារវដ្តនេះ »

-នៅក្នុងករណីមេត្តសូត្រ ឱ្យយើងចម្រើនមេត្តាដល់សព្វសត្វទាំងឡាយ ទុកដូចជាកូនយើងមានតែមួយ...។

## -គុណនៃមេត្តា ការចម្រើនមេត្តាចិត្ត

-គុណ គឺមេត្តានេះ កាលណាកុលបុត្រនោះបានចម្រើនល្អ ហើយនៅក្នុងសន្តានក៏រមែងធ្វើឱ្យចិត្ត នឹងមាំទាំ នឹងធឹង ស្ងប់រម្ងាប់ គឺមិនអាចរំជើបរំជួល ដោយពាក្យសម្តីរបស់អ្នកដទៃ ដែលប្រព្រឹត្តពាក្យស្ងួកសៀត ពាក្យសម្តីអាក្រក់ ពាក្យបៀតបៀន អីយ៉ាងណាក៏មិនអាចធ្វើឱ្យកុលបុត្រនោះ ជ្រួលច្របល់បានទេ គឺប្រៀបដូចជាភ្នំថ្មតាន់ ដែលមិនញាប់ញ័រដោយខ្យល់បក់ឡើយ ឬថាប្រៀបដូចជាទឹកមហាសមុទ្រ ដែលបុគ្គលកាន់គប់ភ្លើង គ្រាន់តែយកគប់ស្មៅ ទៅរោល ទៅដុត ឱ្យក្តៅមិនមែនជាខណៈឡើយ បុគ្គលនោះបានតែលំបាកកាយ លំបាកចិត្ត ហត់អត់អំពើតែប៉ុណ្ណោះ។ ឧបមាដូចជាផែនដី ដែលបុរសកាន់យកចប កាន់យកបង្គី មកកាប់មកជីកផែនដី រួចនិយាយថាយើងនឹងធ្វើផែនដី ឱ្យទៅជាមិនមែនផែនដីវិញ ឬថាប្រៀបដូចអាកាស ដែលបុគ្គលយកថ្នាំពណ៌ កាន់ជក់ រួចហើយគិតថានឹងគូររូប ក្នុងអាកាស...។

ឧទាហរណ៍ ដូចជាបុរសម្នាក់ដែលទៅឃើញលំពែងបញ្ឈរមួយ ដែលមានមុខស្រួច បុរសនោះគិតថាយើងនឹងប្រើបាតដៃទះ តប់ ទៅលំពែងនេះឱ្យខ្ទូរមុខ...។

-ការធ្វើទានអស់ ១០០ខ្ទះក្នុងពេលព្រឹក ១០០ខ្ទះក្នុងពេលថ្ងៃត្រង់ ធ្វើទានអស់ ១០០ខ្ទះនៅក្នុងពេលល្ងាច តែប៉ុណ្ណោះប៉ុន្តែទាននោះនៅមិនស្មើនឹងបុគ្គលដែលបានចម្រើនមេត្តានោះឡើយ។ មិនស្មើមួយរឹតទឹកដោះគោនៃបុគ្គលចម្រើនមេត្តា គឺសភាពមិនប្រទូស្ត ការមិនបៀតបៀន ដែលជាចិត្តប្រព្រឹត្តទៅចង់ឱ្យអ្នកដទៃបានសេចក្ដីសុខ ។

## ៧. តត្រមជ្ឈត្តតាចេតសិក

### -ព្រហ្មវិហារធម៌ ៤

១. មេត្តា ក្នុងព្រហ្មវិហារធម៌ អង្គធម៌បានដល់ អទោសចេតសិក។

២. ករុណា ក្នុងព្រហ្មវិហារធម៌ អង្គធម៌បានដល់ ករុណាចេតសិក។

៣. មុទិតា ក្នុងព្រហ្មវិហារធម៌ អង្គធម៌បានដល់ មុទិតាចេតសិក។

៤. ឧបេក្ខា ក្នុងព្រហ្មវិហារធម៌ អង្គធម៌បានដល់ តត្រមជ្ឈត្តតាចេតសិក ។

-តត្រមជ្ឈត្តតា ភាពជាកណ្ដាលក្នុងធម៌នោះៗ ឈ្មោះថា តត្រមជ្ឈត្តតា ។

-តត្រមជ្ឈត្តតា ជាធម្មជាតិធ្វើឱ្យចិត្ត និង ចេតសិកមានលំនឹង។

# -លក្ខណាទិចតុក្កៈរបស់ តត្រមជ្ឈត្តតា

១. ចិត្តចេតសិកានំ សមវាហិតលក្ខណា មានការនាំចិត្តនិងចេតសិកទៅដោយស្មើជានិច្ច (ឬមានការទ្រទ្រង់ចិត្តនិងចេតសិកឱ្យស្មើ) ជាលក្ខណៈ ។

២. ឧនាធិកតានិវារណរសា មានការហាមនូវភាពលើសខ្វះគ្នាជាកិច្ច ។

៣. មជ្ឈត្តភាវបច្ចុប្បដ្ឋានា មានភាពជាកណ្តាល ជាអាការប្រាកដ ។

៤. សម្បយុត្តបទដ្ឋានា មានសម្បយុត្តធម៌ ជាហេតុជិត ។

*-តត្រមជ្ឈត្តតាចេតសិក នេះ មានន័យច្រើនបណ្ឌិតគប្បីឃើញដោយភាពព្រងើយនៃចិត្ត និងចេតសិកទាំងឡាយ ដូចសារថីសម្លឹងមើលព្រងើយៗ នូវសេះអាជានេយ្យដែលរត់ទៅស្មើល្អហើយដូច្នោះ។*

# -យុគលធម៌ ៦ គូ

## -យុគលធម៌គូទី ១

## ៨. កាយបស្សទ្ធិ ៩. ចិត្តបស្សទ្ធិ

-កាយបស្សទ្ធិ បានដល់សេចក្តីស្ងប់កាយ នាមខន្ធ ៣ គឺ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ) ។

-ចិត្តបស្សទ្ធិ បានដល់សេចក្តីស្ងប់ចិត្ត (វិញ្ញាណក្ខន្ធ) ។

## -លក្ខណាទិចតុក្កៈរបស់ បស្សទ្ធិ

១. កាយចិត្តានំ ទរថវូបសមលក្ខណា មានការស្ងប់កាយ (នាមខន្ធ ៣) និងចិត្ត (វិញ្ញាណក្ខន្ធ) ជាលក្ខណៈ ។

២. កាយចិត្តទរថនិម្មទ្ទនរសា មានការកម្ចាត់បង់ភាពក្តៅក្រហាយរបស់កាយនិងចិត្ត ជាកិច្ច ។

៣. កាយចិត្តានំ អបរិប្ផន្ទនសីតិភាវបច្ចុប្បដ្ឋានា មានភាពស្ងប់ត្រជាក់មិនក្តៅផ្សានៃកាយ និងចិត្ត ជាអាការប្រាកដ ។

៤. កាយចិត្តបទដ្ឋានា មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ)និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត។

*-បស្សទ្ធិ ជាបដិបក្ខនឹង ឧទ្ធច្ចៈ (ការរវើរវាយ កុក្កុច្ចៈ។*

# -យុគលធម៌គូទី ២

## ១០. កាយលហុតា ១១. ចិត្តលហុតា

-កាយលហុតា បានដល់ សេចក្តីស្រាលនៃកាយ។

-ចិត្តលហុតា បានដល់ សេចក្តីស្រាលនៃចិត្ត។

## -លក្ខណាទិចតុក្កៈរបស់ លហុតា

១. កាយចិត្តគរុភាវូបសមលក្ខណា មានការស្ងប់ភាពធ្ងន់របស់ កាយនិង ចិត្ត ជាលក្ខណៈ ។

២. កាយចិត្តគរុភាវនិម្មទ្ទនរសា មានការកម្ចាត់បង់ភាពធ្ងន់ របស់កាយនិងចិត្ត ជាកិច្ច ។

៣. កាយចិត្តានំ អទន្ធតាបច្ចុប្បដ្ឋានា មានការមិនយឺតយូរ (របេ័សរបេួន) របស់កាយ និងចិត្ត ជាអាការប្រាកដ ។

៤. កាយចិត្តបទដ្ឋានា មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*-លហុតា ជាបដិបក្ខនឹង ថីនមិទ្ធៈ។*

## -យុគលធម៌គូទី ៣

## ១២. កាយមុទុតា ១៣. ចិត្តមុទុតា

-កាយមុទុតា ភាពទន់ភ្លន់នៃកាយ។

-ចិត្តមុទុតា ភាពទន់ភ្លន់នៃចិត្ត។

## -លក្ខណាទិចតុក្កៈរបស់ មុទុតា

១. កាយចិត្តថទ្ធភាវរូបសមលក្ខណា មានការស្ងប់ភាពរឹងត្អឹង របស់កាយនិង ចិត្ត ជាលក្ខណៈ។

២. កាយចិត្តថទ្ធភាវនិម្មទ្ទនរសា មានការកម្ចាត់បង់ភាពរឹងត្អឹង របស់កាយ និងចិត្ត ជាកិច្ច ។

៣. អប្បដិឃាតបច្ចុប្បដ្ឋានា មានភាពមិនជំទាស់ (មិនចង្អៀតចង្អល់) ជាអាការប្រាកដ ។

៤. កាយចិត្តបទដ្ឋានា មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*-មុទុតា ជាបដិបក្ខនឹង មានះ។*

# -យុគលធម៌គូទី ៤

## ១៤. កាយកម្មញ្ញតា ១៥. ចិត្តកម្មញ្ញតា

-កាយកម្មញ្ញតា សេចក្ដីគួរដល់ការងារនៃកាយ។

-ចិត្តកម្មញ្ញតា សេចក្ដីគួរដល់ការងារនៃចិត្ត។

## -លក្ខណាទិចតុក្កៈរបស់ កម្មញ្ញតា

១. កាយចិត្តានំ អកម្មញ្ញភាវវូបសមលក្ខណា មានការរម្ងាប់កាយ (នាមខន្ធ ៣) និងចិត្ត (វិញ្ញាណក្ខន្ធ) ជាលក្ខណៈ ។

២. កាយចិត្តកម្មញ្ញភាវនិម្មទ្ទនរសា មានការកម្ចាត់បង់ភាពមិនគួរដល់ការងារ របស់កាយនិងចិត្ត ជាកិច្ច ។

៣. កាយចិត្តានំ អារម្មណករណសម្បត្តិបច្ចុប្បដ្ឋានា មានការដល់ព្រមក្នុងការធ្វើអារម្មណ៍ឱ្យកាយ និងចិត្ត ជាអាការប្រាកដ ។

៤. កាយចិត្តបទដ្ឋានា មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*-កម្មញ្ញតា ជាបដិបក្ខនឹង នីវរណៈ ដែលនៅសល់*

*(កាមច្ឆន្ទៈ ព្យាបាទៈ វិចិកិច្ឆា ។*

## -នីវរណធម៌ ៥

១. កាមច្ឆន្ទនីវរណៈ

២. ព្យាបាទនីវរណៈ

៣. ថីនមិទ្ធនីវរណៈ

៤. ឧទ្ធច្ចកុក្កុច្ចនីវរណៈ

៥. វិចិកិច្ឆានីវរណៈ

-បើព្រះអង្គសម្ដែងនៅក្នុងព្រះសូត្រ នីវរណធម៌ មាន ៥ ។

## -នីវរណធម៌ ៦

១. កាមច្ឆន្ទនីវរណៈ

២. ព្យាបាទនីវរណៈ

៣. ថីនមិទ្ធនីវរណៈ

៤. ឧទ្ធច្ចកុក្កុច្ចនីវរណៈ

៥. វិចិកិច្ឆានីវរណៈ

៦. អវិជ្ជានីវរណៈ

-បើព្រះអង្គសម្ដែងនៅក្នុងព្រះអភិធម្ម នីវរណធម៌ មាន ៦ ។

## -យុគលធម៌គូទី ៥

## ១៦. កាយបាគុញ្ញតា ១៧. ចិត្តបាគុញ្ញតា

-កាយបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃកាយ។

-ចិត្តបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃចិត្ត។

## -លក្ខណាទិចតុក្កៈរបស់ បាគុញ្ញតា

១. កាយចិត្តានំ គេលញ្ញរូបសមលក្ខណា មានការស្ងប់នូវអាពាធនៃកាយ (នាមខន្ធ ៣) និងចិត្ត (វិញ្ញាណក្ខន្ធ) ជាលក្ខណៈ ។

២. កាយចិត្តគេលញ្ញនិម្មទ្ធនរសា មានការកម្ចាត់បង់អាពាធនៃកាយ និងចិត្ត ជាកិច្ច ។

៣. និរាទីនវបច្ចុប្បដ្ឋានា មានការប្រាសចាកទោស ជាអាការប្រាកដ ។

៤. កាយចិត្តបទដ្ឋានា មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*-បាគុញ្ញតា ជាបដិបក្ខនឹង អស្សទ្ធា (ការមិនមានសទ្ធា ដែលជាអាពាធនៃ ចិត្ត និង ចេតសិក ។*

**-អាពាធ បានដល់ អកុសលចិត្ត ១២ ដួង ។**

## -យុគលធម៌គូទី ៦

## ១៨. កាយុជុកតា ១៩. ចិត្តុជុកតា

-កាយុជុកតា សេចក្តីស្មោះត្រង់នៃកាយ។

-ចិត្តុជុកតា សេចក្តីស្មោះត្រង់នៃចិត្ត។

## -លក្ខណាទិចតុក្កៈរបស់ ឧជុកតា

១. កាយចិត្តានំ អជ្ជវលក្ខណា មានភាពស្មោះត្រង់នៃកាយ (នាមខន្ធ ៣) និងចិត្ត (វិញ្ញាណក្ខន្ធ) ជាលក្ខណៈ ។

២. កាយចិត្តកុដិលភាវនិម្មទ្ទនរសា មានការកម្ចាត់បង់នូវសេចក្តីមិនស្មោះត្រង់នៃកាយ និងចិត្ត ជាកិច្ច ។

៣. អជិម្ហតាបច្ចុប្បដ្ឋានា មានភាពត្រង់របស់កាយ និងចិត្ត ជាអាការប្រាកដ ។

៤. កាយចិត្តបទដ្ឋានា មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*-ឧជុកតា ជាបដិបក្ខនឹង មាយា (លាក់ពុត និង សាថេយ្យៈ (អំនួតអួតអាង ។*

## -វិរតិចេតសិក ៣

-វិរតិ ប្រែថា តម វៀរចាក ចៀសវាង ។

១. សម្មាវាចាចេតសិក  បានដល់ វាចាប្រពៃ

២. សម្មាកម្មន្តចេតសិក បានដល់ ការងារប្រពៃ

៣. សម្មាអាជីវចេតសិក បានដល់ អាជីវៈប្រពៃ

## ២០. សម្មាវាចាចេតសិក

-សម្មាវាចា ព្រោះអត្ថថា ជាការនិយាយដោយប្រពៃនៃបុគ្គល បានដល់ ការវៀរចាកវចីទុច្ចរិត ៤ ។

-សម្មាវាចា (ជាតួចេតនា ខាងក្នុង) រុញវាចាឱ្យនិយាយក៏ល្អ ។

## -សម្មាវាចា ៤

១. ចេតនាវៀរចាកការនិយាយកុហក ឆបោក

២. ចេតនាវៀរចាកការនិយាយញុះញង់ បំបែកបំបាក់

៣. ចេតនាវៀរចាកការនិយាយពាក្យអាក្រក់ ជេរប្រទេច

៤. ចេតនាវៀរចាកការនិយាយរោយរាយ ឥតប្រយោជន៍

-ការនិយាយវាចាល្អទាំង ៤ ក៏ជាសម្មាវាចា ការវៀរចាកការនិយាយវាចាអាក្រក់ទាំង ៤ ក៏ជាសម្មាវាចា ។

## -ក្នុងមួយថ្ងៃ តើយើងអាចមិននិយាយមួយថ្ងៃបានទេ?

-ខណៈពេលខ្លះ យើងចង់និយាយកុហក ចង់និយាយញុះញង់ បំបែកបំបាក់ និយាយពាក្យអាក្រក់ ជេរប្រទេច ចង់និយាយ រោយរាយ ឥតប្រយោជន៍ (និយាយលេងសើចអត់បានការ) ដល់យើងមានសតិដឹងទាន់ ថាពាក្យនេះមិនគួរនិយាយទេ។

តួដឹងហើយមិននិយាយវិញ នេះគឺជាតួវិរតិ ប៉ុន្តែបើនៅស្ងៀម អត់ចង់និយាយអីទាំងអស់ ក៏វិរតិនេះ វាមិនកើតដែរ។

ឧទាហរណ៍ ដូចមានអ្នកណាធ្វើអីខុស (កូនចៅធ្វើខូចឥវ៉ាន...) តាមតែចិត្តខឹង ចង់តែជេរ ចង់ទៅស្តីឱ្យ ដល់គិតទៅពិចារណាទៅ ជេរក៏មិនបានស្តីដែរ តួដែលការពារមិនឱ្យផ្ទុះការជេរនឹងចេញទៅ នេះជាតួសម្មាវាចា មិនចាំបាច់ទាល់តែនិយាយចេញទេ គ្រាន់តែវៀរមិននិយាយទៅគេ ឱ្យគេឈឺចាប់ហើយក៏អត់និយាយវិញ ។

-នៅពេលអរិយមគ្គ កើតឡើងមានអីនិយាយ ដូចជា ព្រះអញ្ញាកោណ្ឌញ្ញៈ ខណៈពេលស្តាប់ធម៌យល់លោកប្រើតែត្រចៀកតើ នៅតែស្ងៀម តែតួសម្មាវាចានឹងកើតឡើង។

ឧទាហរណ៍ យើងចង់និយាយកុហក ចង់និយាយញុះញង់ និយាយពាក្យអាក្រក់ ជេរប្រទេច ចង់និយាយរោយរាយ ឥត

ប្រយោជន៍ ដូចជាមេរោគផ្លូវចិត្ត ដល់ តួសម្មាវាចា ទៅស្អែនមេរោគហ្នឹង ទាល់តែវាមានមេរោគទើបវាស្អែន ។

ឧទាហរណ៍ ទាល់តែចោរលួច ទើបប៉ូលីសដេញចាប់...។

## -លក្ខណាទិចតុក្កៈរបស់ សម្មាវាចា

១. វចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណា មានការមិនកន្លងវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាលក្ខណៈ ។

ឧទាហរណ៍ អីវ៉ាន់ខូចគឺជាវត្ថុដែលជាទីតាំងនាំឱ្យជេរ...។

ឧទាហរណ៍ ថាឃើញគេមានលុយច្រើន យើងចង់កុហកបោកប្រាស់គេ យកលុយគេ ប៉ុន្តែដល់ វិរតិវាកើតឡើង បង្វែរការគិតឃើញថាលុយគេទម្រាំតែរកបានមក គឺវាពិបាកណាស់។

២. វចីទុច្ចរិតវត្ថុតោ សង្កោចនរសា មានការថយចាកវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាកិច្ច ។

ឧទាហរណ៍ ឃើញអ្នកដទៃបានសេចក្តីសុខ ដូចមិត្តភក្តិគេត្រូវគ្នា ប្តីប្រពន្ធគេត្រូវគ្នា ម្តាយកូនគេត្រូវគ្នា ស្រឡាញ់គ្នា (នេះជាវត្ថុដែលជាទីតាំង ជាហេតុ) ហើយយើងក៏អត់ពេញចិត្តនឹងគេបានសុខ រួចក៏ចង់ញុះញង់ឱ្យគេបែកបាក់គ្នា ប៉ុន្តែដល់ វិរតិវាកើតឡើង វាថយចាកវត្ថុដែលជាទីតាំងហ្នឹង (វាបង្វែលការគិត

វាដូរការគិត វាដូរអារម្មណ៍) ទៅជាត្រេកអរឃើញគេបានសុខទៅវិញ គេបានសុខដោយសារបុណ្យរបស់គេទេតើ ។

-ថយ គឺ ដូរអារម្មណ៍ទៅជាមេត្តា មុទិតាទៅវិញ ។

៣. តស្ស អក្រិយបច្ចុប្បដ្ឋានា មានការមិនធ្វើនូវវចីទុច្ចរិតនោះជាអាការប្រាកដ (អត់និយាយ) ។

៤. សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានា មានគុណគឺសទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិច ជាដើម ជាហេតុជិត ។

-យើងគ្រាន់តែហាម ចិត្តកុំឱ្យកុហក កុំឱ្យញុះញង់ កុំឱ្យជេរប្រទេច កុំឱ្យនិយាយអត់បានការហ្នឹង ក៏ជាកុសលដោយពិត។

## -អង្គនៃមុសាវាទមាន ៤ គឺ ៖

១. រឿងមិនពិត

២. គិតនឹងពោលឱ្យខុសពីការពិត

៣. ព្យាយាមពោលឱ្យខុសពីការពិត

៤. ញុំាងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ(គេជឿក៏ដោយ មិនជឿក៏ដោយ ក៏ឈ្មោះថា ដាច់សីល ដាច់កម្មបថដែរ ឱ្យតែគេដឹងន័យឬយល់ន័យយើងនិយាយ) ។

កាលណាគ្រប់អង្គទាំង៤ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល ។

## -អង្គនៃបិសុណាវាទមាន ៤ គឺ ៖

១. មានអ្នកដទៃដែលខ្លួនគប្បីញុះញង់ បំបែក

២. គិតនឹងញុះញង់បំបែកអ្នកដទៃនោះ

៣. ព្យាយាមញុះញង់បំបែកអ្នកដទៃនោះ

៤. ញុាំងអ្នកដទៃឱ្យដឹងច្បាស់នូវរឿងដែលខ្លួនញុះញង់នោះ (កាលបើបុគ្គលដទៃមិនបែកបាក់គ្នាទេ កម្មបថក៏មិនដាច់ កាលបើបុគ្គលដទៃបែកបាក់គ្នាន៑ុះឯង កម្មបថក៏ ឈ្មោះថា ដាច់) ។

(បិដកអដ្ឋកថា ៦៤ អកុសលកម្មបទ ១០ ទំព័រ៣២៧~៣៤០)

-កាលណាគ្រប់អង្គទាំង៤ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល ។

## -អង្គនៃផរុសវាទមាន ៣ គឺ ៖

១. មានអ្នកដទៃដែលខ្លួនគប្បីជេរ (សត្វ ឬក៏មនុស្សនៅរស់)

២. មានចិត្តខឹងក្រោធ

៣. បានជេរប្រទេច (ឱ្យតែបានជេរ ទោះបីគេឮ មិនឮ ដឹងក៏ដោយ មិនដឹងក៏ដោយ ជេរពីមុខ ជេរពីក្រោយក៏ដោយ ក៏ឈ្មោះថា ដាច់កម្មបថដែរ) ។

-កាលណាគ្រប់អង្គទាំង៣ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល ។

## -អង្គនៃសម្ផប្បលាបវាទមាន ២ គឺ ៖

១. ចិត្តចង់និយាយរឿងដែលអត់ប្រយោជន៍ (ឱ្យគេដឹង)

២. បាននិយាយនៅរឿងដែលអត់ប្រយោជន៍នោះ

-កាលណាគ្រប់អង្គទាំង២ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល ។

# ២១. សម្មាកម្មន្តចេតសិក

-សម្មាកម្មន្តៈ ការងារដែលប្រព្រឹត្តទៅដោយប្រពៃ ឈ្មោះថា សម្មាកម្មន្តៈ បានដល់ ចេតនាជាគ្រឿងវៀរចាកនូវ កាយទុច្ចរិត ៣ ។

## -សម្មាកម្មន្តៈ ៣

## ១. ចេតនាវៀរចាក ការសម្លាប់សត្វ

-នៅស្មៀមតើ ចង់សម្លាប់សត្វ តែអត់សម្លាប់សត្វវិញ តួប្រាំង មួយដែលទប់មិនឱ្យសម្លាប់ នេះជា សម្មាកម្មន្តៈ ។

ឧទាហរណ៍ ថាយើងខឹងស្រមោច ខឹងមូស (វាខាំ) ខឹងរុយ (វាពោមអាហារ) ខឹងឆ្កែ (ជុះអាចម៍ដាក់មុខផ្ទះ) ខឹងមាន់ ខឹងឆ្មា ចង់ទៅដាក់ឱ្យងាប់...។

ឧទាហរណ៍ តាមចិត្តឃ្លាន ឃើញមាន់ចង់តែចាប់ស្ងោរស៊ី ដល់ឮកូនវាយំស្រែករញ៉េរញ៉ៃពេក អ៊ីចឹងទៅក៏លែងសម្លាប់វាទៅវិញ ។

## ២. ចេតនាវៀរចាក ការលួចទ្រព្យគេ

-បើតាមតែអំណាចលោភៈហ្នឹង ឃើញរបស់គេ ប្រហែលចង់តែបាន ចង់តែលួច ដល់ពេលហិរិ ឱត្តប្បៈ មកជំនួសក៏សម្រេចចិត្តថាអត់លួចគេវិញ ឃើញថារបស់ទ្រព្យយើង រកបានមកក៏ពិបាក ក៏យើងហួងហែង របស់គេក៏មានគេហួងហែង បើយើងបាត់របស់ យើងក៏កើតទុក្ខ គេបាត់របស់ គេក៏កើតទុក្ខដែរ ដល់អ៊ីចឹងក៏លែងលួចគេវិញទៅ ។

## ៣. ចេតនាវៀរចាក ការប្រព្រឹត្តខុសក្នុងកាម

-បើតាមតែកិលេសនឹងខិល លោភៈនឹងខូចណាស់ ចង់តែរកស្រីក្មេង ឃើញស្រីក្មេងមិនបាន ក៏ប៉ុន្តែដោយគិតដល់ប្រពន្ធកូនទៅលែងចង់ទៅប្រព្រឹត្តខុសក្នុងកាមវិញទៅ ។

## -លក្ខណាទិចតុក្កៈរបស់ សម្មាកម្មន្តៈ

១. កាយទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាលក្ខណៈ ។

ឧទាហរណ៍ ត្រីងៀតគឺជាវត្ថុដែលជាទីតាំងនាំឱ្យចង់សម្លាប់។

ឧទាហរណ៍ ថាឃើញគេមានលុយច្រើន ចង់លួចលុយគេ ប៉ុន្តែដល់ វិរតិ វាកើតឡើង បង្វែរការគិត ឃើញថាលុយគេទម្រាំតែរកបានមក គឺវាពិបាកណាស់ ។

២. កាយទុច្ចរិតវត្ថុតោ សង្កោចនរសោ មានការថយចាកវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាកិច្ច ។

ឧទាហរណ៍ ឃើញស្រីស្អាត ស្រីក្មេង ឃើញទ្រព្យរបស់អ្នកដទៃ (នេះជាវត្ថុដែលជាទីតាំង ជាហេតុ) ប៉ុន្តែដល់ វិរតិ វាកើតឡើង វាថយចាកវត្ថុដែលជាទីតាំងហ្នឹង (វាបង្វែលការគិត វាដូរការគិត វាដូរអារម្មណ៍) រួចក៏ឈប់ធ្វើអំពើនោះទៅ ។

ឧទាហរណ៍ គិតថាខ្លួនឯងវ័យចាស់ហើយជិតស្លាប់ទៅវិញ ហើយនៅចង់រកស្រីក្មេងដល់ណាទៀត...។

-ថយ គឺ ដូរអារម្មណ៍ទៅជាមេត្តា ករុណា មុទិតាទៅវិញ។

៣. តស្ស អក្រិយបច្ចុប្បដ្ឋានោ មានការមិនធ្វើនូវកាយទុច្ចរិតនោះ ជាអាការប្រាកដ (ជាផលរបស់វា គឺអត់ធ្វើ) ។

៤. សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានោ មានគុណគឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិច ជាដើម ជាហេតុជិត ។

**-យើងគ្រាន់តែហាម ចិត្តកុំឱ្យសម្លាប់សត្វ កុំឱ្យលួចទ្រព្យគេ កុំឱ្យប្រព្រឹត្តខុសក្នុងកាម ហ្នឹង ក៏ជាកុសលដោយពិត។**

# -សីលធម៌

## -សីល ៥ = កល្យាណធម៌ ៥

១. មិនសម្លាប់សត្វ នាំឱ្យកើត មេត្តាធម៌

« មិនសម្លាប់តែអត់មេត្តា វាស្មើនឹងឃាតករអត់បានសម្លាប់ » ពេលខ្លះ ខ្លាចគេចាប់ដាក់គុក ខ្លាចគេសងសឹក ខ្លាចធ្លាក់នរក។

២. មិនលួចទ្រព្យគេ នាំឱ្យកើត សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ដូចជា យើងគិតថាមានដៃ២ ជើង២ ដូចគេដែរ មិនគួរណាទៅលួចទ្រព្យគេទេព្រោះមានមុខរបរច្រើនណាស់។

« មិនលួចតែអត់មានការតាំងចិត្តចិញ្ចឹមជីវិតត្រូវ វាស្មើនឹងចោរអត់បានលួច » ពេលខ្លះ ខ្លាចប៉ូលិសចាប់ដាក់គុក ខ្លាចម្ចាស់គេវ៉ៃ ខ្លាចធ្លាក់នរក បានអត់លួច ដល់អ៊ីចឹង សួរថាចោរនោះមានគុណធម៌ឬអត់?

៣. មិនប្រព្រឹត្តខុសក្នុងកាម នាំឱ្យកើត សទារសន្តោសៈ (ចេះសន្តោសក្នុង បុត្រនិងភរិយា) ។

« មិនប្រព្រឹត្តខុសក្នុងកាម តែមិនថែរក្សាកូន ប្រពន្ធដោយធម៌ គឺស្មើនឹងមនុស្សក្បត់ចិត្ត តែមិនបានប្រព្រឹត្តខុសតែប៉ុណ្ណឹង »

៤. ការមិនកុហក នាំឱ្យកើត សច្ចវាចា

« មិនកុហកតែមិនចម្រើនសច្ចវាចា វាស្មើនឹងមនុស្សក្បត់សម្តី តែមិនបាននិយាយកុហកតែប៉ុណ្ណឹង »

៥. ការមិនសេពគ្រឿងស្រវឹង នាំឱ្យកើត មានសតិ សម្បជញ្ញៈ

« មិនផឹកទឹកស្រវឹងតែមិនចម្រើន សតិ សម្បជញ្ញៈ វាស្មើនឹង ជនប្រមឹកតែអត់បានផឹកតែប៉ុណ្ណឹង »

## -អង្គនៃបាណាតិបាត មាន ៥ គឺ ៖

១. បាណោ សត្វមានជីវិត

២. បាណសញ្ញិតា សេចក្តីដឹងថាសត្វមានជីវិត

៣. វធកចិត្តំ ចិត្តគិតនឹងសម្លាប់

៤. ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥. តេនមរណំ សត្វស្លាប់ដោយការព្យាយាមនោះ ។

កាលណាគ្រប់អង្គទាំង ៥ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេប៉ុន្តែ អាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល ។

## -អង្គនៃអទិន្នាទាន មាន ៥ គឺ ៖

១. បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា

២. បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថាទ្រព្យមានម្ចាស់គេហួងហែងរក្សា ។

៣. ថេយ្យចិត្តំ ចិត្តគិតនឹងលួច

៤. ឧបក្កមោ ព្យាយាមនឹងលួច

៥. តេនហរណំ លួចបានមកដោយការព្យាយាមនោះ។

កាលណាគ្រប់អង្គទាំង ៥ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេប៉ុន្តែ អាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល។

## -អង្គនៃកាមេសុមិច្ឆាចារ មាន ៤ គឺ ៖

១. អគមនីយវត្ថុ វត្ថុដែលមិនគួរទាក់ទង (បានដល់ស្ត្រី ២០)។

២. តស្មឹ សេវនចិត្តំ មានចិត្តគិតនឹងសេពនូវវត្ថុ (ស្ត្រី) ដែលមិនគួរទៅទាក់ទងនោះ។

៣. សេវនប្បយោគោ ព្យាយាមក្នុងការសេព។

៤. នគ្គេន មគ្គប្បដិបាទនំ ញុាំងមគ្គ និង មគ្គឱ្យដល់គ្នា។

កាលណាគ្រប់អង្គទាំង ៤ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេប៉ុន្តែ អាចជាទុច្ចរិតកម្ម អាចឱ្យផល ក្នុងបវត្តិកាល ។

## ២២. សម្មាអាជីវចេតសិក

-សម្មាអាជីវៈ ព្រោះអត្ថថា ជាគ្រឿងចិញ្ចឹមជីវិតដោយប្រពៃនៃសត្វទាំងឡាយ បានដល់ចេតនាវៀរចាកមិច្ឆាអាជីវៈ ។

-សម្មាអាជីវៈ មាន ៧ យ៉ាង គឺវៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ដែលមានអាជីវៈជាហេតុ ឬមានច្រើនយ៉ាងដោយអំណាចនៃការវៀរចាកការកុហកបោកបញ្ឆោតជាដើម ។

ឧទាហរណ៍ វៀរចាកការនិយាយកុហកនឹងដើម្បីចិញ្ចឹមជីវិត (ដូចជាលក់ផ្លែឈើ លក់សម្លៀកបំពាក់ របស់ហ្នឹងមិនល្អ តែកុហកគេថាល្អ) នេះហៅថា សម្មាអាជីវៈ។ ប៉ុន្តែបើវៀរចាកការនិយាយកុហកគេលេងសើច នេះហៅថា សម្មាវាចា។

ឧទាហរណ៍ ថាមានគេអ្នករកស៊ីមុខរបរដូចគ្នា(អ្នកលក់មាស) អ៊ីចឹងទៅ ឃើញគេលក់ដាច់ជាងខ្លួន ក៏និយាយញុះញង់អ្នកទិញមាស ថាមាសគាត់នោះអត់គ្រប់ទឹកទេ មាសទឹក១០ បានតែទឹក៩ អ៊ីចឹងទៅ ដើម្បីឱ្យគេខាតប្រយោជន៍ រួចមកទិញវិញខ្លួនបានចំណេញយកលុយនោះមកដើម្បីចិញ្ចឹមជីវិត នេះហៅថា មិច្ឆាអាជីវៈ ។

ឧទាហរណ៍ អ្នកខ្លះឡាយ (Live) និយាយជេរគ្នា ដល់គេចូលមើលច្រើនទៅគាត់បានលុយ រួចគាត់យកលុយនោះមកដើម្បីចិញ្ចឹមជីវិត នេះហៅថា មិច្ឆាអាជីវៈ។ ប៉ុន្តែអ្នកខ្លះ ខឹងគេរឿងអីរួចក៏ជេរគេទៅ អត់មានបានលុយទេ នេះហៅថា មិច្ឆាវាចា។

ឧទាហរណ៍ ថាយើងទៅសម្លាប់ជីវិតសត្វនឹងដើម្បីចិញ្ចឹមជីវិត នេះហៅថា មិច្ឆាអាជីវៈ។ ប៉ុន្តែបើយើងសម្លាប់ស្រមោច សម្លាប់មូស ដោយចិត្តខឹងហើយក៏វ៉ៃវាឱ្យងាប់ អត់មានយកមកចិញ្ចឹមជីវិតអីទេ នេះហៅថា មិច្ឆាកម្មន្តៈ។

ឧទាហរណ៍ យើងវៀរចាកការលួច(ស៊ីភ្នែកជញ្ជីងគេ)នឹងដើម្បីយកមកចិញ្ចឹមជីវិត នេះហៅថា សម្មាអាជីវៈ។ ប៉ុន្តែបើយើងវៀរចាកការលួច ដុតផ្ទះគេចោល នេះហៅថា សម្មាកម្មន្តៈ។

ឧទាហរណ៍ ដូចជាប្រព្រឹត្តខុសក្នុងកាម (លក់ខ្លួន) ដើម្បីបានលុយយកមកចិញ្ចឹមជីវិត នេះហៅថា មិច្ឆាអាជីវៈ។ ប៉ុន្តែប្រសិនបើប្រព្រឹត្តខុសក្នុងកាម ដោយការសប្បាយជាមួយគ្នាលេង នេះហៅថា មិច្ឆាកម្មន្តៈ ។

## -មិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតខុស ៥ យ៉ាង ៖

១. សត្ថវណិជ្ជា ការជួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារ (មានដាវ កាំភ្លើងជាដើម សម្រាប់សម្លាប់) គឺធ្វើគ្រឿងសស្ត្រាវុធដោយខ្លួនឯងឬបានមកដោយហេតុឯណានីមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះៗ ។

-ព្រះពុទ្ធហាម អីចឹង គេថាអ្នកកាន់ព្រះពុទ្ធសាសនាកើតសង្គ្រាមអីគ្រាន់តែដាវ កាប់គ្នាហ្នឹង ព្រះអង្គមិនឱ្យជួញផង។

២. សត្តវណិជ្ជា ជួញមនុស្ស (លក់ទាសករ គឺគាត់លក់ជីវិត) ។

-ការជួញដូរមនុស្ស ព្រះពុទ្ធហាម តាំងពីយូរ សិទ្ធិមនុស្សទឹមនិយាយក្រោយទេ យើងទាមទារតែសិទ្ធិមនុស្ស ប៉ុន្តែសត្វអត់មានទាមទារឱ្យគ្នាខ្លះសោះ។

ឧទាហរណ៍ អ្នកខ្លះលក់សត្វ យកសត្វលេងធ្វើជាល្បែង ជល់មាន់ ជល់ត្រីក្រឹមជាដើម មិនមែនជាជំនួញខុសទេ ។

៣. មំសវណិជ្ជា ការជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយមានជ្រូកជាដើម លុះសត្វទាំងនោះចម្រើនធំឡើង ក៏សម្លាប់យកសាច់ទៅលក់ ។

ឧទាហរណ៍ អ្នកខ្លះចិញ្ចឹមសត្វលក់ បំបែកបំបាក់គ្រួសារគេ វាមានកូន វាមានម៉ែវា (ដូចជា មាន់ ទា ជាដើម)។

៤. មជ្ជវណិជ្ជា ការជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯងឬក៏ទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ។

៥. វិសវណិជ្ជា ការជួញថ្នាំពិស គឺចាត់ចែងនូវថ្នាំពិសឱ្យកើតឡើងដោយឯងឬឱ្យគេផ្សំឱ្យឬ បានមកដោយហេតុណាមួយ ហើយលក់នូវថ្នាំពិសនោះ។

-នៅពេលយើងមានធម៌ ប្រតិបត្តិក្នុងជីវិតប្រចាំថ្ងៃហ្នឹងរកស៊ីមិនបានទេ? គឺវៀរចាកតែមុខរបរខុស ៥ យ៉ាងនេះទេតើ ខ្វះអីមុខរបរមួយគគោក អ្នកខ្លះថាចេះធម៌ទៅ រកស៊ីមិនកើត ហើយខ្ញុំចង់សួរថារកស៊ីបានតែ៥មុខហ្នឹងទេឬ? គ្រាន់តែច្បាប់ក៏គេមានហាមដែរ ជួញមនុស្ស ជួញគ្រឿងសស្ត្រាវុធ។

-ព្រះពុទ្ធដីកា « អត្តានំ ឧបមំ កត្វា » គប្បីធ្វើខ្លួនឯងជាឧបមា។ យើងឈប់គិត ឈប់និយាយរឿងបុណ្យ បាប យើងយកខ្លួនឯងធ្វើជាឧបមាវិញម្តង។ អ្នកខ្លះនិយាយរឿងបុណ្យ បាបគាត់មិនយល់ទេ ប៉ុន្តែនៅពេលដែលគាត់គិតឃើញ ដោយខ្លួនឯងឧបមា មកប្រពន្ធ កូនខ្លួនឯងវិញ បើគេយកទៅលក់ គេសម្លាប់យកសាច់លក់ តើយើងយ៉ាងម៉េចវិញ? រីឯសត្វក៏ដូចគ្នា ឃើញសត្វក៏ចេះស្រឡាញ់ ចេះកើតទុក្ខ ចេះស្រឡាញ់កូនវាដែរ។

-បើថ្ងៃនេះគេចាប់យើងយកទៅលក់វិញយើងយ៉ាងម៉េច?

-បើគេសម្លាប់យើងយកសាច់ទៅលក់វិញយើងយ៉ាងម៉េច?

-បើគេយកថ្នាំពុលនឹងមកឱ្យយើងផឹកវិញ តើយើងស្រួលខ្លួនអត់? អត់ស្រួលខ្លួនទេ វាប្រកាច់ ។

-យើងយកថ្នាំពុលទៅបំពុលសត្វវាម៉េចដែរ?

**-ចូរយកខ្លួនជាឧបមា យើងក៏ចង់បានសុខ អ្នកដទៃក៏ចង់បានសុខ ដូច្នេះហើយ យើងមិនគប្បីបៀតបៀនគ្នាឡើយ ។**

## -លក្ខណាទិចតុក្កៈរបស់ សម្មាអាជីវៈ

១. តិវិធកាយទុច្ចរិតចតុព្វិធវចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាលក្ខណៈ ។

២. តេសំ វត្ថូនំ សង្កោចនរសោ មានការថយចាកវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាកិច្ច ។

៣. តសំ ទុច្ចរិតានំ អក្រិយបច្ចុប្បដ្ឋានោ មានការមិនធ្វើទុច្ចរិតនោះ ជាអាការប្រាកដ (ជាផលរបស់វា គឺអត់ធ្វើ អត់និយាយ)។

៤. សទ្ធាហិរោត្តប្បាទិគុណបទដ្ឋានោ មានគុណគឺសទ្ធា ហិរិ ឱត្តប្បៈជាដើម ជាហេតុជិត ។

# -អធិប្បាយវិរតិ ៣

-វារៈនៃការវៀរចាកបាប ឈ្មោះថា វិរតិចេតនា ឬហៅថា វិរតិ មាន ៣ ប្រភេទគឺ ៖

១. សម្បត្តវិរតិ ២. សមាទានវិរតិ ៣. សមុច្ឆេទវិរតិ

**១. សម្បត្តវិរតិ** បានដល់ការវៀរចាកបាប ដោយអធ្យាស្រ័យរបស់ខ្លួនដូចក្នុងខណៈដែលកំពុងមាន វិរមិតព្វវត្ថុ (វត្ថុត្រូវវៀរ) ប្រាកដចំពោះមុខហើយក៏មិនប្រព្រឹត្តកន្លង។

-អ្នកមិនកាន់ព្រះពុទ្ធសាសនា ក៏គេមានសីលដែរ ។

ឧទាហរណ៍ គេគិតឃើញភ្លាមៗ គេតមភ្លាមៗ តមម្ដងមួយៗ ពេលកើតមួយវៀរចាកមួយ...។ ឃើញទេ? សីលអត់មានជាប់ទម្រង់ទេ ។

**២. សមាទានវិរតិ** បានដល់ការវៀរចាកបាប ដោយសមាទាន (ការកាន់យកឬរៀនយកដោយល្អ) នូវសិក្ខាបទដែលបញ្ញត្តទុក មាននិច្ចសីល និងឧបោសថសីលជាដើម។

**៣. សមុច្ឆេទវិរតិ** បានដល់ការវៀរចាកបាប ដែលកាត់ផ្ដាច់ជាសមុច្ឆេទ ដោយអរិយមគ្គ ។

-វិរតិ ៣ នេះ បើកើតតាមធម្មតាកើតម្តងបានតែមួយទេ ដល់តែកើតក្នុងអរិយមគ្គទើបកើតម្តងបាន ៣ ។

# -អប្បមញ្ញាចេតសិក ២

## ១. ករុណាចេតសិក ២. មុទិតាចេតសិក

-អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វ មិនមានប្រមាណ មិនមានដែនកំណត់ ។

-មនុស្សយើងជាធម្មតា កាលណាមិនបានចម្រើនមេត្តាភាវនា រមែងមានអគតិធម៌ ៤ ខ្លាំងក្លា ។ បើស្រឡាញ់ទាល់តែ កូនអញ ញាតិអញ ក្រុមអញ អ្នកធ្វើល្អជាមួយអញ... ទើបអញ មេត្តា ករុណា មុទិតា ជាមួយ។ យើងគ្រប់ៗគ្នាជាធម្មតា អប្បមញ្ញា នេះ នៅមានកម្រិតនៅឡើយ។

-អប្បមញ្ញា ដល់កើតឡើងមែនទែន ឈប់មានដែនកំណត់ ទៀតហើយ ឈប់មានជនជាតិអីទៀតហើយ។

-អញស្រឡាញ់តែខ្មែរ អញស្អប់យួន អញស្រលាញ់តែឆ្កែ សត្វ ឆ្មា ចឹងចក់ សត្វពស់អញមិនស្រឡាញ់ទេ គឺអត់មានអីចឹងទេ គឺមានចិត្ត មេត្តា ករុណា មុទិតា ឧបេក្ខា ស្មើៗគ្នាគ្រប់សព្វសត្វ ទាំងឡាយ។

## ២៣. ករុណាចេតសិក

-ករុណា ធម្មជាតិណា កាលសត្វដទៃមានទុក្ខ រមែងធ្វើនូវសេចក្ដីអាណិតអាសូរដល់សាធុជនទាំងឡាយ ព្រោះហេតុនោះធម្មជាតិនោះ ឈ្មោះថា ករុណា។

-ករុណា មាន ទុក្ខិតសត្តប្បញ្ញត្តិ សេចក្ដីទុក្ខរបស់សត្វ ជាអារម្មណ៍ ។

## -លក្ខណាទិចតុក្កៈរបស់ ករុណា

១. បរទុក្ខាបនយកាមតាលក្ខណា មានសេចក្ដីប្រាថ្នាជួយបំបាត់ទុក្ខអ្នកដទៃ(អាណិតអាសូរ) ជាលក្ខណៈ ។

-ករុណារបស់ព្រះពុទ្ធខ្ពស់ជាងយើងក្រៃលែងត្រង់ ឃើញថាសត្វលោកកំពុងតែសុខ កំពុងតែសប្បាយ ក៏កើតទុក្ខទៀត។ ឧទាហរណ៍ យើងឃើញគេមានឡាន មានទ្រព្យ មានប្រពន្ធមានកូន ព្រះអង្គឃើញសុទ្ធតែជាទុក្ខ (ព្រោះវាប្រែប្រួល)។

២. បរទុក្ខាសហានរសា មានការអត់ធន់មិនបានចំពោះសេចក្ដីទុក្ខអ្នកដទៃ ជាកិច្ច ។

-គឺអត់ទ្រាំមិនជួយមិនបាន (ត្រូវតែជួយ) គឺពិបាកធ្វើប្រងើយណាស់ ពេលឃើញសត្វមានទុក្ខ មិនអាណិតមិនបាន

(ត្រូវតែអាណិត) ។ ប៉ុន្តែមិនមែនដល់ថ្នាក់ឃំទេណា ហើយក៏មិនមែនជាលក្ខណៈពិបាកចិត្តដែរ ។

ឧទាហរណ៍ ថាឃើញគេដួលម៉ូតូ ដួលកង់ ឃើញសត្វលង់ទឹកហ្នឹងគឺទ្រាំមិនបានត្រូវទៅជួយ...។

៣. អវិហឹសា បច្ចុប្បដ្ឋានា មានការមិនបៀតបៀន ជាអាការប្រាកដ ។

ឧទាហរណ៍ យើងឃើញមនុស្ស ធ្វើអាក្រក់ដាក់យើង ក៏យើងនៅតែអាណិត ។

-សូម្បីតែឃើញគេចាប់បានចោរ គេចាប់បានអ្នកសម្លាប់គេ គេវៃពួកគាត់ហ្នឹង ក៏យើងមិនដាក់បណ្តាសា ចោរដែរ តែបែរជាអាណិតគាត់ទៅវិញ ។

៤. ទុក្ខាភិភូតានំ អានាថភាវទស្សនបទដ្ឋានា មានការឃើញសត្វដែលទុក្ខគ្រប់សង្កត់ហើយ មិនមានទីពឹង ជាហេតុជិត ។

# -សម្បត្តិ និង វិបត្តិ របស់ករុណា ៖

១. មានការចូលទៅរម្ងាប់នូវសេចក្តីបៀតបៀន ជាសម្បត្តិ ។

២. មានការកើតឡើងនៃសេចក្តីសោក(ងាយនឹងឱ្យសោកកើតឡើង) ជាវិបត្តិ ។

ឧទាហរណ៍ អ្នកខ្លះអាណិតៗ ដល់អត់យល់ទៅជា ទោមនស្សកើតឡើង មិនគួរសោះ មិនគួរអើចឹងសោះ (កូននឹងល្អ ប៉ុន្តែត្រូវគ្រោះថ្នាក់ចរាចរណ៍ស្លាប់) ។

-អ្នកខ្លះច្រឡំថាយំហើៗៗ ហ្នឹងថាខ្ញុំអាណិតណាស់ ។

-អ្នកខ្លះយល់ច្រឡំមានញាតិស្លាប់ក៏មិនយំ ខឹងទៀត ថាយើងអត់មានមនោសញ្ចេតនាអីសោះ ។

៣. មានទោមនស្ស (ការខូចចិត្ត) ដោយអាស្រ័យកាមគុណ ជាសត្រូវជិត ។

-តើអ្វីជាសត្រូវ? អកុសលធម៌ទាំងអស់ (អកុសលចិត្ត ១២) ហ្នឹងជាសត្រូវ ហើយវាងាយនឹងកើតឡើងណាស់ ទោមនស្សនេះ។

ឧទាហរណ៍ ជាសត្រូវជិត អាណិតៗៗ ជួយមិនបានយំ ពិបាកចិត្ត ឃើញវាឆាប់កើតណាស់ ។

៤. មានការបៀតបៀនសត្វ (មិនងាយបៀតបៀនសត្វទេ) ជាសត្រូវឆ្ងាយ ។

# ២៤. មុទិតាចេតសិក

**-មុទិតា** បុគ្គលរមែង **ត្រេកអរ** (ចំពោះសេចក្ដីសុខ ឬសម្បត្តិរបស់អ្នកដទៃ) ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថាមុទិតា។

**-មុទិតា** មាន **សុខិតសត្តប្បញ្ញត្តិ** សេចក្ដីសុខ ឬសម្បត្តិរបស់សត្វ ជាអារម្មណ៍។

**-មុទិតា គឺ ត្រេកអរ រឿងគេបាន** (ចំពោះសេចក្ដីសុខ ឬសម្បត្តិរបស់អ្នកដទៃ) ប៉ុន្តែ **បើលោភៈ គឺត្រេកអរ រឿងយើងបាន** (ចំពោះខ្លួនឯងបានសេចក្ដីសុខ បានទ្រព្យ បានអីៗ) **នេះជា លោភៈ** ។

**-មុទិតា** បដិបក្ខនឹង **ឥស្សា** (ការច្រណែន) ។

## -លក្ខណាទិចតុក្កៈរបស់ មុទិតា

**១. បរសម្បត្តិអនុមោទនលក្ខណា** មានការត្រេកអររីករាយ (សរសើរ) ចំពោះសម្បត្តិរបស់អ្នកដទៃ ជាលក្ខណៈ។

**-ការសរសើរ និងការលើកទឹកចិត្តអាចជាថ្នាំប៉ូវ** បើយើងប្រើមិនត្រូវអាចជាថ្នាំពុល ហើយសរសើរត្រឹមអ្វីដែលគួរសរសើរ ទើបជាថ្នាំប៉ូវ បើសរសើរលើសពីការពិត ទៅជាការបញ្ឆោរទៅវិញ នេះជាថ្នាំពុល ។

**២. អនិស្សាយនរសា** មានការមិនច្រណែន ជាកិច្ច ។

៣. អរតិវិឃាតបច្ចុប្បដ្ឋានា មានការកម្ចាត់បង់នូវអរតិ (ការមិនត្រេកអរ ) ជាអាការប្រាកដ ។

៤. បរសម្បត្តិទស្សនបទដ្ឋានា មានការឃើញសម្បត្តិរបស់អ្នកដទៃ ជាហេតុជិត ។

## -សម្បត្តិ និង វិបត្តិ របស់មុទិតា ៖

១. មានការចូលទៅរម្ងាប់នូវអរតិ (ការមិនត្រេកអរ) ជាសម្បត្តិ។

២. មានការសើចសប្បាយ (ភ្ញាកភ្ញាយ ភ្លើតភ្លើនភ្លេចខ្លួន) ជា វិបត្តិ ។

ឧទាហរណ៍ ដូចពេលកូនបានប្រឡងជាប់ កូនបានទៅកូរ៉េ កូនបានតំណែង មកសប្បាយ មិនត្រឹមតែត្រេកអរ ធម្មតាទេ គឺ ជប់លៀង ស៊ីផឹក រាំ ច្រៀង ពេញហ្នឹង ។

៣. មានសោមនស្ស ដែលអាស្រ័យកាមគុណ ជាសត្រូវជិត ។

តើអ្វីជាសត្រូវ? អកុសលធម៌ទាំងអស់ (អកុសលចិត្ត ១២) ហ្នឹងជាសត្រូវ ហើយវាងាយនឹងកើតឡើងណាស់ សោមនស្ស កើតក្នុងលោភៈ ។

៤. មានការមិនត្រេកអរ (នឹងសុខ ឬសម្បត្តិរបស់អ្នកដទៃ) សត្រូវឆ្ងាយ។

-មុទិតា និង ករុណា គឺកើតផ្លាស់ប្តូរគ្នា ។

ឧទាហរណ៍ ថាយើងឃើញគេឈឺ អត់លុយព្យាបាល យើងជួយឱ្យលុយគាត់ព្យាបាលខ្លះនេះ គឺជា ករុណា ដល់គាត់បានព្យាបាលជំងឺនឹងជា ដល់យើងបានឮដំណឹងថាគាត់ជា យើងក៏ត្រេកអរនេះ ហៅថា មុទិតា ។

## -អប្បមញ្ញា ឬ ព្រហ្មវិហារធម៌ ៤

១. មេត្តា ព្រហ្មវិហារធម៌ អង្គធម៌ គឺ អទោសចេតសិក។

២. ករុណា ព្រហ្មវិហារធម៌ អង្គធម៌ គឺ ករុណាចេតសិក។

៣. មុទិតា ព្រហ្មវិហារធម៌ អង្គធម៌ គឺ មុទិតាចេតសិក។

៤. ឧបេក្ខា ព្រហ្មវិហារធម៌ អង្គធម៌ គឺតត្រមជ្ឈត្តតាចេតសិក។

## -ព្រហ្មវិហារធម៌

-ព្រហ្ម : ប្រសើរ ឧត្តុងឧត្តម

-វិហារ : ជម្រក ផ្ទះសម្បែង

-ធម៌ : គុណធម៌ សេចក្តីល្អ

-ព្រហ្មវិហារធម៌ គឺធម៌ជាជម្រកដ៏ប្រសើររបស់ចិត្ត ឬធម៌ជាជម្រកដ៏ត្រជាក់របស់ចិត្ត ។

# ១. មេត្តា

-មេត្តា  សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាចង់ឱ្យខ្លួនឯងបានសុខ និងចង់ឱ្យអ្នកដទៃបានសុខដូចគ្នា។

-មេត្តា  ការស្រឡាញ់រាប់អានស្មើៗគ្នា មិនថាមនុស្ស សត្វ ការស្រឡាញ់រាប់អានមិនរើសមុខ (ទោះបីមនុស្សនឹង ធ្វើល្អ ធ្វើអាក្រក់ ដាក់យើងក៏ដោយ មិនប្រកាន់ជនជាតិ មិនរើសអើង

វណ្ណៈទាប ខ្ពស់ ស្អាត អាក្រក់ ទាប ខ្ពស់នោះឡើយ )។

-មុនដំបូង ត្រូវចេះស្រឡាញ់ខ្លួនឯងជាមុនសិន រួចទើបផ្តល់សេចក្តីស្រឡាញ់ដល់អ្នកដទៃ។

-បើអ្នកមិនចេះស្រឡាញ់ខ្លួនឯងផង តើពោលថាស្រឡាញ់អ្នកដទៃដូចម្តេចបាន?

-រៀនផ្សាយមេត្តាដល់ខ្លួនឯងជាមុន ទើបផ្សាយមេត្តាដល់អ្នកដទៃជាក្រោយ។

-អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វ មិនមានប្រមាណ មិនមានដែនកំណត់។

-មេត្តា មានការស្រឡាញ់រាប់អានស្មើៗគ្នា នៃសត្វទាំងឡាយ ជាអារម្មណ៍ (ដូចជាម្តាយ ស្រឡាញ់កូន  ។

-នៅក្នុងករណីមេត្តសូត្រ ព្រះអង្គឱ្យយើងរៀនចម្រើនមេត្តាចិត្ត ឱ្យដូចជា មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ (ស្មើដោយជីវិត) សូម្បីតែលះបង់ជីវិតខ្លួនឱ្យតែកូនបានរស់ យ៉ាងណាមិញ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ចំពោះសត្វទាំងឡាយទាំងពួង យ៉ាងនោះឯង។

(បិដកលេខ ៥២ ករណីមេត្តសូត្រ ទំព័រ១៨~២០)

-យើងត្រូវរៀនចម្រើនមេត្តាចិត្ត ស្មើដូចជា ព្រះអាទិត្យ ព្រះចន្ទ ទឹក ដី ជាដើម ។

## -គុណធម៌មេត្តារបស់ព្រះសារីបុត្ត ៩ ចំណុច ៖

១. ស្មើដោយ ផែនដី

២. ស្មើដោយ ទឹក

៣. ស្មើដោយ ភ្លើង

៤. ស្មើដោយ ខ្យល់

៥. ស្មើដោយ សំពត់ជូតធូលី

៦. ស្មើដោយ ចណ្ឌាលកុមារ

៧. ស្មើដោយ គោឧសភបាក់ស្នែង

៨. ស្មើដោយ កម្ពោះ ក្រមុំ ខ្ទើមសាកសព

៩. ស្មើដោយ ភាជនៈសម្រាប់ដាក់ខ្លាញ់

(បិដកលេខ ៤៩ សីហនាទវគ្គ ទំព័រ៥៤~៥៥)

## -គន្លងនៃពាក្យទាំងឡាយនេះមាន ៥ ប្រការគឺ ៖

១. និយាយក្នុងកាលគួរ ឬមិនគួរ ១

២. និយាយដោយពាក្យពិត ឬមិនពិត ១

៣. និយាយដោយពាក្យល្អ ឬអាក្រក់ ១

៤. និយាយដោយពាក្យប្រកបដោយប្រយោជន៍ឬ
មិនប្រកបដោយប្រយោជន៍ ១

៥. និយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬទោសចិត្ត ១

-ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងគន្លងនៃពាក្យនោះយ៉ាងនេះថា ចិត្តរបស់យើងនឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា (ស្មើដោយផែនដី ស្មើដោយអាកាស ស្មើដោយទន្លេគង្គា ) ជាចិត្តធំទូលាយ ដល់នូវភាវៈជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឱ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ។

-ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងការ បៀតបៀនរបស់ចោរនោះថា ចិត្តរបស់យើងនឹងមិនប្រែប្រួល ផងយើងនឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះ ដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្ត ផង នឹងជាអ្នកចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គល នោះផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តធំ ទូលាយ ដល់នូវភាវៈជាធំ ប្រមាណមិនបាន មិនមានពៀរ មិន មានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឱ្យជា អារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

(បិដកលេខ ២១ កកចូបមសូត្រ ទំព័រ១៤~២៥)

## -មេត្តានិមិត្ត

-យើងយកព្រះសម្មាសម្ពុទ្ធជានិមិត្ត បុគ្គលដែលត្រូវចោរយក រណាមានដងទាំង ២ ខាង យកមកអារជើង ប្រសិនបើបុគ្គល នោះ ញ៉ាំងចិត្តឱ្យប្រទូស្តជាមួយចោរ ពោលពាក្យអាក្រក់ ជាមួយចោរ នោះឈ្មោះថា មិនរាប់អានតថាគត ។ ធ្វើឱ្យយើង មានសេចក្តីអត់ធន់ ចំពោះសេចក្តីក្រោធនឹងបាន ពីព្រោះយើង ស្រឡាញ់ព្រះអង្គ ។

-ព្រះពុទ្ធដីកា « សត្វណាដែលមិនធ្លាប់ជាមាតាបិតា បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី កូនប្រុស កូនស្រី ជាញាតិរបស់យើង គឺគេកម្រនឹងរកបានណាស់ក្នុងសង្សារវដ្តនេះ » ។

-ការធ្វើទានអស់ ១០០ខ្ទះក្នុងពេលព្រឹក ១០០ខ្ទះក្នុងពេលថ្ងៃត្រង់ ធ្វើទានអស់ ១០០ខ្ទះនៅក្នុងពេលល្ងាច តែប៉ុណ្ណោះប៉ុន្តែទាននោះនៅមិនស្មើនឹងបុគ្គលដែលបានចម្រើនមេត្តានោះ

ឡើយ។ មិនស្មើមួយរំពេចទឹកដោះគោនៃបុគ្គលចម្រើនមេត្តា គឺសភាពមិនប្រទូស្ត ការមិនបៀតបៀន មិនមានព្យាបាទ ដែលជាចិត្តប្រព្រឹត្តទៅចង់ឱ្យអ្នកដទៃបានសេចក្តីសុខ ។

-អរិសាវ័ក រមែងអនុគ្រោះពពួកសត្វដោយចិត្ត រមែងជួបប្រសព្វនូវបុណ្យដ៏ច្រើន គឺការផ្សាយមេត្តាចិត្តនេះឯង ការមិនមានព្យាបាទ ការមិនបៀតបៀនជាដើម ។

## -មេត្តាភាវនាមានអានិសង្ស ១១ ប្រការគឺ ៖

១. បុគ្គលនោះដេកលក់ជាសុខ

២. ភ្ញាក់ឡើងជាសុខ

៣. មិនយល់សប្តអាក្រក់

៤. ជាទីស្រឡាញ់របស់ពួកមនុស្ស

៥. ជាទីស្រឡាញ់របស់ពួកអមនុស្ស

៦. ពួកទេវតាតែងថែរក្សា

៧. ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ក៏មិនប៉ះពាល់ដល់បុគ្គលនោះ។

៨. ចិត្តបុគ្គលនោះ រមែងចូលទៅកាន់សមាធិដោយរួសរាន់

៩. បុគ្គលនោះមានពណ៌សម្បុរមុខស្រស់បស់

១០. បុគ្គលនោះមិនបានវង្វេងស្មារតី មុនធ្វើមរណកាល

១១. កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ខ្ពស់ទេ ជាអ្នកបានទៅកើតក្នុងព្រហ្មលោក ។

(បិដកលេខ ១៣ បរិវារៈ ទំព័រ ១០៨)

# ២. ករុណា

-ករុណា ការអាណិតអាសូរ (ជួយសង្គ្រោះនៅពេលសត្វមានទុក្ខ) ។

-ករុណា មាន ទុក្ខិតសត្តប្បញ្ញត្តិ សេចក្តីទុក្ខរបស់សត្វ ជាអារម្មណ៍ ។

ឧទាហរណ៍ ថាឃើញគេដួលម៉ូតូ ដួលកង់ ឃើញសត្វលង់ទឹក ឃើញមនុស្សចាស់ពិបាកឆ្លងផ្លូវ...។

ឧទាហរណ៍ យើងជិះរថភ្លើងឬក៏ឡានក្រុង ឃើញមនុស្សចាស់ មនុស្សមានផ្ទៃពោះ គាត់អត់កន្លែងអង្គុយ យើងឃើញគាត់ពិបាក យើងមានចិត្តអាណិតគាត់ ឱ្យកន្លែងគាត់អង្គុយ។

ឧទាហរណ៍ ថាអ្នកខ្លះមានវិបត្តិផ្លូវចិត្ត យើងមានចិត្តអាណិតទៅជួយពន្យល់គាត់...។

ឧទាហរណ៍ ថាអ្នកខ្លះមានជំងឺ នឹងអត់មានលុយមើល...។

-អ្នកខ្លះអត់បាយហូបយើងអាណិតគាត់ជួយគាត់...។

# ៣. មុទិតា

-មុទិតា ការត្រេកអរនឹងអ្នកដទៃបានសុខ (ចំពោះសេចក្ដីសុខ ឬសម្បត្តិរបស់អ្នកដទៃ)។

-មុទិតា មាន សុខិតសត្តប្បញ្ញត្តិ (សេចក្ដីសុខ ឬសម្បត្តិរបស់សត្វ ជាអារម្មណ៍ ។

ឧទាហរណ៍ នៅពេលយើងឃើញគេ រៀនធម៌ ស្ដាប់ធម៌គេបានយល់ដឹងច្រើនក៏ត្រេកអរនឹងអ្នកដទៃបានសុខ។

ឧទាហរណ៍ ថាឃើញអ្នកដទៃនឹង រកស៊ីមានបាន មានលុយ មានឡាន មានផ្ទះ... គ្រួសារគេមានសេចក្ដីសុខ មានកូននឹងល្អ គេរៀនពូកែ គេធ្វើសេចក្ដីល្អ មានការធ្វើទាន រក្សាសីល ចម្រើនភាវនាជាដើម រួចក៏ត្រេកអរនឹងអ្នកដទៃបានសុខ។

នៅពេលដែលយើងត្រេកអរនឹងសេចក្ដីល្អដែលខ្លួនធ្លាប់បានធ្វើ មិនមែនជា មុទិតាទេ គឺជាអនុស្សតិទៅវិញ មានចាគានុស្សតិសីលានុស្សតិ ពុទ្ធានុស្សតិជាដើម។

ឧទាហរណ៍ ថាយើងធ្វើទាន ដល់យើងរឭកចំពោះសេចក្ដីល្អ អំពើល្អ មានទាននឹងជាអារម្មណ៍ វាទៅជាចាគានុស្សតិទៅវិញ ។

ឧទាហរណ៍ ថាយើងរក្សាសីល ដល់យើងរឭកចំពោះសេចក្ដីល្អ មានសីលនឹងជាអារម្មណ៍ វាទៅជាសីលានុស្សតិទៅវិញ។

-បើអារម្មណ៍ជាបរមត្ថ ក៏អាចអនុមោទនាបានដែរ ដូចជាយើងឃើញដល់អំពើល្អដែលជា គួចេតនាល្អ រួចយើងត្រេកអរជាមួយអំពើល្អនោះ វារួចផុតពី សត្វ បុគ្គល អត់មានមុទិតាទេ ។

-រីឯមុទិតា មានសត្វ បុគ្គលជាអារម្មណ៍ (បញ្ញត្តិ) ។

-បើមហាកុសលប្រកបដោយឧបេក្ខា អាចមានមុទិតាដែរឬទេ? មាន តែកុំប្រែថា ត្រេកអរ គឺប្រែថា ឯកភាព មិនជំទាស់ចំពោះនឹងសេចក្ដីសុខរបស់អ្នកដទៃ ។

# ៤. ឧបេក្ខា

-ឧបេក្ខា ការតាំងចិត្តកណ្ដាលក្នុងធម៌នោះៗ ឬភាពប្រងើយនៃចិត្ត (ប្រកបដោយភាពយុត្តិធម៌មិនលម្អៀងដោយអគតិធម៌ទាំង ៤ ប្រការ) ។

-ឧបេក្ខា មាន ការតាំងចិត្តកណ្ដាល ចំពោះសត្វ ជាអារម្មណ៍ ។ (ទោះបីគេធ្វើល្អ ឬក៏ធ្វើអាក្រក់ ជាមួយយើងក៏ចិត្តយើងតាំងស្មើជាមួយសព្វសត្វទាំងឡាយនោះ) ។

## -អគតិធម៌ទាំង ៤ ប្រការ

១. ឆន្ទាគតិ ការលម្អៀងព្រោះស្រឡាញ់ ។

២. ទោសាគតិ ការលម្អៀងព្រោះស្អប់ ។

៣. មោហាគតិ    ការលម្អៀងព្រោះល្ងង់ ។

៤. ភយាគតិ      ការលម្អៀងព្រោះខ្លាច ។

-មិនញាប់ញ័រ នៅក្នុងលោកធម៌ទាំង ៨ និងអាយតនៈទាំង ៦ គឺលក្ខណៈសាមញ្ញធម្មតាៗ ព្រោះឃើញធម៌តាមសេចក្តីពិត។

ឧទាហរណ៍ ថាគេជេរយើង គេសរសើរយើង ចិត្តយើងតាំងស្មើនូវ ភាពជាកណ្តាល ។

ឧទាហរណ៍ ដូចជាឃើញវេទនាតាមសេចក្តីពិត (ទោះបីសុខវេទនាពាល់ត្រូវក្តី ទុក្ខវេទនាពាល់ត្រូវក្តី ឧបេក្ខាវេទនាពាល់ត្រូវក្តី ចិត្តយើងតាំងស្មើនូវ ភាពជាកណ្តាល ok បានទាំងអស់ ពេលនោះឯងបុគ្គលនោះមានទីពឹង ។

-ការឃើញ កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត ព្រោះធម៌គ្រប់យ៉ាង មិនទៀង មិនឋិតថេរ មានវេទនាទាំង ៣ ជាដើម កើតពីបច្ច័យ ដូច្នេះហើយទើបតណ្ហាកើតលែងបានតទៅទៀត ចឹងចិត្តរបស់លោក ប្រងើយចំពោះសង្ខារទាំងឡាយដល់ញាណទី ១១ គឺ សង្ខារុបេក្ខាញាណ ញាណដែលប្រងើយចំពោះសង្ខារទាំងឡាយ (ប្រងើយជាមួយ កាយ វេទនា ចិត្ត ធម៌ ឬខន្ធ ៥) ។

-ឧបេក្ខា នៅក្នុងចិត្ត គឺជាវេទនា សភាពប្រងើយនៃចិត្ត ដែល មិនសោមនស្សនិង មិនទោមនស្ស ។

-ឧបេក្ខា នៅខាងក្នុងព្រហ្មវិហារធម៌ អាចកើតឡើងបានក្នុង សោមនស្សវេទនាក៏បាន ឧបេក្ខាវេទនាក៏បាន។

-ឧបេក្ខា ក្នុងព្រហ្មវិហារធម៌ ចំពោះកូន គឺការសម្លឹងមើល អនាគតកូន (កូនរៀនអ្វី ធ្វើការងារអ្វី) ។

-អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វ មិនមានប្រមាណ មិនមានដែនកំណត់ ។

-យើងគ្រប់ៗគ្នាជាធម្មតា អប្បមញ្ញានេះ នៅមានកម្រិតនៅ

ឡើយ។ បើស្រឡាញ់ទាល់តែ កូនអញ ញាតិអញ ក្រុមអញ អ្នកធ្វើល្អជាមួយអញ... ទើបអញ មេត្តា ករុណា មុទិតា ឧបេក្ខា ជាមួយ ។

-អប្បមញ្ញា ដល់កើតឡើងមែនទែន ឈប់មានដែនកំណត់ ទៀតហើយ ឈប់មានជនជាតិអីទៀតហើយ ។

-អញស្រឡាញ់តែខ្មែរ អញស្អប់យួន អញស្រឡាញ់តែឆ្កែ សត្វ ឆ្មា ចឹងចក់ សត្វពស់អញមិនស្រឡាញ់ទេ គឺអត់មានអីចឹងទេ គឺមានចិត្ត មេត្តា ករុណា មុទិតា ឧបេក្ខា ស្មើៗគ្នាគ្រប់សព្វសត្វ ទាំងឡាយ។

# -អប្បមញ្ញា ឬ ព្រហ្មវិហារធម៌ ៤

១. មេត្តា ព្រហ្មវិហារធម៌ អង្គធម៌ គឺ អទោសចេតសិក។

២. ករុណា ព្រហ្មវិហារធម៌ អង្គធម៌ គឺ ករុណាចេតសិក។

៣. មុទិតា ព្រហ្មវិហារធម៌ អង្គធម៌ គឺ មុទិតាចេតសិក។

៤. ឧបេក្ខា ព្រហ្មវិហារធម៌ អង្គធម៌ គឺតត្រមជ្ឈត្តតាចេតសិក។

-អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វ មិនមានប្រមាណ មិនមានដែនកំណត់។

-មេត្តា មានការស្រឡាញ់រាប់អានស្មើៗគ្នា នៃសត្វទាំងឡាយ ជាអារម្មណ៍ (ដូចជាម្ដាយ ស្រឡាញ់កូន ។

-ករុណា មាន ទុក្ខិតសត្តប្បញ្ញត្តិ សេចក្ដីទុក្ខរបស់សត្វ ជាអារម្មណ៍ ។

-មុទិតា មាន សុខិតសត្តប្បញ្ញត្តិ (សេចក្ដីសុខ ឬសម្បត្តិរបស់សត្វ ជាអារម្មណ៍។

-ឧបេក្ខា មាន ការតាំងចិត្តកណ្ដាល ចំពោះសត្វ ជាអារម្មណ៍ ។ (ទោះបីគេធ្វើល្អ ឬក៏ធ្វើអាក្រក់ ជាមួយយើងក៏ចិត្តយើងតាំងស្មើ ជាមួយសព្វសត្វទាំងឡាយនោះ ។

# ២៥. បញ្ញាចេតសិក

-សម្មាទិដ្ឋិ អង្គធម៌ បានដល់ បញ្ញាចេតសិក ។

-បជានាតីតិ = បញ្ញា ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងទូទៅ គឺ ដឹងអរិយសច្ចធម៌ ៤ ជាដើម (មានទុក្ខសច្ចៈជាដើម) ។

-បញ្ញា នោះឯង ជាឥន្ទ្រិយ (ជាធំក្នុងការដឹងច្បាស់នូវសភាវធម៌) ព្រោះហេតុនោះ ទើបឈ្មោះថា បញ្ញិន្ទ្រិយ ។

## -ម្នាលភិក្ខុទាំងឡាយ បញ្ញា តើដូចម្តេច?

១. ការដឹងច្បាស់ក្នុងទុក្ខ

២. ការដឹងច្បាស់ក្នុងហេតុដែលនាំឱ្យកើតទុក្ខ

៣. ការដឹងច្បាស់ក្នុងទីរម្លត់ទុក្ខ

៤. ការដឹងច្បាស់ក្នុងបដិបទាជាដំណើរទៅកាន់ទីរម្លត់ទុក្ខ។

-ព្រះពុទ្ធ បញ្ញាយ បរិសុជ្ឈតិ សត្វបរិសុទ្ធបានដោយបញ្ញា ។

-បជានាតិ គឺ ដឹងច្បាស់ អង្គធម៌បានដល់ បញ្ញាចេតសិក ។

-បញ្ញា មានឈ្មោះហៅច្រើន ញាណ សម្បជញ្ញៈ វិបស្សនា កតញ្ញូ ។

-កតញ្ញូ គឺការដឹងគុណ ។

-សម្បជញ្ញៈ គឺសេចក្តីដឹងខ្លួន អង្គធម៌ បានដល់ បញ្ញាចេតសិក។

-អនុបស្សនា មានន័យថា តាមឃើញ តាមដឹង តាមពិចារណា តាមមើលរឿយៗ (តាមមើល កាយ វេទនា ចិត្ត ធម៌ តាមមើល កាយនេះ ធ្វើអីខ្លះ?) អង្គធម៌បានដល់ បញ្ញាចេតសិក ។

-អនុបស្សនា និង សម្បជញ្ញៈ គឺគ្រាន់តែខុសគ្នាដោយព្យញ្ជនៈ ទេប៉ុន្តែ អត្ថដូចគ្នាអង្គធម៌ បានដល់ បញ្ញាចេតសិកដូចគ្នា ។

## -តើមុនទៅធ្វើ វិបស្សនា គួរទៅរៀនអ្វី?

-យើងត្រូវរៀនពាក្យវិបស្សនា ឱ្យយល់ជាមុនសិន ។

-វិបស្សនា ប្រែថា ឃើញច្បាស់ ដឹងច្បាស់ ឬ ឃើញដោយវិសេស ដឹងដោយវិសេស អង្គធម៌បានដល់ បញ្ញាចេតសិក ។

-វិ + បស្ស  វិ ប្រែថា ច្បាស់ ឬក៏ ដោយវិសេស។

-បស្ស ប្រែថា ឃើញ។

-តើឃើញអ្វី? តើច្បាស់អ្វី?

គឺឃើញ កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត។

គឺដឹងច្បាស់ កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត។

-វិបស្សនា គ្មានរូបភាព គ្មានទម្រង់អ្វីទេ តាមពិតទៅតួវិបស្សនា គឺតួនាមធម៌សុទ្ធ អង្គធម៌នៃវិបស្សនា គឺបានដល់ តួ បញ្ញាចេតសិក ។

-បញ្ញានោះ មានលក្ខណៈឃើញដោយវិសេស ឃើញប្លែកពីយើងឃើញរាល់ថ្ងៃ គិតរាល់ថ្ងៃ យើងឃើញ យើងឮ យើងធំក្លិន យើងដឹងរស យើងដឹងផោដ្ឋព្វៈ យើងគិតរាល់ថ្ងៃ នេះគឺជាការដឹងរឿងក្លែងក្លាយ ដល់ពេលវិបស្សនាកើតឡើងគឺឃើញរឿងមែនទែន តាមសេចក្តីពិត ឃើញ កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត។ តួវិបស្សនា គឺជាតួបញ្ញាដែលឃើញរឿងពិតពិតយ៉ាងណា ដឹងយ៉ាងនោះ ធម្មជាតិយ៉ាងម៉េច គឺឃើញអ៊ីចឹង គឺអត់ឃើញរបស់ក្លែងក្លាយទេ ។

-យើងមើលគ្នារាល់ថ្ងៃ តើយើងឃើញអ្វី? ឃើញតែរបស់ក្លែងក្លាយ យើងឃើញប្រុស ឃើញស្រី ឃើញកូន ឃើញប្តី ឃើញប្រពន្ធ ឃើញឪពុកម្តាយហ្នឹងមែនទែន ឃើញលុយ ឃើញមាស ឃើញប្រាក់ ឃើញឡាន ឃើញវីឡា នាំឱ្យយើងកើតសេចក្តីលោភលន់ ការច្រណែន ខឹង ស្អប់ និន្ទា កើតឡើង

-តើមកពីអ្វី? មកពីវិបស្សនាវាមិនកើតឡើង បើវិបស្សនាអត់កើតឡើងកិលេស កើតឡើងជំនួសឃើញវិញម្តង ឃើញទេ?

-វិបស្សនា ឃើញ « យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធ ធម្មន្តិ »
ធម្មជាតិណា មានការកើតឡើងជាធម្មតា ធម្មជាតិនោះរមែង
រលត់ទៅវិញជាធម្មតា ។

-(ធម្មជាតិទាំងនោះមានបច្ច័យទើបកើតឡើង ដល់អស់បច្ច័យ
ក៏រលត់ទៅវិញជាធម្មតា) ធម្មជាតិ បានដល់ ចិត្ត ចេតសិក រូប។

ញាណចក្ខុ (ភ្នែកបញ្ញា) ឃើញធម៌ ដំបូងគឺឃើញបែបនេះឯង។

-នៅក្នុងសតិសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា៖

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវជាអ្នកមានស្មារតី ជាអ្នកដឹងខ្លួន
នេះជាអនុសាសនី គឺជាពាក្យប្រៀនប្រដៅរបស់តថាគតចំពោះ
អ្នកទាំងឡាយ ។

-ស្មារតី អង្គធម៌ សតិចេតសិក។

-ដឹងខ្លួន គឺសម្បជញ្ញៈ អង្គធម៌ បញ្ញាចេតសិក។

-សតិមា គឺអ្នកមានស្មារតី គឺពោលទៅលើបុគ្គលបញ្ញត្តិ ដល់
ពេល សតិ (ស្មារតី) គឺបានដល់ សតិចេតសិក ជាបរមត្ថ។

-អនុសាសនី គឺជាពាក្យប្រៀនប្រដៅរឿយៗ ទូន្មានហើយ
ទូន្មានទៀត។ ទូន្មានម្តង ហៅថា ឱវាទ ។

-សម្បជានោ គឺអ្នកសេចក្តីដឹងខ្លួន គឺពោលទៅលើបុគ្គលបញ្ញត្តិ ដល់ពេល សម្បជញ្ញៈ (សេចក្តីដឹងខ្លួន) គឺបានដល់ បញ្ញាចេតសិក ជាបរមត្ថ ។

## -សិក្សា បទថា សតិ

## -ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ជាគ្រឿងកំណាត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ១ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ពិចារណានូវចិត្តក្នុងចិត្តទាំងឡាយ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ជាគ្រឿងកំណាត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី យ៉ាងនេះឯង ។

## -ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួន តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងការដើរទៅមុខ និងថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលក្រឡេកមើលទៅខាងមុខ និងក្រឡេកមើលទិសផ្សេ

ឯៗ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលបត់ដៃជើង និងលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលទ្រទ្រង់នូវសំពត់សង្ឃាដិ បាត្រ និងចីវរ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលបរិភោគភោជន ផឹកទឹក ទំពាស៊ី (ខាទនីយវត្ថុ) ជញ្ជាប់រស ធ្វើនូវសេចក្តីដឹងខ្លួនក្នុងការ បន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាល ដើរ ឈរ អង្គុយ លក់ ភ្ញាក់ឡើង និយាយ និងនៅស្ងៀម ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួន យ៉ាងនេះឯង ។

-អនុសាសនី គឺជាពាក្យប្រៀនប្រដៅរឿយៗ ទូន្មានហើយទូន្មានទៀត។ ទូន្មានម្តង ហៅថា ឱវាទ ។

(បិដកអដ្ឋកថាលេខ ២៤ សតិសូត្រទី ២ ទំព័រ១៣~៤៥)

## -អវិជ្ជា គឺសេចក្តីមិនដឹងក្នុងធម៌ ៨ យ៉ាង

## -វិជ្ជា គឺការដឹងច្បាស់ក្នុងធម៌ ៨ យ៉ាង

១. សេចក្តីដឹងក្នុងទុក្ខសច្ចៈ

២. សេចក្តីដឹងក្នុងទុក្ខសមុទយសច្ចៈ

៣. សេចក្តីដឹងក្នុងទុក្ខនិរោធសច្ចៈ

៤. សេចក្តីដឹងក្នុងមគ្គសច្ចៈ

៥. សេចក្តីដឹងក្នុងខន្ធ អាយតនៈ ធាតុ ជាអតីត

៦. សេចក្តីដឹងក្នុងខន្ធ អាយតនៈ ធាតុ ជាអនាគត

៧. សេចក្តីដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និង អនាគត

៨. សេចក្តីដឹងក្នុងបដិច្ចសមុប្បាទធម៌ គឺដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាទើបកើតឡើង (ធម៌កើតពីបច្ច័យ)។

## -ការកំណត់នូវអវិជ្ជា

## -អវិជ្ជា មានវិជ្ជាជាគ្រឿងប្រៀបធៀប

-វិជ្ជា ដឹងនៅក្នុងសច្ចធម៌ ៤ មានទុក្ខសច្ចៈ ជាដើម។

-អវិជ្ជា មិនដឹងនៅក្នុងសច្ចធម៌ ៤ មានទុក្ខសច្ចៈជាដើម។

-វិជ្ជា ដឹងថាមិនទៀង ជាទុក្ខ ជាអនត្តា។

-អវិជ្ជា ដឹងថាទៀង ជាសុខ ជាអត្តា។

-វិជ្ជា ដឹងថា នុ៎ះមិនមែនអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។

-អវិជ្ជា ដឹងថា នុ៎ះជាអញ នុ៎ះជារបស់អញ នុ៎ះជាខ្លួនរបស់ អញ ។

# -លក្ខណាទិចតុក្កៈរបស់ បញ្ញា

១. ធម្មសភាវបដិវេធលក្ខណា មានការចាក់ធ្លុះសភាវៈនៃធម៌ (នាម រូប) ជាលក្ខណៈ ។

-គឺឃើញនាម រូបតាមសេចក្ដីពិត ដែលតាំងនៅក្នុងត្រៃលក្ខណ៍ ធម៌ឬ សាមញ្ញលក្ខណៈ ( អនិច្ចំ ទុក្ខំ អនត្តា ) ។

២. ធម្មានំ សភាវបដិច្ឆាទកមោហន្ធការវិទ្ធំសនរសា មានការកម្ចាត់បង់នូវភាពងងឹត គឺមោហៈ ដែលបិទបាំងសភាវធម៌ ជាកិច្ច ។

៣. អសម្មោហបច្ចុប្បដ្ឋានា មានការមិនវង្វេង ជាអាការប្រាកដ (ដូចមគ្គុទ្ទេសក៍ដ៏ចំណាន) ។

-វង្វេងក្នុងទីនេះ គឺមិនដឹងនាម រូប តាមសេចក្ដីពិត មិនដឹងសេចក្ដីសុខ ទុក្ខ កើតអំពីអ្វីតាមសេចក្ដីពិត ។

៤. សមាធិបទដ្ឋានា មានសមាធិ ជាហេតុជិត ។

# -លក្ខណាទិចតុក្កៈរបស់ បញ្ញា ន័យម៉្យាងទៀត

១. យថាភូតបដិវេធលក្ខណា មានការចាក់ធ្លុះ (ដឹងច្បាស់)
នូវធម៌តាមសេចក្តីពិត ជាលក្ខណៈ ។

-គឺដឹងច្បាស់នូវ កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត ។

២. វិសយោភាសនរសា មានការចាក់ធ្លុះបញ្ចាំងនូវអារម្មណ៍ឱ្យ
ភ្លឺច្បាស់ ជាកិច្ច (ដូចប្រទីបជាគ្រឿងបំភ្លឺ) ។

-បញ្ញា គឺដឹងច្បាស់តែម្តង រូបដែលប្រាកដតាមផ្លូវភ្នែកត្រឹមតែ
ជា វណ្ណៈ(ពណ៌) សំឡេងដែលប្រាកដតាមផ្លូវត្រចៀកត្រឹមតែ
ជាសទ្ទៈ ផោដ្ឋព្វៈដែលប្រាកដតាមផ្លូវកាយត្រឹមតែជាកាយ
វិញ្ញាណជាដើម ។

ឧទាហរណ៍ ថាវេទនាកើតឡើងត្រឹមតែជាវេទនា...។

ឧទាហរណ៍ ចិត្តកើតឡើងត្រឹមតែជាចិត្ត... ។

៣. អសម្មោហបច្ចុប្បដ្ឋានា មានការមិនវង្វេង ជាអាការប្រាកដ ។

៤. យោនិសោមនសិការបទដ្ឋានា មានយោនិសោមនសិការ
ជាហេតុជិត ។

តិហេតុកបដិសន្ធិកតាបទដ្ឋានា វា ឬតិហេតុកបដិសន្ធិ(បដិសន្ធិ
ដោយហេតុ ៣ គឺ អលោភៈ អទោសៈ អមោហៈ) ជាហេតុជិត ។

-បញ្ញាចេតសិត នេះការកើតឡើង រមែងដឹងទូទៅដល់ធម៌ទាំងឡាយ ដែលជាកុសល ជាអកុសល ធម៌ដែលគួរសេព ធម៌ដែលមិនគួរសេព ដឹងធម៌ណាដែលជាប្រយោជន៍ ធម៌ណាដែលមិនជាប្រយោជន៍ ដឹងធម៌ណាដែលនាំទៅរកសេចក្តីសុខធម៌ណាដែលនាំទៅរកសេចក្តីទុក្ខ ដឹងធម៌ដែលអាក្រក់ ធម៌ដែលប្រណីត ធម៌ដែលចូលគ្នាបាន និងធម៌ដែលចូលគ្នាមិនបាន ដូចពេទ្យអ្នកជំនាញអាចផ្សំភេសជ្ជៈគឺថ្នាំ ដែលជាទីសប្បាយដល់អ្នកជំងឺជាដើមដូច្នោះ។

-សតិ គឺការរឭក ការមានស្មារតី (នៅក្នុង កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត) មិនមែនមានស្មារតី ក្នុងរឿងដទៃឡើយ។

-បញ្ញា គឺ ការដឹងទូទៅ (គឺដឹងអរិយសច្ចធម៌ ៤ ជាដើម) ឬ

ការដឹងច្បាស់ (នៅក្នុង កាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត) មិនមែនដឹងច្បាស់ ក្នុងរឿងដទៃឡើយ ។

ឧទាហរណ៍ មិនមែនមានស្មារតីឬក៏ដឹងច្បាស់ នៅក្នុងរឿង

ខ្លួនដាំបាយ ខ្លួនងងុយដេក ខ្លួនអ្នកខឹង ខ្លួនឈឺពោះ ឈឺក្បាល ឈឺធ្មេញ...ការមានស្មារតី ការដឹងច្បាស់បែបនេះ គឺជាការដឹងដោយទិដ្ឋិ ការដឹងដោយអវិជ្ជា ប៉ុណ្ណោះ ។

-ការដឹងច្បាស់ ការមានស្មារតី នៅក្នុងកាយ វេទនា ចិត្ត ធម៌ តាមសេចក្តីពិត ។

-ដឹងថាចិត្តប្រកបដោយថីនមិទ្ធៈ (ងងុយងោកងក់) កើតឡើង ។
-ដឹងថាចិត្តប្រកបដោយរាគៈ (ចិត្តជាប់ជំពាក់) កើតឡើង ។
-ដឹងថាចិត្តប្រកបដោយទោសៈ (ចិត្តប្រទូស្ត) កើតឡើង ។
-ដឹងថាទុក្ខវេទនាកើតឡើង ដឹងថាសុខវេទនាកើតឡើង ។
-នេះ ជាការដឹងត្រូវ គឺការដឹងដោយសតិ និងបញ្ញា ។

## -សិក្សា បទថា សម្មាទិដ្ឋិ

### -សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច?

-បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតដូចផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងឆ្លុះគឺបញ្ញា រតនៈ គឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិកើតមានក្នុងសម័យនោះ ។

(បិដកអដ្ឋកថាលេខ ៦៤ ទំព័រ៤២៣)

# -សម្មាទិដ្ឋិ

-ម្នាលភិក្ខុទាំងឡាយ បណ្តាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន (ជាប្រធាន) ។

-ម្នាលភិក្ខុទាំងឡាយ ឯសម្មាទិដ្ឋិ ជាធម្មជាតិដល់មុន តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិ ដឹងច្បាស់នូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ ។ សេចក្តីដឹងនោះជាសម្មាទិដ្ឋិរបស់បុគ្គលនោះ ។

-ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ថាទានដែលបុគ្គលឱ្យហើយមិនមានផល គ្រឿងបូជាតូច មិនមានផល គ្រឿងបូជាធំ មិនមាននផល ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អ និងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វជាឱបបាតិកមិនមាន ពួកសមណព្រាហ្មក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិត្រូវ ធ្វើឱ្យ ជាក់ច្បាស់ ដ៏ប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ត្រាស់ដឹងនូវលោកនេះ និងលោកខាងមុខមិនមាន នេះ ហៅថា មិច្ឆាទិដ្ឋិ ។

-ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិ តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងនូវសម្មាទិដ្ឋិ ថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ គឺសម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឱ្យផលជាឧបធិក្កិលេស ក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

-ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យឱ្យផលជាឧបធិក្កិលេស តើដូចម្តេច?

-ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ថាទានដែលបុគ្គលឱ្យហើយមានផល បូជាតូចមានផល បូជាធំមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អ និងអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ សត្វជាឱបបាតិកមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិត្រូវ ធ្វើឱ្យ ជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ត្រាស់ដឹងនូវលោកនេះ និងលោកខាងមុខក៏មាន ម្នាលភិក្ខុទាំងឡាយ នេះហៅថា សម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឱ្យផលជាឧបធិក្កិលេស ។

-ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ តើដូចម្ដេច?

-ម្នាលភិក្ខុទាំងឡាយ បញ្ញា បញ្ញិន្រ្ទិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គៈ សម្មាទិដ្ឋិ អង្គនៃមគ្គរបស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ អ្នកបរិបូណ៌ដោយអរិយមគ្គ អ្នកចម្រើននូវអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា សម្មាទិដ្ឋិដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ ។ បុគ្គលនោះ ព្យាយាមដើម្បីលះបង់នូវមិច្ឆាទិដ្ឋិ បំពេញនូវសម្មាទិដ្ឋិ សេចក្ដីព្យាយាមនោះ ឈ្មោះថា សម្មាវាយាមរបស់បុគ្គលនោះ ។ បុគ្គលនោះ មានសតិលះបង់នូវមិច្ឆាទិដ្ឋិ មានសតិផ្ដេកផ្ដួលចិត្តទៅរកសម្មាទិដ្ឋិ ។ សតិនោះ ជាសម្មាសតិរបស់បុគ្គលនោះ ។ ធម៌ទាំង ៣ ប្រការនេះ គឺសម្មាទិដ្ឋិ សម្មាវាយាម សម្មាសតិ តែងតាម ចោមរោមនូវសម្មាទិដ្ឋិ ដោយប្រការដូច្នោះឯង ។

(បិដកអដ្ឋកថាលេខ ១៧ សម្មាទិដ្ឋិសូត្រ ទំព័រ៧៦២)

## -ហេតុនាំឱ្យកើតបញ្ញាមាន ៣ យ៉ាងគឺ ៖

១. សុតមយបញ្ញា បញ្ញាកើតឡើងពីការស្តាប់ ឬបញ្ញាសម្រេចពីការស្តាប់ (ការសិក្សារៀនសូត្រធម៌ និងស្តាប់ព្រះធម៌) ។

២. ចិន្តាមយបញ្ញា បញ្ញាកើតឡើងពីការគិត ពិចារណា ឬបញ្ញាសម្រេចពីការគិត ពិចារណា ។

៣. ភាវនាមយបញ្ញា បញ្ញាកើតឡើងពីការចម្រើនភាវនា មានការចម្រើន សមថៈវិបស្សនា សតិប្បដ្ឋាន ៤ ជាដើម (បញ្ញា ផ្ទាក់ពិសោធន៍ អង្គធម៌ បានដល់ សតិ និងបញ្ញា)។

ភាវនាមយបញ្ញានេះ មានតែព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធប៉ុណ្ណោះ ទើបអាចចម្រើន ភាវនាមយបញ្ញា រួចអាចត្រាស់ដឹងធម៌ដោយខ្លួនឯងបាន។ ក៏ប៉ុន្តែចាប់ពី ព្រះសារីបុត្ត ចុះមកក្រោម គឺសុទ្ធតែចាប់ផ្តើមពី សុតមយបញ្ញា រួច ចិន្តាមយបញ្ញា កើតឡើងបន្តបន្ទាប់ រហូតដល់ភាវនាមយបញ្ញា កើតឡើងទើបអាចត្រាស់ដឹងសច្ចធម៌បាន ។

-ភាវនា គឺការចម្រើន ការឱ្យធ្វើច្រើន ការធ្វើឱ្យរឿយៗ ។

-តើចម្រើននូវអ្វី? គឺចម្រើននូវសតិ បញ្ញា ចម្រើនដោយការពិសោធន៍ផ្ទាល់ចំពោះសភាវធម៌ដែលកំពុងប្រាកដ ។

-ភាវនាមយបញ្ញា គឺបញ្ញាថ្នាក់ពិសោធន៍ក្នុងជីវិតប្រចាំថ្ងៃនេះ ឯង ក្នុងសតិប្បដ្ឋាន ៤ ជាដើម មាន(កាយ វេទនា ចិត្ត ធម៌) ។

-ការចម្រើន សតិ បញ្ញា ក្នុងជីវិតប្រចាំថ្ងៃ តាមទ្វារទាំង ៦ មាន (ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត) ខណៈពេលឃើញ ត្រឹមតែជាការឃើញ ខណៈពេលឮត្រឹមតែជាការឮ...ជាដើម ដឹងរឿយៗ ក្នុងជីវិតប្រចាំថ្ងៃ ។

## -តើការស្តាប់ធម៌ក៏អាចសម្រេចមគ្គផលបានដែរ?

បាន ព្រោះបញ្ញា ទាំង ៣ នេះ កើតឡើងមកដល់ព្រម ។

-ដូចជាក្នុងសម័យពុទ្ធកាលមនុស្សច្រើនណាស់ គាត់គ្រាន់តែស្តាប់ធម៌ក៏អាចសម្រេចធម៌បានដែរ គឺត្រឹមតែស្តាប់ព្រោះគេមិនមានជំនឿថា ការស្តាប់មិនសម្រេចធម៌ ដល់គេស្តាប់គេខ្វះទៅរកសច្ចធម៌តែម្តង ព្រះអង្គសម្តែងអ្វីគាត់បង្អោនចិត្តទៅតាមអ្វីដែលព្រះអង្គសម្តែង បញ្ញានឹងផុសឡើង មកឃើញសច្ចធម៌ពេលនឹងតែម្តង ព្រោះអ្វី? ព្រោះគេអត់មានជំនឿថាបញ្ញាវានឹងឈប់កើតឡើង មិនអាចឃើញសច្ចធម៌នឹងបាន។

-ធម៌ទាំងឡាយកើតពីហេតុ មានហេតុបច្ច័យ ទើបកើតឡើង មិនថាកុសល ឬអកុសលឡើយ ។

-សតិ បញ្ញាក៏មិនរើសពេលវេលា អកុសលក៏មិនរើសពេលវេលាដែរ អកុសលយើងមិនបង្កើតយ៉ាងណា សតិ បញ្ញាក៏ដូចគ្នាក៏ហេតុបច្ច័យគ្រប់គឺកើតឡើងហើយ ។

-ប៉ុន្តែបុគ្គលខ្លះស្តាប់ធម៌ហើយក៏មិនអាចសម្រេចភ្លាមៗទេ គឺត្រូវយកទៅគិត ពិចារណា យកទៅចម្រើនភាវនា តទៅទៀត ទើបអាចសម្រេចមគ្គផលបានក៏មាន ។



## III. លំដាប់នៃព្រះសទ្ធម្ម មាន ៣ គឺ ៖

១. **បរិយត្តិ** គឺការសិក្សានូវព្រះពុទ្ធវចនៈ (ព្រះត្រៃបិដក) ។

-បរិយត្តិ គឺមានន័យថាការដល់ដ៏ជុំវិញ (ទាំងអត្ថ និង ព្យញ្ជនៈ) ការដល់ដ៏ជុំវិញ ទាំងអត្ថ និង ព្យញ្ជនៈ ទើបឈ្មោះថា អ្នកយល់ធម៌ ។

២. **បដិបត្តិ** គឺការបដិបត្តិតាមពុទ្ធវចនៈដែលបានសិក្សានោះ មានសមថ និងវិបស្សនាជាដើម ។

-បដិបត្តិ គឺមានន័យថា ការដល់ដោយចំពោះ (សភាវធម៌ដែលកំពុងប្រាកដ) អង្គធម៌បានដល់ សតិចេតសិក និងបញ្ញាចេតសិក ។

-អ៊ីចឹងហើយអ្នកសិក្សាធម៌ទាំងឡាយ ត្រូវឈ្លាស ត្រូវសិក្សាសង្កត់ធ្ងន់នូវធម៌ណា ដែលសមគួរដល់ សតិ និង បញ្ញា របស់ខ្លួនអាចពិសោធន៍បាន ទើបអាចឈានដល់ បដិវេធទៅបាន ប៉ុន្តែធម៌ខ្លះ សតិ និង បញ្ញា យើងលូកមិនដល់ ពិសោធន៍មិនបាន យើងអាចរៀនដោយសេចក្តីជ្រះថ្លាចុះ ។

៣. **បដិវេធ** គឺជាផលដែលចាក់ធ្លុះ ឃើញច្បាស់បានពីការបដិបត្តិនោះ បានដល់មគ្គ ៤ ផល ៤ និងនិព្វាន ១ ។

-បើអ្នកមិនបានដើរតាមចំណុចទាំង ២ ខាងលើ មិនបានត្រឹមត្រូវផង អ្នកមិនចាំបាច់សង្ឃឹមថាបានចាក់ធ្លុះនូវសច្ចធម៌ឡើយ។

## -ការចាំធម៌ ការយល់ធម៌ ការបដិបត្តិធម៌ ការចាក់ធ្លុះធម៌

១. ការចាំធម៌ បានដល់សញ្ញាចេតសិក ។

២. ការយល់ធម៌ បានដល់ បញ្ញាចេតសិក (ថ្នាក់បរិយត្តិធម៌)

៣. ការបដិបត្តិធម៌ បានដល់បញ្ញា (ថ្នាក់បដិបត្តិធម៌)

-អង្គធម៌ បានដល់ សតិចេតសិក និងបញ្ញាចេតសិក ។

៤. ការចាក់ធ្លុះធម៌ បានដល់បញ្ញា (ថ្នាក់បដិវេធធម៌)

គឺបានដល់បញ្ញានៅក្នុងមគ្គ ៤ ផល ៤ និព្វាន ១ ដែលមានសតិប្បដ្ឋាន ៤ ឬវិបស្សនាជាជំនួយ ។

-ព្រះពុទ្ធ « អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ » ។

-សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើងនឹងវិនាសទៅវិញជាធម្មតា រមែងកើតឡើង ហើយក៏រលត់ទៅវិញ លុះតែរលត់នូវសង្ខារធម៌ទាំងឡាយនោះហើយ ទើបបាននូវសេចក្ដីសុខគ្រប់យ៉ាង ។

-ព្រះអង្គ ប្រកាសសច្ចធម៌ ៤ មានទុក្ខសច្ចៈ ១ សមុទយសច្ចៈ ១ និរោធសច្ចៈ ១ មគ្គសច្ចៈ ១ ។

-អត្ថនៃពាក្យ សង្ខារធម៌ទាំងឡាយ គឺបានដល់ បញ្ចក្ខន្ធ មានរូបក្ខន្ធជាដើម ។

-អត្ថនៃពាក្យ លុះរលត់នូវសង្ខារធម៌ទាំងឡាយ គឺរលត់នូវបញ្ចក្ខន្ធ ទើបបាននូវសេចក្ដីសុខគ្រប់យ៉ាង បានដល់ ព្រះនិព្វាន ។

-ព្រះពុទ្ធ « បុគ្គលណា មិនមានសេចក្តីកង្វល់ក្នុងកាលមុនផង ក្នុងកាលខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គលដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់ នោះថាជាព្រាហ្មណ៍ » ។

-អត្ថនៃពាក្យ សេចក្តីកង្វល់ សេចក្តីប្រកាន់ គឺបានដល់បញ្ចក្ខន្ធ មានរូបក្ខន្ធជាដើម ។

-ការមិនមានសេចក្តីប្រកាន់ ការមិនមានសេចក្តីកង្វល់ តថាគតហៅថា ព្រះនិព្វាន ។

## -ព្រះអស្សជិពោលធម្មបរិយាយចំពោះបរិព្វាជកឈ្មោះសារីបុត្ត

« យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ (អាហ)

តេសញ្ច យោ និរោធោ ឯវំវាទី មហាសមណោតិ »

« ធម៌ទាំងឡាយណា គឺ ខន្ធ ៥ តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀតសេចក្តីរលត់នឹងឧបាយជាគ្រឿងរលត់នូវធម៌ទាំងឡាយណា ព្រះតថាគតពោលនូវសេចក្តីរលត់នឹងឧបាយជាគ្រឿងរលត់នូវធម៌ទាំងឡាយនោះ ព្រះមហាសមណៈទ្រង់មានប្រក្រតីពោលយ៉ាងនេះ » ។

-ព្រះអង្គ ប្រកាសសច្ចធម៌ ៤ មានទុក្ខសច្ចៈ ១ សមុទយសច្ចៈ ១ និរោធសច្ចៈ ១ មគ្គសច្ចៈ ១ ។

(បិដកលេខ ៦ ទំព័រ ១២៧ មហាខន្ធកៈ)

## -ធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធសម្តែងចុះ ២ លក្ខណៈគឺ ៖

១.វិសេសលក្ខណៈឬ បច្ចត្តលក្ខណៈ គឺលក្ខណៈពិសេសរបស់សភាវធម៌មួយៗ ។

-ព្រះសម្មាសម្ពុទ្ធព្រះអង្គសម្តែងថា រូប តើដូចម្តេច?

-វេទនា តើដូចម្ដេច? សញ្ញា តើដូចម្ដេច? សង្ខារ តើដូចម្ដេច? វិញ្ញាណ តើដូចម្ដេច? សុខវេទនា តើដូចម្ដេច?

ទុក្ខវេទនា តើដូចម្ដេច? បឋវី តើដូចម្ដេច?

២. សាមញ្ញលក្ខណៈ គឺត្រៃលក្ខណ៍ធម៌ អនិច្ចំ (មិនទៀង) ទុក្ខំ (ជាទុក្ខ) អនត្តា (មិនមែនជាខ្លួន) ។

-ព្រះសម្មាសម្ពុទ្ធព្រះអង្គសម្ដែងថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀង កាលណារបស់ណាមិនទៀង របស់នោះជាទុក្ខ កាលណារបស់ណាជាទុក្ខ របស់នោះមិនមែនជាខ្លួន ។

**-បុគ្គលគប្បីមានប្រាជ្ញាដ៏ប្រពៃតាមសេចក្ដីពិតយ៉ាងនេះថា៖**

-នុ៎ះមិនមែនអញ (មិនប្រកាន់ដោយមានះ)

-នុ៎ះមិនមែនជារបស់អញ (មិនប្រកាន់ដោយតណ្ហា)

-នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ (មិនប្រកាន់ដោយទិដ្ឋិ)

-ឯសេវន្តោ ទុក្ខស្ស នេះឯងជាទីបំផុតនៃសេចក្ដីទុក្ខ ៕

## -អរិយមគ្គអង្គ ៨ ប្រការ អង្គធម៌ បានដល់អ្វីខ្លះ?

១. សម្មាទិដ្ឋិ ការយល់ត្រូវ អង្គធម៌ បញ្ញាចេតសិក

២. សម្មាសង្កប្បៈ ការត្រិះរិះត្រូវ អង្គធម៌ វិតក្កចេតសិក

៣. សម្មាវាចា ការនិយាយត្រូវ អង្គធម៌ សម្មាវាចាចេតសិក

៤. សម្មាកម្មន្ត ការងារត្រូវ អង្គធម៌ សម្មាកម្មន្តចេតសិក

៥. សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ អង្គធម៌ សម្មាអាជីវចេតសិក

៦. សម្មាវាយាម ការព្យាយាមត្រូវ អង្គធម៌ វីរិយចេតសិក

៧. សម្មាសតិ ការរឭកត្រូវ អង្គធម៌ សតិចេតសិក

៨. សម្មាសមាធិ ការតម្កល់ចិត្តនឹងត្រូវ អង្គធម៌ ឯកគ្គតាចេតសិក

# ចប់ សោភណចេតសិក ២៥

# ចប់ មេរៀនចេតសិក ៥២

## IV. ចេតសិក ៥២ ដោយសង្ខេប

## ក. អញ្ញសមានាចេតសិក ១៣

១. ផស្សៈ ការប៉ះខ្ទប់ ការពាល់ត្រូវ ការទង្គក់ទង្គិច ។

២. វេទនា ការរងនូវអារម្មណ៍ ការសោយនូវអារម្មណ៍ ។

៣. សញ្ញា ការចងចាំ ឬ ការចំណាំនូវអារម្មណ៍ ។

៤. ចេតនា ការតាំងចិត្ត ការផ្គង់ចិត្ត (ធ្វើអ្វីមួយ) ឬការខ្វល់ខ្វាយក្នុងការតាក់តែងធម៌ ដែលជាសង្ខតៈ (តួចេតនា ជាតួកម្ម) ។

៥. ឯកគ្គតា សេចក្តីស្ងប់ក្នុងអារម្មណ៍តែមួយ ។

៦. ជីវិតិន្ទ្រិយ ការរក្សាសហជាតធម៌ (តួជីវិតរបស់នាម) ។

៧. មនសិការៈ ការរួបរួមសហជាតធម៌ (គឺនាំសម្បយុត្តធម៌ទៅកាន់អារម្មណ៍) ឬការធ្វើទុកក្នុងចិត្ត។

៨. វិតក្កៈ ការលើកចិត្តឡើងកាន់អារម្មណ៍ ឬការត្រិះរិះ (នឹក) ដល់អារម្មណ៍ ។

៩. វិចារៈ ការពិចារណាក្នុងអារម្មណ៍ ។

១០. អធិមោក្ខៈ ការដាក់ចិត្តស៊ប់ (សន្និដ្ឋាន) ។

១១. វីរិយៈ សេចក្ដីព្យាយាម ។

១២. បីតិ សេចក្ដីត្រេកអរ រីករាយ ស្រស់ស្រាយ ឆ្អែតកាយ ឆ្អែតចិត្ត ។

១៣. ឆន្ទៈ សេចក្ដីពេញចិត្ត សេចក្ដីប្រាថ្នាដើម្បីនឹងធ្វើអ្វីមួយ។

## ខ. អកុសលចេតសិក ១៤

១. មោហៈ ការវង្វេង ការមិនដឹង ។

២. អហិរិកៈ ការមិនខ្មាសបាប មិនខ្ពើមបាប មិនរង្កៀសបាប ។

៣. អនោត្តប្បៈ ការមិនតក់ស្លុតបាប ការមិនខ្លាចបាប ។

៤. ឧទ្ធច្ចៈ ការរវើរវាយ (មិនស្ងប់) ។

៥. លោភៈ ការជាប់ជំពាក់ ។

៦. ទិដ្ឋិ ការយល់ខុស ។

៧. មានះ ការតម្កើងខ្លួន ។

៨. ទោសៈ ការប្រទូសរ៉ាយ ការខឹងក្រោធ ។

៩. ឥស្សា ការច្រណែន ។

១០. មច្ឆរិយៈ សេចក្ដីកំណាញ់ ។

១១. កុក្កុច្ចៈ ការក្ដៅក្រហាយ ការស្ដាយក្រោយ ។

១២. ថីនៈ ការធុញទ្រាន់ ការរួញរា ។

១៣. មិទ្ធៈ ការងោកងុយ ការងោកងក់ ការងងុយដេក ខ្ជិល ។

១៤. វិចិកិច្ឆា សេចក្តីសង្ស័យ ។

## គ. សោភណចេតសិក ២៥

១. សទ្ធា ការជឿជាក់ ការទុកចិត្ត (កុសល) ។

២. សតិ ការរឭក ការមានស្មារតី ។

៣. ហិរិ ការខ្មាសបាប ខ្ពើមបាប រង្កៀសចំពោះបាប ។

៤. ឱត្តប្បៈ ការខ្លាចបាប ការតក់ស្លុត ការញញើតចំពោះបាប។

៥. អលោភៈ ការមិនជាប់ជំពាក់ ។

៦. អទោសៈ ការមិនប្រទូសរ៉ាយ ការមិនខឹងក្រោធ (មេត្តា) ។

៧. តត្រមជ្ឈត្តតា ភាពជាកណ្តាលក្នុងធម៌នោះៗ ឬធម៌ឱ្យធ្វើ ចិត្ត និង ចេតសិកមានលំនឹង ។

៨. កាយបស្សទ្ធិ សេចក្តីស្ងប់កាយ ។

៩. ចិត្តបស្សទ្ធិ សេចក្តីស្ងប់ចិត្ត ។

១០. កាយលហុតា សេចក្តីស្រាលនៃកាយ ។

១១. ចិត្តលហុតា សេចក្តីស្រាលនៃចិត្ត ។

១២. កាយមុទុតា ភាពទន់ភ្លន់នៃកាយ ។

១៣. ចិត្តមុទុតា ភាពទន់ភ្លន់នៃចិត្ត ។

១៤. កាយកម្មញ្ញតា សេចក្តីគួរដល់ការងារនៃកាយ ។
១៥. ចិត្តកម្មញ្ញតា សេចក្តីគួរដល់ការងារនៃចិត្ត ។

១៦. កាយបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃកាយ ។

១៧. ចិត្តបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃចិត្ត ។

១៨. កាយុជុកតា សេចក្តីស្មោះត្រង់នៃកាយ ។
១៩. ចិត្តុជុកតា សេចក្តីស្មោះត្រង់នៃចិត្ត ។

២០. សម្មាវាចា ការនិយាយត្រូវ (វាចាប្រពៃ) ។

២១. សម្មាកម្មន្តៈ ការងារត្រូវ (ការងារប្រពៃ) ។

២២. សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ (ការចិញ្ចឹមជីវិតប្រពៃ)។

២៣. ករុណា ការអាណិតអាសូរ ។

២៤. មុទិតា ការត្រេកអរ ចំពោះសេចក្តីសុខអ្នកដទៃ ។

២៥. បញ្ញា ការដឹងទូទៅ ការដឹងធម៌តាមសេចក្តីពិត ការដឹងច្បាស់ គឺដឹងអរិយសច្ចធម៌ ៤ មានទុក្ខអរិយសច្ចៈជាដើម ។

# ចប់ ចេតសិក ៥២ ដោយសង្ខេប

# -ចេតសិក ដែលសំខាន់ៗ យើងសិក្សាឱ្យបានច្បាស់ ដើម្បីយកមកបដិបត្តិនៅក្នុងជីវិតប្រចាំថ្ងៃ

## ក. អញ្ញសមានាចេតសិក ១៣

១. វេទនា ការរងនូវអារម្មណ៍ ការសោយនូវអារម្មណ៍ ។

២. សញ្ញា ការចងចាំ ឬ ការចំណាំនូវអារម្មណ៍ ។

៣. ចេតនា ការតាំងចិត្ត ការផ្តង់ចិត្ត (ធ្វើអ្វីមួយ) ឬការខ្វល់ខ្វាយក្នុងការតាក់តែងធម៌ ដែលជាសង្ខត:

៤. មនសិការ: ការរួបរួមសហជាតធម៌ (គឺនាំសម្បយុត្តធម៌ទៅកាន់អារម្មណ៍) ឬការធ្វើទុកក្នុងចិត្ត។

៥. វិតក្ក: ការលើកចិត្តឡើងកាន់អារម្មណ៍ ឬការត្រិះរិះ (នឹក) ដល់អារម្មណ៍ ។

៦. វិរិយ: សេចក្តីព្យាយាម ។

## ខ. អកុសលចេតសិក ១៤

៧. មោហ: ការវង្វេង ការមិនដឹង ។

៨. ឧទ្ធច្ច: ការរវើរវាយ (មិនស្ងប់) ។

៩. លោភៈ ការជាប់ជំពាក់ ។

១០. ទិដ្ឋិ ការយល់ខុស ។

១១. មានះ ការតម្កើងខ្លួន ។

១២. ទោសៈ ការប្រទូសរ៉ាយ ការខឹងក្រោធ ។

១៣. ឥស្សា ការច្រណែន ។

១៤. មច្ឆរិយៈ សេចក្តីកំណាញ់ ។

១៥. កុក្កុច្ចៈ ការក្តៅក្រហាយ ការស្តាយក្រោយ ។

១៦. ថីនៈ ការធុញទ្រាន់ ការរួញរា ។

១៧. មិទ្ធៈ ការងោកងុយ ការងោកងក់ ការងងុយដេក ខ្ជិល ។

១៨. វិចិកិច្ឆា សេចក្តីសង្ស័យ ។

## គ. សោភណចេតសិក ២៥

១៩. សទ្ធា ការជឿជាក់ ការទុកចិត្ត (ជាកុសល) ។

២០. សតិ ការរឭក ការមានស្មារតី ។

២១. អលោភៈ ការមិនជាប់ជំពាក់ ។

២២. អទោសៈ ការមិនប្រទូសរ៉ាយ ការមិនខឹងក្រោធ (មេត្តា) ។

២៣. តត្រមជ្ឈត្តតា ភាពជាកណ្តាលក្នុងធម៌នោះៗ ឬធម៌ឱ្យធ្វើ
ចិត្ត និង ចេតសិកមានលំនឹង ។

២៤. សម្មាវាចា ការនិយាយត្រូវ (វាចាប្រពៃ) ។

២៥. សម្មាកម្មន្តៈ ការងារត្រូវ (ការងារប្រពៃ) ។

២៦. សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ (ការចិញ្ចឹមជីវិតប្រពៃ)។

២៧. ករុណា ការអាណិតអាសូរ ។

២៨. មុទិតា ការត្រេកអរ ចំពោះសេចក្តីសុខអ្នកដទៃ ។

២៩. បញ្ញា ការដឹងទូទៅ ការដឹងធម៌តាមសេចក្តីពិត ការដឹង
ច្បាស់ គឺដឹងអរិយសច្ចធម៌ ៤ មានទុក្ខអរិយសច្ចៈជាដើម ។

# -ថ្ងៃល្អនៃជីវិត

- បុណ្យ បាប គឺឋិតនៅក្នុងចិត្ត បើអ្នកទៅរកនៅឯរបស់ខាងក្រៅ អ្នកមិនអាចរកឃើញបានទេ។
- សុខ ទុក្ខ គឺឋិតនៅក្នុងចិត្ត បើអ្នកទៅរកសុខ ទុក្ខ នៅរបស់ខាងក្រៅ អ្នកមិនអាចរកឃើញបានទេ។

-ថ្ងៃណាក៏ល្អដែរឱ្យតែមនុស្សធ្វើល្អ ដូចមានសម្តែងក្នុងបិដក ៤១ ទំព័រ ៤៧៥ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា៖

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**

**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។**

-ថ្ងៃណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត ថ្ងៃនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ ទានដែលបុគ្គលបូជាដល់ព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងពេលនោះ ឈ្មោះថា ជាគ្រឿងបូជាល្អ ។

# -ពាក្យខមាទោសចំពោះព្រះរតនត្រៃ

## ១. ខមាទោសចំពោះព្រះពុទ្ធរតនៈ

« ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខម តុតំ មមំ » ។

ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

## ២. ខមាទោសចំពោះព្រះធម្មរតនៈ

« ធម្មេយោខលិតោ ទោសោ ធម្មោ ខម តុតំ មមំ » ។

ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

## ៣. ខមាទោសចំពោះព្រះសង្ឃរតនៈ

« សង្ឃេ យោខលិតោទោសោ សង្ឃោ ខម តុតំ មមំ » ។

ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

## -ការជូនបុណ្យធម្មទានដល់ញាតិ និងទេវតា

« ទេវា គន្លា និវេទយុំ សព្វេលោកម្ហិ យេ សត្តា ជីវន្តាហារ ហេតុកា មនុញ្ញំភោជនំ សព្វេ លភន្តុ មម ចេតសាតិ » ។

ប្រែ ៖ សត្វទាំងឡាយណា បានដឹងច្បាស់ នូវបុណ្យដែលខ្ញុំបានធ្វើហើយ នោះ សត្វទាំងនោះ (ចូរបានទទួល) នូវផលនៃបុណ្យដែលខ្ញុំឱ្យហើយ ម្យ៉ាងទៀត បណ្ដាសត្វទាំងនោះ សត្វទាំងឡាយណា មិនបានដឹង សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹង (ដល់សត្វទាំងនោះ) ផង។

## -ការផ្សាយមេត្តាចំពោះសព្វសត្វ

« ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ » ។

ប្រែ៖ សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្ដីទុក្ខ សូមឱ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្ដីសោក សូមឱ្យជាសត្វ បាត់សេចក្ដីសោកទៅហោង ៕